ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកោះកុង

# របាយការណ៍

# ស្ដីពី

# ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង

# ប្រចាំខែឧសភា ឆ្នាំ២០២៤

ព.ស.២៥៦៧ ឆ្នាំ២០២៤

# មាតិកានុក្រម


ទំព័រ

សេចក្តីផ្តើម ........ ១

ផ្នែកទី១៖សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត ........ ២

១.១-ការងាររដ្ឋបាល ........ ២

១.១.១-ការងាររបៀប និងឯកសារ ........ ២

១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន ........ ២

១.១.៣-ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ........ ៣

១.១.៤-ការងារសរុប និងព័ត៌មាន ........ ៣

១.១.៥-ការងារលេខាធិការក្រុមប្រឹក្សា ........ ៤

១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា ........ ៤

១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា ........ ៥

១.២-ការងារផែនការ និងវិនិយោគ ........ ៦

១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ........ ៦

១.២.២-ការគាំទ្រមូលដ្ឋាន ........ ៦

១.២.៣-ការវិនិយោគ ........ ៨

១.២.៤-ការងារសេវាសង្គម ........ ៩

១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប. ........ ៩

១.២.៦-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា ........ ១០

១.៣-ការគ្រប់គ្រងធនធានមនុស្ស ........ ១០

១.៣.១-ការងារគ្រប់គ្រងបុគ្គលិក ........ ១០

១.៣.២-ការងារកសាងសមត្ថភាព ........ ១១

១.៤-ការងារអន្តរវិស័យ ........ ១២

១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច ........ ១២

១.៤.២-ការងារគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ ........ ១២

១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ ........ ១៣

១.៤.៤-ការងារគ្រប់គ្រងកាកសំណល់ ........ ១៣

១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ ........ ១៣

១.៦-ការងារការិយាល័យប្រជាពលរដ្ឋ(សម្រុះសម្រួលដោះស្រាយបណ្តឹង) ........ ១៤

១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត ........ ១៥

១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន ........ ១៥

១.៨.១-ច្រកទ្វារព្រំដែនដែលកំពុងដំណើរការ ........ ១៥

១.៨.២-សន្តិសុខ និងសណ្តាប់ធ្នាប់តាមព្រំដែន ........ ១៥

១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ) ........ ១៥

១.៨.៤-ការផ្លាស់ប្តូរទំនិញ ........ ១៥

១.៨.៥-កិច្ចសហប្រតិបត្តិការ ........ ១៥

១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ ........ ១៦

១.៩.១-ការងារហិរញ្ញវត្ថុ ........ ១៦
១.៩.២-ការងារគណនេយ្យ ........ ១៦
១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ ........ ១៧
១.១០-ការងារលទ្ធកម្ម ........ ១៧
១.១១-ការងារសុខាភិបាល ........ ១៧
១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល ........ ១៨
១.១៣-ការងារផ្សេងៗ ........ ១៨
ផ្នែកទី២៖សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ ........ ១៩
២.១-ផ្នែកសេដ្ឋកិច្ច ........ ១៩
២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ១៩
២.១.២-ការងារធនធានទឹក និងឧតុនិយម ........ ២១
២.១.៣-ការងារអភិវឌ្ឍជនបទ ........ ២១
២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ........ ២២
២.១.៥-ការងាររ៉ែ និងថាមពល ........ ២២
២.១.៦-ការងារពាណិជ្ជកម្ម ........ ២៣
២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ ........ ២៤
២.១.៧.១-ការងារហិរញ្ញវត្ថុ ........ ២៤
២.១.៧.២-ការងារពន្ធដារ ........ ២៤
២.១.៧.៣-ការងារគយ និងរដ្ឋាករ ........ ២៤
២.១.៨-ការងារទេសចរណ៍ ........ ២៤
២.១.៩-ការងារផែនការ ........ ២៥
២.១.១០-ការងារផ្សេងៗ ........ ២៦
២.១.១០.១-ការងារសាខាធនាគារជាតិ ........ ២៦
២.១.១០.២-ការងាររតនាគារ ........ ២៦
២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ........ ២៦
២.២-ផ្នែកសង្គមកិច្ច ........ ២៦
២.២.១-ការងារអប់រំ យុវជន និងកីឡា ........ ២៦
២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ ២៧
២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម ........ ២៨
២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ........ ២៨
២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម ........ ២៩
២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ ........ ៣០
២.២.៥-ការងារព័ត៌មាន ........ ៣០
២.២.៦-ការងារកិច្ចការនារី ........ ៣១
២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ........ ៣១
២.២.៨-ការងារធម្មការ និងសាសនា ........ ៣២
២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ........ ៣២

២.២.១០-ការងារមុខងារសាធារណៈ ...................................... ៣៣
២.២.១១-ការងារផ្សេងៗ ...................................... ៣៤
២.២.១១.១-ការងារសាលាដំបូងខេត្ត ...................................... ៣៤
២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ...................................... ៣៥
២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ...................................... ៣៥
២.៣.២-ការងារបរិស្ថាន ...................................... ៣៦
២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន ...................................... ៣៦
២.៣.៤-ការងារផ្សេងៗ ...................................... ៣៧
២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ...................................... ៣៧
២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ...................................... ៣៧
២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍ ...................................... ៣៩
២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត ...................................... ៤០
២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ ...................................... ៤១
២.៤.៥-ការងារផ្សេងៗ ...................................... ៤១
ផ្នែកទី៣៖បញ្ហាប្រឈម និងសំណើដោះស្រាយ ...................................... ៤២
ផ្នែកទី៤៖ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅខែបន្ទាប់ ...................................... ៤២
ឧបសម្ព័ន្ធ
ឧបសម្ព័ន្ធទី១៖ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំខែឧសភា
ឧបសម្ព័ន្ធទី២៖ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំខែឧសភា
ឧបសម្ព័ន្ធទី៣៖វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគ នៃរដ្ឋបាលខេត្ត ប្រចាំខែមេសា (ថវិកាវិភាជន៍ពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសប្បុរសជន)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកោះកុង**
លេខ ២៤៣/២៤

ថ្ងៃ ពុធ៦កើត ខែ ជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨
ខេត្តកោះកុង ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២៤

# របាយការណ៍
## ស្តីពី
## ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង ប្រចាំខែឧសភា ឆ្នាំ២០២៤

**សេចក្តីផ្តើម**

ខេត្តកោះកុង មានទីតាំងស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ចម្ងាយ២៩០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងលិច និងខាងត្បូងជាប់នឹងឈូងសមុទ្រថៃ និងប្រទេសថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ និងមានផ្ទៃដីសរុប ១០.០៤៥,៥៨គ.ម² មានក្រុង១ ស្រុក៦ ឃុំ២៦ សង្កាត់៣ និងមានភូមិសរុបចំនួន១១៩ភូមិ។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ និងព្រះរាជក្រឹត្យលេខ នស/រកត/០៦១៩/៧៥២ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៩ ត្រាស់បង្គាប់ទទួលស្គាល់សមាជិកក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៣។ ក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៣ មានសមាសភាព១៩រូប ស្រី២រូប ប្រធាន១រូបប្រុស និងមាន គណៈកម្មាធិការ ជាកាតព្វកិច្ចចំនួន៤រួមមាន៖ ១).គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ២).គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ៣).គណៈកម្មាធិការលទ្ធកម្ម និង ៤).គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម។

ដោយមានស្ថានភាពភូមិសាស្ត្រអំណោយផលពីធម្មជាតិ នាំឱ្យខេត្តកោះកុង មានសក្តានុពលដ៏សម្បូរបែបអាចបម្រើដល់វិស័យជាច្រើន ជាពិសេសវិស័យទេសចរណ៍ រួមមាន ៖ តំបន់ធម្មជាតិដ៏ស្រស់ត្រកាលគ្របដណ្តប់ដោយព្រៃភ្នំជ្រលងដងអូរ តំបន់អេកូទេសចរណ៍ធម្មជាតិព្រៃកោងកាងទំហំ១២.០០០ហិកតា តំបន់ព្រំដែនមានសណ្ឋាគារលំដាប់ផ្កាយ៥ជាប់មាត់សមុទ្រ តំបន់សេដ្ឋកិច្ចពិសេសកោះកុង តំបន់កោះទាំង២៣ មានប្រជុំកោះ៩ ដែលមានផ្កាថ្មដ៏ស្រស់ស្អាត និងតំបន់ឆ្នេរសមុទ្រមានប្រវែង២១៧គីឡូម៉ែត្រ លាតសន្ធឹងពីចំណុចជ្រោយស្វាយ ស្រុកស្រែអំបិល រហូតដល់ចំណុចចាំយាម ស្រុកមណ្ឌលសីមា ស្មើនឹង៤៩% នៃប្រវែងឆ្នេរសមុទ្រ៤៤០គីឡូម៉ែត្រ នៃព្រះរាជាណាចក្រកម្ពុជា។ តំបន់វិស្សមកាលតារាសាគរកោះស្តេចដែលមានទីលានវាយកូនហ្គោលខ្នាតអន្តរជាតិ តំបន់កសិ-ឧស្សាហកម្មចម្រុះ និងទំនប់វារីអគ្គិសនីចំនួន៤កន្លែង។ ក្រៅពីនេះខេត្តកោះកុង មានដៃព្រែកធំៗចំនួន៥ បានរួមចំណែកក្នុងការរុញច្រានកំណើនសេដ្ឋកិច្ចខេត្ត រួមមាន ព្រែកកោះប៉ោះ ព្រែកតាតៃ ព្រែកត្រពាំងរូង ព្រែកអណ្តូងទឹក និងព្រែកស្រែអំបិល។

ក្រុមប្រឹក្សាខេត្ត រួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង គោលដៅ ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ(២០២០-២០២៤) ក្នុងការលើកកម្ពស់អភិបាលកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានស្របតាមច្បាប់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តិនានា ដោយផ្តោតលើគោលដៅអភិវឌ្ឍន៍ដូចជា៖ ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ លូ ស្ពាន សួនច្បារ សួនកម្សាន្ត សំណង់អគារ រមណីយដ្ឋានទេសចរណ៍ អគ្គិសនី ទឹកស្អាត វប្បធម៌ សាសនា និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។

# ផ្នែកទី១÷សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត

## ១.១-ការងាររដ្ឋបាល

### ១.១.១-ការងាររបៀប និងឯកសារ

- បានរៀបចំកែសម្រួលបញ្ជីទុកដាក់លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ ដើម្បីឆ្លើយតបតាមការណែនាំរបស់គណៈអភិបាលខេត្ត
- បានកត់ត្រា និងដំណើរការចរន្តឯកសាររដ្ឋបាល ជូនថ្នាក់ដឹកនាំ និងមន្ទីរ អង្គភាពពាក់ព័ន្ធបានល្អប្រសើរ
- បានទំនាក់ទំនង សម្របសម្រួល និងតាមដានរាល់លិខិតចេញ ចូល របស់រដ្ឋបាលខេត្ត ជាប់ជាប្រចាំ។

តារាងទី១៖លិខិតបទដ្ឋាន និងឯកសារប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ដីកាដែលបានដាក់ចេញ | ១៧ | ១១ | ២៨ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ២១ | ៦ | ២៧ |
| ៣ | លិខិតដែលបានដាក់ចេញ | ១.២៧០ | ៣៩៦ | ១.៦៦៦ |
| ៤ | លិខិតចូល | ១.២១៤ | ២៤៩ | ១.៤៦៣ |
| ៥ | ឯកសារដែលបានធ្វើនីត្យានុកូលកម្ម | ១០ | ៥ | ១៥ |
| ៦ | អនុស្សរណៈឬកិច្ចព្រមព្រៀង | 0 | 0 | 0 |
| ៧ | សៀវភៅគ្រួសារ | ២៧៦ | ៤៧ | ៣២៣ |
| ៨ | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ៤.០៨៧ | ៧២៤ | ៤.៨១១ |

### ១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន

- បានស្រាវជ្រាវពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬខូច ដោយយថាហេតុ តាមការស្នើសុំរបស់សាមីខ្លួនចំនួន៣នាក់ ក្នុងនោះ ស្រុកកោះកុង២នាក់ និងស្រុកមណ្ឌលសីមាចំនួន១នាក់)
- បានស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈមេឃុំចៅសង្កាត់ បានចំនួន៣០នាក់ ក្នុងនោះ ក្រុងខេមរភូមិន្ទចំនួន៩នាក់ ស្រុកមណ្ឌលសីមា២០នាក់ និងស្រុកកោះកុងចំនួន១នាក់)
- បានបញ្ជូនដីកាសម្រេចកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានពីសាលាដំបូងខេត្តកោះកុងទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃចំនួន៤១ច្បាប់។

តារាងទី២៖ស្ថិតិប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | គ្រួសារសរុប | ៣៥.៦២៦ | |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៣៤.០២៥ | |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១.៦០១ | |
| ៤ | ស្ត្រីជាមេគ្រួសារ | ៧.២១១ | |
| ៥ | ប្រជាពលរដ្ឋសរុប | ១៥២.៣៤២ | ៧៧.៤១៣ |
| ៦ | កុមារអាយុក្រោម៦ឆ្នាំ | ១៥.១៩៦ | ៧.៨១៤ |

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ៧ | កុមារអាយុពី៦ឆ្នាំដល់ក្រោម១៨ឆ្នាំ | ៣៩.៧៤៩ | ១៩.៧៤៦ |
| ៨ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៩៧.៣៩៧ | ៤៩.៨៥៣ |
| ៩ | ប្រជាពលរដ្ឋចំណាកស្រុកក្នុងប្រទេស | ៥.៣៦៤ | ២.៣៧៤ |
| ១០ | ប្រជាពលរដ្ឋចំណាកស្រុកក្រៅប្រទេស | ១.៣៨៧ | ៥៧៩ |

តារាងទី៣៖អត្រានុកូលដ្ឋាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ស្ថិតិចុះបញ្ជីកំណើត | ៥៧៣ | ១៦៦ | ៧៣៩ |
| ២ | បញ្ជាក់កំណើត | ៩៤៥ | ១៧១ | ១.១១៦ |
| ៣ | បញ្ជីមរណភាព | ១៤៩ | ៤២ | ១៩១ |
| ៤ | អាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | ១,០២៦ | ២២៩ | ១.២៥៥ |
| ៥ | អាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | ៧ | ១ | ៨ |

### ១.១.៣-ការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលការងារជូនគណៈប្រតិភូគណៈកម្មាធិការប្រជាជនខេត្ត និងជាប្រធានគណៈកម្មការជំនាញខេត្តគៀនយ៉ាង និងដឹកនាំប្រតិភូអញ្ជើញជួបសួរសុខទុក្ខ និងលើកទឹកចិត្តក្រុមK92 (គៀនយ៉ាង) ដែលកំពុងឈរជើងបំពេញភារកិច្ចនៅវរសេនាតូចលេខ៣ ស្ថិតនៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានសម្របសម្រួលសហការរៀបចំកម្មវិធីប្រកួតកីឡាបាល់ទាត់ដើម្បីផ្សារភ្ជាប់ទំនាក់ទំនង រវាងអ្នកប្រតិបត្តិការងារព្រំដែនកម្ពុជា-ថៃ នៅទីលានបាល់ទាត់ស្មោសិប្បនិមិត្ត បានហួងសោម ភូមិលេខ៣ ឃុំម៉ាយរ៉ូត ស្រុកខ្លងយ៉ៃ ខេត្តត្រាត។

តារាងទី៤៖ការងារទំនាក់ទំនងសាធារណៈ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សាធារណជនមកទំនាក់ទំនងនៅសាលាខេត្ត | ១,១៩៩ | ២៤៩ | ១.៤៤៨ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ៦ | ៣ | ៩ |

### ១.១.៤-ការងារសរុប និងព័ត៌មាន

- បានរៀបចំសេចក្តីព្រាងរបាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្តប្រចាំខែឧសភា ឆ្នាំ២០២៤
- បានរៀបចំបូកសរុបរបាយការណ៍ ស្តីពីសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់ និងព្រឹត្តិការណ៍សំខាន់ៗក្នុងខេត្តប្រចាំថ្ងៃ ជូនលោកជំទាវអភិបាលខេត្ត និងឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត
- បានរៀបចំផ្សព្វផ្សាយព័ត៌មានតាមបណ្តាញផ្សព្វផ្សាយនានារបស់រដ្ឋបាលខេត្ត។

តារាងទី៥៖ការផ្សព្វផ្សាយព័ត៌មាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | វិទ្យុ | ៨៤ | ១៨ | ១០២ |
| ២ | ទូរទស្សន៍ | ១៤០ | ២៧ | ១៦៧ |

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ៣ | បិទផ្សាយលើក្ដារព័ត៌មានសាធារណៈ | ៩ | ៣ | ១២ |
| ៤ | បណ្ដាញសង្គម (គេហទំព័ររដ្ឋបាលខេត្ត) | ២.៩៣៦ | ៧៣៦ | ៣.៦៧២ |
| ៥ | ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្ដី និងសារព័ត៌មាន | ០ | ០ | ០ |

### ១.១.៥-ការងារលេខាធិការក្រុមប្រឹក្សា

- បានសម្របសម្រួលដំណើរការកិច្ចប្រជុំ និងរៀបចំសេចក្ដីព្រាងកំណត់ហេតុកិច្ចប្រជុំសាមញ្ញលើកទី៦០ របស់ក្រុមប្រឹក្សាខេត្ត
- បានរៀបចំសេចក្ដីព្រាងរបៀបវារៈកិច្ចប្រជុំ និងលិខិតអញ្ជើញសម្រាប់កិច្ចប្រជុំសាមញ្ញលើកទី៦០ និងកិច្ចប្រជុំវិសាមញ្ញលើកទី៣ របស់ក្រុមប្រឹក្សាខេត្ត
- បានចាត់ចែងទុកដាក់ និងថែរក្សារាល់ឯកសារដែលបានអនុម័តរួចដោយក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលកិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលរាល់លិខិត និងឯកសារនានាដែលចរាចរចេញ ចូលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាខេត្ត បានទាន់ពេលវេលា។

តារាងទី៦៖ការរៀបចំវេទិកា (ពុំមាន)

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | | | |

### ១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា

### ក)-ការងារគណៈអភិបាល

**១. អភិបាល នៃគណៈអភិបាលខេត្ត**

- បានចូលរួមជាអធិបតី គណៈអធិបតី និងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សរុបចំនួន១៥លើក
- បានចាត់តាំងក្រុមការងារ និងទីចាត់ការចំណុះសាលាខេត្ត រៀបចំកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការធ្វើតេស្តហ៊ើសរកសារជាតុញៀនតាមទឹកមូត្រដល់ថ្នាក់ដឹកនាំ មន្ត្រី និងមន្ត្រីជាប់ កិច្ចសន្យា នៃរដ្ឋបាលខេត្ត ក្រុង ស្រុក។

**២. អភិបាលរង នៃគណៈអភិបាលខេត្ត**

- បានចូលរួមជាអធិបតី គណៈអធិបតី និងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងក្រៅប្រទេសសរុបចំនួន៩៧លើក។

តារាងទី៧៖កិច្ចប្រជុំគណៈអភិបាល

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ២ | ១ | ៣ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ០ | ០ | ០ |
| ៣ | កិច្ចប្រជុំផ្សេងៗរបស់គណៈអភិបាល | ៨ | ៣ | ១១ |

## ខ)-ការងារគណៈកម្មាធិការនានា

តារាងទី៨៖កិច្ចប្រជុំគណៈកម្មាធិការនានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ១ | ០ | ២ |
| ២ | កិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ | ៤ | ០ | ៤ |
| ៣ | កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ១ | ១ | ២ |
| ៤ | កិច្ចប្រជុំក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ៣ | ១ | ៤ |
| ៥ | ផ្សេងៗ...... | | | |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ២ | ១ | ៣ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ៤ | ១ | ៥ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ៤ | ១ | ៥ |

## ១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

- បានដំណើរការកិច្ចប្រជុំសាមញ្ញលើកទី៦០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត
- បានពិនិត្យ និងអនុម័តលើឯកសារពាក់ព័ន្ធនានាតាមរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញលើកទី៦០ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត
- បានដំណើរការកិច្ចប្រជុំសាមញ្ញលើកទី៦០ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត។

តារាងទី៩៖កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ៤ | ១ | ៥ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ១ | ០ | ១ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ | ០ | ០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ២ | ០ | ២ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ៤ | ១ | ៥ |
| ៦ | កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម | ២ | ១ | ៣ |
| ៧ | ផ្សេងៗ............ | ០ | ០ | ០ |

## ១.២-ការងារផែនការ និងវិនិយោគ

### ១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

- បានបូកសរុបបញ្ជីគម្រោងអាទិភាពរបស់ក្រុង ស្រុក ឃុំ សង្កាត់និងរៀបចំបញ្ជីគម្រោងអាទិភាពដែលប្រើប្រាស់ថវិកាខេត្ត ឆ្នាំ២០២៥-២០២៧។

តារាងទី១០៖ការអនុវត្តគម្រោងវិនិយោគ(មានការគាំទ្រ)

| ល.រ. | ផ្នែក | សរុប | តម្លៃគម្រោង (លានរៀល) | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|---|
| | | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ៨ | ១៣.៨៣២,២០ | ៨ | ០ | ០ |
| ២ | សង្គមកិច្ច | - | - | - | - | - |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | - | - | - | - | - |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | - | - | - | - | - |
| **សរុប** | | **៨** | **១៣.៨៣២,២០** | **៨** | **០** | **០** |

### ១.២.២-ការគាំទ្រមូលដ្ឋាន

#### ១.២.២.១-ការគាំទ្ររដ្ឋបាលក្រុង ស្រុក

តារាងទី១១៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក

| ល.រ | ការបរិយាយ | ចំនួនក្រុង ស្រុក | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |
| ១ | ជំហានទី១ | ៧ | ០ |
| ២ | ជំហានទី២ | ០ | ៧ |
| ៣ | ជំហានទី៣ | ០ | ៧ |

តារាងទី១២៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងក្រុង ស្រុក

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ១១ | ១១ | ០ | ០ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ០ | ០ | ០ | ០ |
| **សរុប** | | **១១** | **១១** | **០** | **០** |

### ១.២.២.២-ការគាំទ្ររដ្ឋបាលឃុំ សង្កាត់

- **ការសិក្សាគម្រោង**

– បានចុះសិក្សាគម្រោងសាងសង់ផ្លូវបេតុងអាមេ១ខ្សែ ប្រើប្រាស់មូលនិធិសង្កាត់ដងទង់ ឆ្នាំ២០២៤ ដែលមានប្រវែង០,០៩៦គ.ម ទទឹង២ម កម្រាស់១៥០ម.ម ដាក់លូមូលរំដោះទឹក៣ខ្សែ ប្រវែង៥៤៩ម អង្កត់ផ្ចិត៨០ស.ម រ៉ែហ្គាចំនួន៥១កន្លែង និងដាក់លូជ្រុងរៀបឥដ្ឋរំដោះទឹកប្រវែង២.៣៧០ម ទទឹង៥០ស.ម កម្ពស់៥០ស.ម ស្ថិតនៅភូមិ២ និងភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ

– បានចុះសិក្សាគម្រោងប្រើប្រាស់មូលនិធិឃុំថ្មស ឆ្នាំ២០២៤ ចំនួន២គម្រោងស្ថិតនៅឃុំថ្មស ស្រុកបូទុមសាគរ មានដូចខាងក្រោម៖

  - គម្រោងសាងសង់លូជ្រុងភ្លោះ៣មX១,៥ម ប្រវែង៦ម ចំនួន១កន្លែង ស្ថិតនៅភូមិស្រែត្រាវ
  - គម្រោងសាងសង់ផ្លូវក្រាលក្រួសធម្មជាតិ៤ខ្សែ ប្រវែងសរុប៥,១៧០គ.ម រួមមាន៖
    - ខ្សែទី១ ប្រវែង០,៤៧២គ.ម ទទឹង៦ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិថ្មស
    - ខ្សែទី២ ប្រវែង០,៣៥០គ.ម ទទឹង៦ម កម្រាស់១៥០ម.ម និងលូមូលភ្លោះកាត់ផ្លូវ១ម ចំនួន១កន្លែង អង្កត់ផ្ចិត១០០០ម.ម ប្រវែង៧ម ស្ថិតនៅភូមិថ្មស
    - ខ្សែទី៣ ប្រវែង០,៥១៤ម ទទឹង៦ម កម្រាស់១៥០ម.ម ដាក់លូមូលទោលកាត់ផ្លូវ០,៨ម ចំនួន១កន្លែង អង្កត់ផ្ចិត៨០០ម.ម ប្រវែង៧ម ស្ថិតភូមិស្រែថ្មី
    - ខ្សែទី៤ ប្រវែង៣,៨៣៤ម ទទឹង៦ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិចម្លងគោ

– បានចុះសិក្សាគម្រោងសាងសង់ផ្លូវបេតុងអាមេ១ខ្សែ ប្រើប្រាស់មូលនិធិឃុំជីផាត ឆ្នាំ២០២៤ មានប្រវែង១គ.ម ទទឹង៦ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិជីផាត ឃុំជីផាត ស្រុកថ្មបាំង

– បានចុះសិក្សាគម្រោងប្រើប្រាស់មូលនិធិឃុំថ្មដូនពៅ ឆ្នាំ២០២៤ ចំនួន២គម្រោង ស្ថិតនៅភូមិកោះ ឃុំថ្មដូនពៅ ស្រុកថ្មបាំង មានដូចខាងក្រោម៖

  - គម្រោងសាងសង់ផ្លូវបេតុងអាមេ១ខ្សែ ប្រវែង៥០០ម ទទឹង៦ម កម្រាស់១៥០ម.ម
  - គម្រោងសាងសង់រង្វង់មូលចំនួន១កន្លែង

– បានចុះសិក្សាគម្រោងប្រើប្រាស់មូលនិធិឃុំកោះស្ដេច ឆ្នាំ២០២៤ ចំនួន២គម្រោង ស្ថិតនៅឃុំកោះស្ដេច ស្រុកគិរីសាគរ រួមមាន៖

  - គម្រោងសាងសង់ផ្លូវក្រួសធម្មជាតិ១ខ្សែ ប្រវែង៤០០ម ទទឹង៦ម កម្រាស់១៥០ម.ម ដាក់លូមូលភ្លោះ អង្កត់ផ្ចិត១ម ចំនួន១កន្លែង និងលូជ្រុងភ្លោះ២ម X ៣ម ចំនួន១កន្លែង ស្ថិតនៅភូមិព្រែកស្មាច់
  - គម្រោងសាងសង់សាលាមត្តេយ្យសិក្សាសហគមន៍១ខ្នង ៣បន្ទប់ ស្ថិតក្នុងភូមិព្រែកស្មាច់

– បានចុះសិក្សាគម្រោងអភិវឌ្ឍន៍ស្រុកគិរីសាគរ ឆ្នាំ២០២៤ លើគម្រោងសាងសង់ផ្លូវបេតុងអាមេ១ខ្សែ ប្រវែង០,៦៥០គ.ម ទទឹង៦ម កម្រាស់១៥០ម.ម ស្ថិតក្នុងភូមិពាមកាយ ឃុំកោះស្ដេច ស្រុកគិរីសាគរ

– បានចុះសិក្សាគម្រោងប្រើប្រាស់មូលនិធិឃុំជីខក្រោម ឆ្នាំ២០២៤ លើគម្រោងសាងសង់ផ្លូវបេតុងអាមេ១ខ្សែ មានប្រវែង៥,០០០ម ទទឹង៥ម កម្រាស់ជីស៣០០ម.ម ស្ថិតនៅភូមិនាពិសី ឃុំជីខក្រោម ស្រុកស្រែអំបិល។

- **ការត្រួតពិនិត្យ និងវាយតម្លៃគម្រោង**

– បានត្រួតពិនិត្យ និងវាយលតម្លៃ ការអនុវត្តគម្រោងប្រើប្រាស់មូលនិធិឃុំកណ្ដោល ឆ្នាំ២០២៣ លើគម្រោងសាងសង់ផ្លូវក្រាលក្រួសក្រហម១ខ្សែ ប្រវែង០,៥៩០គ.ម ទទឹង៥ម កម្រាស់១៥០ម.ម និងដាក់លូមូល១កន្លែង អង្កត់ផ្ចិត១០០០ម.ម ប្រវែង៦ម ស្ថិតក្នុងភូមិកណ្ដោល ឃុំកណ្ដោល ស្រុកបូទុមសាគរ។ ជាលទ្ធផល ក្រុមហ៊ុនអនុវត្តការងារបាន១០០% ដោយសាងសង់ត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស

– បានចុះត្រួតពិនិត្យ និងវាយតម្លៃលើការធានារយៈពេល៦ខែ នៃកិច្ចសន្យាគម្រោងប្រើប្រាស់មូលនិធិឃុំភ្លីមាស ឆ្នាំ ២០២៣ លើគម្រោងសាងសង់ផ្លូវបេតុងអាមេ១ខ្សែប្រវែង០,៤៨៤គម ទទឹង៥ម កម្រាស់១៥០ម.ម ស្ថិតនៅភូមិតានី ឃុំភ្លីមាស ស្រុកគិរីសាគរ។ ជាលទ្ធផល គម្រោងផ្លូវបេតុងនៅមានគុណភាពល្អ និងត្រូវបានប្រើប្រាស់ជាប្រចាំដោយប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

តារាងទី១៣៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

| ល.រ. | ការបរិយាយ | ចំនួនឃុំ សង្កាត់ | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |
| ១ | ជំហានទី១ | ២៩ | ០ |
| ២ | ជំហានទី២ | ០ | ២៩ |
| ៣ | ជំហានទី៣ | ០ | ២៩ |

តារាងទី១៤៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ៤៧ | ១៩ | ៨ | ៦ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ០ | ០ | ០ | ០ |
| **សរុប** | | **៤៧** | **១៩** | **៨** | **៦** |

### ១.២.៣-ការវិនិយោគ

– បានចុះពិនិត្យការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់ នឹងធម្មជាតិខ្នាតតូច ដែលមានទំហំដីមិនលើសពី ១០ហិកតា ស្ថិតនៅទីតាំង ដូចខាងក្រោម៖
    - ឧទ្យានជាតិជួរភ្នំក្រវាញ ស្ថិតនៅភូមិគគីរជ្រុំ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ជាលទ្ធផល ពិនិត្យឃើញថា បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាត (ស.ជ.ណ) ពីក្រសួងបរិស្ថាន ម្ចាស់គម្រោង បានសហការជាមួយមន្ទីរបរិស្ថានខេត្ត និងអាជ្ញាធរពាក់ព័ន្ធបោះបង្គោលព្រំដីទីតាំងគម្រោងតាមរយៈនិយាមកា (UTM) ដែលបានកំណត់ក្នុង ស.ជ.ណ របស់ក្រសួងបរិស្ថានរួចរាល់ និងត្រឹមត្រូវ ប៉ុន្តែម្ចាស់គម្រោងពុំទាន់បានធ្វើសកម្មភាពអភិវឌ្ឍន៍គម្រោងនៅឡើយ
    - ឧទ្យានជាតិបទុមសាគរ ស្ថិតនៅក្នុងភូមិជីត្រេះ ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ។ ជាលទ្ធផល ក្រុមការងារ និងស្ថាប័នពាក់ព័ន្ធបានពិនិត្យឃើញថាបន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាត(ស.ជ.ណ) របស់ក្រសួងបរិស្ថាន ម្ចាស់គម្រោងបានសហការជាមួយមន្ទីរបរិស្ថានខេត្ត និងអាជ្ញាធរពាក់ព័ន្ធធ្វើការបោះបង្គោលព្រំដីទីតាំងគម្រោងតាមនិយាមកា (UTM) ដែលបានកំណត់ដោយ ស.ជ.ណ របស់ក្រសួងបរិស្ថានរួចរាល់ និងត្រឹមត្រូវ ប៉ុន្តែម្ចាស់គម្រោងពុំទាន់បានធ្វើសកម្មភាពអភិវឌ្ឍន៍គម្រោងនៅឡើយទេ
    - តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតនៅភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល ជាលទ្ធផល ពិនិត្យឃើញថា បន្ទាប់ពីទទួលបានគោលការណ៍ អនុញ្ញាត (ស.ជ.ណ) ពីក្រសួងបរិស្ថាន ម្ចាស់គម្រោងបានសហការជាមួយមន្ទីរបរិស្ថានខេត្ត និងអាជ្ញាធរពាក់ព័ន្ធបោះបង្គោលព្រំទីតាំងគម្រោងតាមរយៈនិយាមកា (UTM) ដែលបានកំណត់ក្នុង ស.ជ.ណ របស់ក្រសួងបរិស្ថានរួចរាល់ និងត្រឹមត្រូវ។ ក្រុមការងារក៏បានពិនិត្យឃើញមានផ្នូរបញ្ចុះសពចំនួន២(ពីរ) ស្ថិតនៅទីតាំងផ្សេងគ្នាក្នុងទីតាំងគម្រោងផងដែរ ដែលជាផ្នូរបញ្ចុះសពសាច់ញាតិ របស់ប្រជាពលរដ្ឋមូលដ្ឋាន។ ក្រៅពីនេះទៀតម្ចាស់គម្រោងពុំទាន់បានធ្វើសកម្មភាព អភិវឌ្ឍន៍គម្រោងនៅឡើយ។

### ១.២.៤-ការងារសេវាសង្គម

- បានរៀបចំកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខេត្ត មានចំនួន១លើក
- ថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើកិច្ចប្រជុំប្រចាំខែឧសភា ចំនួន៣៥៧.០០០រៀល។

### ១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប

តារាងទី១៥៖លទ្ធផលសម្រេចបាន

| ល.រ | ឈ្មោះលទ្ធផល | ស្ថានភាព | % សម្រេច | % ចំណាយ |
|---|---|---|---|---|
| ១ | ការពង្រឹងយន្តការដឹកនាំកំណែទម្រង់ ដើម្បីបន្តជំរុញកំណែទម្រង់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការវិវឌ្ឍទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន | កំពុងអនុវត្ត | ៤០% | ៤០% |
| ២ | ការផ្សព្វផ្សាយចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា | កំពុងអនុវត្ត | ១០% | ១០% |
| ៣ | ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | កំពុងអនុវត្ត | ៣០% | ៣០% |
| ៤ | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាល ក្រុង/ស្រុក ឃុំ/សង្កាត់ | កំពុងអនុវត្ត | ៣០% | ៣០% |
| ៥ | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | កំពុងអនុវត្ត | ៤០% | ៤០% |
| ៦ | ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៤០% | ៤០% |
| ៧ | ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល | កំពុងអនុវត្ត | ៤០% | ៤០% |
| ៨ | ការរៀបចំ និងដាក់ឱ្យអនុវត្ត ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៤០% | ៤០% |
| ៩ | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៥០% | ៥០% |
| ១០ | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ពុំទាន់អនុវត្ត | ០០% | ០០% |
| ១១ | ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែន ការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹងនិងកំណត់យ៉ាងច្បាស់លាស់ | កំពុងអនុវត្ត | ៥០% | ៥០% |
| ១២ | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៥០% | ៥០% |
| ១៣ | ការពិនិត្យ កែលម្អ និងពង្រឹង ការអនុវត្តយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | កំពុងអនុវត្ត | ៤៥% | ៤៥% |
| ១៤ | ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន | កំពុងអនុវត្ត | ៤៥% | ៤៥% |

| | | | | |
|---|---|---|---|---|
| ១៥ | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | កំពុងអនុវត្ត | ២៨% | ២៨% |

### ១.២.៦-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា

- **ការអនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជា ខេត្តកោះកុង**

– បានតាមដាន និងត្រួតពិនិត្យ ព្រមទាំងគាំទ្របច្ចេកទេសដល់ក្រុមទ្រទ្រង់សុខភាពភូមិរបស់ឃុំ/សង្កាត់ទាំង២៩ អំពីរបៀបធ្វើបច្ចុប្បន្នភាពផែនទីសង្គម ការធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមគោលដៅ១.០០០ថ្ងៃដំបូងនៃជីវិត

– បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះក្រុមទ្រទ្រង់សុខភាពភូមិ និងផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប

– បានចុះផ្តល់ការហ្វឹកហ្វឺនតម្រង់ទិសដល់ក្រុមការងារស្រុកគិរីសាគរ ស្រុកថ្មបាំង និងស្រុកបូទុមសាគរ អំពីរបៀបរៀបចំ និងអនុវត្តផែនការហ្វឹកហ្វឺន ប្រចាំឆមាសទី១ ឆ្នាំ២០២៤

– បានសហការជាមួយក្រុមការងារស្រុកថ្មបាំង និងស្រុកកោះកុង ចុះពិនិត្យក្រុមទ្រទ្រង់សុខភាពភូមិអនុវត្តជាក់ស្តែង និងផ្តល់ការហ្វឹកហ្វឺន អំពីការផ្តល់ប្រឹក្សាសុខភាពស្ត្រី កុមារ និងអាហារូបត្ថម្ភតាមខ្នងផ្ទះ។

## ១.៣-ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១-ការងារគ្រប់គ្រងបុគ្គលិក

– បានរៀបចំបេសកកម្មជូនក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីសាលាខេត្ត និងមន្ទីរ អង្គភាពជុំវិញខេត្ត ក្នុងខែឧសភា ឆ្នាំ២០២៤ សរុបចំនួន១៥៧លេខ

– បានរៀបចំដីកាលេខ០១៣/២៤ ដក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីកាដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ចំនួន២រូប នៃមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត

– បានរៀបចំដីកាលេខ០១៥/២៤ ដក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិដល់មន្ត្រីរាជការនៃរដ្ឋបាលខេត្ត ចំនួន៤២រូប

– បានរៀបចំដីកាលេខ០១៦/២៤ ដក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ (ករណីមុនកាលកំណត់) ចំនួន១រូប មន្ត្រីរាជការមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត

– បានរៀបចំដីកាលេខ០១៧,០១៨,០១៩,០២០ និង០២២/២៤ ដក ចុះថ្ងៃ២០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន៥រូប

– បានរៀបចំដីកាលេខ០២១/២៤ ដក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិដល់មន្ត្រីរាជការមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត ចំនួន១១៦រូប

តារាងទី១៦៖ស្ថិតិក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា (ចំនួនក្រុមប្រឹក្សាដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត) | ១៩ | ២ |
| ២ | ប្រធានក្រុមប្រឹក្សា | ១ | ០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០ | ០ |
| ៤ | អភិបាល | ១ | ១ |
| ៥ | អភិបាលរង | ១០ | ២ |
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ៤ | ១ |

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ៨ | នាយកទីចាត់ការ/ប្រធានអង្គភាព | ៧ | ០ |
| ៩ | ប្រធានមន្ទីរ ឬអង្គភាព( ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ) | ១ | ០ |
| ១០ | នាយករងទីចាត់ការ/អនុប្រធានអង្គភាព | ១៤ | ៤ |
| ១១ | អនុប្រធានមន្ទីរ ឬអង្គភាព( ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ) | ៣ | ១ |
| ១២ | ប្រធានការិយាល័យ | ១៥ | ៣ |
| ១៣ | អនុប្រធានការិយាល័យ | ១៣ | ៦ |
| ១៤ | មន្ត្រីការិយាល័យ | ១៣ | ៦ |
| ១៥ | បុគ្គលិកកិច្ចសន្យា | ៣៩ | ២៣ |

- **ស្ថិតិការិយាល័យប្រជាពលរដ្ឋខេត្ត**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ០ |
| ២ | អនុប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ១ |
| ៣ | ប្រធានផ្នែក | ២ | ០ |
| ៤ | អនុប្រធានផ្នែក | ៤ | ០ |
| ៥ | មន្ត្រី | ០ | ០ |

- **ស្ថិតិបុគ្គលិកមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**

| ល.រ | បរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានមជ្ឈមណ្ឌល | ១ | ០ |
| ២ | មន្ត្រីជាប់កិច្ចសន្យា | ១ | ១ |

### ១.៣.២-ការងារកសាងសមត្ថភាព

- បានសម្របសម្រួលជូនសាស្ត្រាចារ្យចិត្តវិទ្យាចំនួន៤នាក់ និងនិស្សិតចំនួន៥នាក់ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចុះប្រមូលព័ត៌មានត្រឡប់ ស្តីពី «ការអនុវត្តឧបករណ៍គាំទ្រសុខភាពផ្លូវចិត្តមនុស្សចាស់» នៅស្រុកស្រែអំបិល និងស្រុកគិរីសាគរ ខេត្តកោះកុង ចាប់ពីថ្ងៃទី២៧ ខែឧសភា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤
- បានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ដល់មន្ត្រីបង្គោលថ្នាក់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធនៃខេត្តកោះកុង ដល់រដ្ឋបាលស្រុកបូទុមសាគរ ស្រុកកោះកុង ស្រុកថ្មបាំង ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា និងស្រុកគិរីសាគរ ដែលមានសមាសភាពចូលរួមសរុប១៦៥នាក់ ស្រី២៦នាក់
- បានសម្របសម្រួលដល់និស្សិតថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក ជំនាន់ទី១៥ ឆ្នាំទី៤ ក្រុមBN42 ចំនួន២រូបជាស្ត្រី មកពីសាកលវិទ្យាល័យអន្តរជាតិ ចុះកម្មសិក្សានៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីដំណើរការនៃការរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាល ថ្នាក់ក្រោមជាតិក្រោម ប្រធានបទ«កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ដែលមានអ្នកចូលរួមសរុប១១០នាក់ ស្រី២០នាក់
- បានជូនដំណឹងដល់រដ្ឋបាលក្រុងខេមរភូមិន្ទ រដ្ឋបាលស្រុកស្រែអំបិល រដ្ឋបាលស្រុកមណ្ឌលសីមា និងរដ្ឋបាលស្រុកថ្មបាំង ស្តីពីការចាត់បញ្ជូនក្រុមគោលដៅជាអភិបាលក្រុង ស្រុក ចូលរួមវគ្គគ្រប់គ្រងកម្រិត១ ឆ្នាំ២០២៤ ដែលរៀបចំឡើងដោយសាលាជាតិរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ

- បានសម្របសម្រួលបញ្ជូនក្រុមគោលដៅជាអភិបាលរងក្រុងស្រុកចំនួន៤រូបជាបុរស ទៅចូលរួមវគ្គគ្រប់គ្រងកម្រិត១ ឆ្នាំ២០២៤ ដែលរៀបចំឡើងដោយសាលាជាតិរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ
- បានផ្សព្វផ្សាយកម្មវិធី«ប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍-២» ដល់មន្ទីរសុខាភិបាលនៃ រដ្ឋបាលខេត្ត
- បានផ្សព្វផ្សាយស្តីពីការចូលរួមបណ្តុះបណ្តាលសម្រាប់ការគ្រប់គ្រងជាន់ខ្ពស់ផ្នែកឱសថបុរាណចិន ឆ្នាំ២០២៤ នៅសាធារណរដ្ឋប្រជាមានិតចិន ដល់មន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត។

តារាងទី១៧៖ការកសាងសមត្ថភាព

| ល.រ | ឈ្មោះវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| ១ | វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគនលោយ្យភាពសង្គម ដល់មន្ត្រីបង្គោលថ្នាក់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធ នៃខេត្តកោះកុង | ២ថ្ងៃ | ១៦៥ | ២៦ | ទីចាត់ការគ្រប់គ្រងធនធានមនុស្ស |
| ២ | វគ្គបណ្តុះបណ្តាល ស្តីពីដំណើរការនៃការរៀបចំវេទិកាវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិក្រោម ប្រធានបទ«កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបាន ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ | ១ថ្ងៃ | ១១០ | ២០ | ក្រុមការងារបច្ចេកទេសគាំទ្រដល់ការរៀបចំវេទិកាស្តីពី«កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០» |
| សរុប | | ៣ថ្ងៃ | ២៧៥ | ៤៦ | |

## ១.៤-ការងារអន្តរវិស័យ

### ១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច

- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់អង្គការជីវិត និងធម្មជាតិនៅកម្ពុជា ស្នើសុំចុះសម្ភាសជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ តំបន់រាមសារកោះកាពិ ស្ថិតនៅឃុំកោះកាពិ ស្រុកកោះកុង
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ក្រសួងផែនការ ស្នើសុំកិច្ចសម្របសម្រួលឱ្យមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ចុះស្រង់ទិន្នន័យនៃការអង្កេតស្តីពីនវានុវត្តន៍ ឆ្នាំ២០២៤
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាបអំពីសំណើរបស់មន្ទីររ៉ែ និងថាមពលខេត្ត ស្នើសុំកែសម្រួលសមាសភាពក្រុមការងារចុះត្រួតពិនិត្យ ទប់ស្កាត់ និងវាយតម្លៃលក្ខណៈ បច្ចេកទេសសុវត្ថិភាពក្នុងការគ្រប់គ្រងស្ថានីយប្រេងឥន្ធនៈ ក្នុងខេត្តកោះកុង។

- **មជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**
  - **សកម្មភាព និងលទ្ធផលការងារ**
    - ពុំមាន
  - **ការចូលរួមពីមន្ទីរ អង្គភាពជុំវិញខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា**
    - លោក សំ វីរៈ និងក្រុមគ្រួសារ បានជួយឧបត្ថម្ភអង្ករចំនួន៥០គីឡូក្រាម ជូនដល់មជ្ឈមណ្ឌល
    - លោកជំទាវ ចេង វន្នី បានជួយឧបត្ថម្ភអង្ករចំនួន៥០គីឡូក្រាម ជូនដល់មជ្ឈមណ្ឌល

### ១.៤.២-ការងារគ្រប់គ្រងការអនិវឌ្ឍ និងសំណង់

- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ឈ្មោះ យិន សំអាត ស្នើសុំចុះបញ្ជីដីទំហំ ២៥២ម² ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ក្រសួងការពារជាតិ ស្នើសុំថ្នាក់ដឹកនាំរដ្ឋបាលខេត្ត និងមន្ត្រីជំនាញ សហការជាមួយក្រុមការងារកំណត់ព្រំដីតំបន់អភិវឌ្ឍន៍ ចុះពិនិត្យផ្ទៀងផ្ទាត់ទីតាំងតំបន់ប្រវត្តិសាស្ត្រយោធា ស្ថិតក្នុងភូមិសាស្ត្រស្រុកកោះកុង
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់ប្រជាពលរដ្ឋ ស្នើសុំបង្រួមផ្លូវ១ខ្សែ ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្នើសុំដី១កន្លែង សម្រាប់សាងសង់មត្តេយ្យសហគមន៍ ស្ថិតនៅក្នុងភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសំណើរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ស្នើប្តឹងទាស់ការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន៩ក្បាលដី ស្ថិតនៅបណ្តោយផ្លូវជាតិលេខ៤៨ ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។

### ១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ

- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីរបាយការណ៍បូកសរុបលទ្ធផលជំរឿនសមាគម និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក នៅបណ្តាក្រុង ស្រុកទូទាំងខេត្ត
- បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំជ្រាប អំពីសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ស្តីពីការអនុញ្ញាតឱ្យគណៈមេធាវី សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ភូមិ និងមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ដើម្បីរៀបចំការផ្សព្វផ្សាយច្បាប់ជាមូលដ្ឋានក្នុងវិស័យរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ផ្សព្វផ្សាយមេធាវី និងសេវាការពារកូនក្តីជូនជនក្រីក្រដោយមិនយកកម្រៃតាមរយៈគម្រោងមេធាវីដល់មូលដ្ឋាន ស្ថិតនៅក្នុងខេត្តកោះកុង។

តារាងទី១៨៖ការដោះស្រាយវិវាទ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| | | 0 | 0 | 0 |
| | | 0 | 0 | 0 |

### ១.៤.៤-ការងារគ្រប់គ្រងកាកសំណល់

- ពុំមាន។

## ១.៥-ការងារអន្តរភាពច្រកចេញចូលតែមួយ

- បានសហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អាជ្ញាធរក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា ចុះផ្តល់សេវាផ្នែកជលយានជូនប្រជានេសាទ បានចំនួន១៩៨សេវា ក្នុងនោះក្រុងខេមរភូមិន្ទចំនួន៦០សេវា និងស្រុកមណ្ឌលសីមាចំនួន១៣៨សេវា
- បានពង្រឹងការអនុវត្តការងាររបស់មន្ត្រីជួរមុខ និងជួរក្រោយ យកចិត្តទុកដាក់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរតាមនីតិវិធី

– បានផ្តល់សេវាជូនប្រជាពលរដ្ឋ មានដូចតារាងខាងក្រោម៖

**តារាងទី១៩៖ស្ថានភាពចំនួនសេវា និងចំណូល**

| ល.រ | ឈ្មោះវិស័យ | ចំនួនសេវា/នាក់ | | ចំនួនថវិកា | ផ្សេងៗ |
|---|---|---|---|---|---|
| | | នាក់ | ស្ត្រី | | |
| ១ | នីត្យានុកូលកម្ម(ថតចម្លង) | ៥ | ០ | ៥៨.០០០ | |
| ២ | ការងាររដ្ឋបាល | ៤៩៤ | ២៩០ | ៩.៨៦០.០០០ | |
| | -សេវាប័ណ្ណព្រំដែន(រដ្ឋបាលខេត្ត) | ៣៧៨ | ២២១ | ៧.៥៤០.០០០ | |
| | -សេវាប័ណ្ណព្រំដែន (ក្រុង ស្រុក) | ១១៦ | ៦៩ | ២.៣២០.០០០ | |
| | -សេវាតម្លើងទីតាំងផ្ទាំងប៉ាណូអចល័ត | ០ | ០ | ០ | |
| ៣ | សុខាភិបាល | ១ | ០ | ៦០០.០០០ | |
| ៤ | ទេសចរណ៍ | ៣ | ២ | ១.០៥០.០០០ | |
| ៥ | សាធារណការ និងដឹកជញ្ជូន | ៣២០ | ៤៣ | ២៤.៤៥១.០០០ | |
| | -សេវាដឹកជញ្ជូនតាមផ្លូវគោក | ៣៦ | ៥ | ៣.៣៥១.០០០ | (បង់សេវាតាមវីង) |
| | -សេវាដឹកជញ្ជូនតាមផ្លូវទឹក | ២៨៤ | ៣៨ | ២១.១០០.០០០ | |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ០ | ០ | ០ | |
| ៧ | ព័ត៌មាន | ០ | ០ | ០ | |
| ៨ | បរិស្ថាន | ០ | ០ | ០ | |
| ៩ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ២ | ០ | ២០០.០០០ | |
| ១០ | រ៉ែ និងថាមពល | ១២ | ៩ | ១.០០០.០០០ | |
| ១១ | ពាណិជ្ជកម្ម | ០ | ០ | ០ | |
| ១២ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ក)+(ខ) | ១៦៥ | ៣៧ | ៣៩.៣៤៤.៨៥០ | |
| | (ក) សំណង់ | ១ | ០ | ៥.៣៥៨.០០០ | |
| | (ខ) សុរិយោដី | ១៦៤ | ៣៧ | ៣៣.៩៨៦.៨៥០ | |
| ១៣ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៥៨ | ២៨ | ១.៨០៣.៣០០ | |
| ១៤ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០ | ០ | ០ | |
| **សរុបរួម** | | **១.០៦០** | **៤០៩** | **៧៨.៣៦៧.១៥០** | |

## ១.៦-ការងារការិយាល័យប្រជាពលរដ្ឋ

– បានទទួលព័ត៌មានផ្សេងៗ (អនាមិក) ក្នុងសមត្ថកិច្ច តាមរយៈប្រអប់សំបុត្រលេខ០៣៣ មានទីតាំងនៅខាងមុខអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត ចំនួន២៣សន្លឹក ក្នុងនោះ ជាការសរសើរ ចំនួន១៨សន្លឹក និងជាការសំណូមពរ ចំនួន៥សន្លឹក

– បានទទួលព័ត៌មានផ្សេងៗ (អនាមិក) ក្រៅសមត្ថកិច្ច តាមរយៈប្រអប់សំបុត្រលេខ០០៥ មានទីតាំងនៅខាងមុខសាលាឃុំបឹងព្រាវ ស្រុកស្រែអំបិល ចំនួន១សន្លឹក ជាការសំណូមពរ។

តារាងទី២០៖ការដោះស្រាយបណ្តឹង

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | បណ្តឹងដែលទទួលបាន(ក្នុង និងក្រៅសមត្ថកិច្ច) | ១៥ | ០ | ១៥ |
| ១.១ | បណ្តឹងស្ថិតក្នុងសមត្ថកិច្ច | ៧ | ០ | ៧ |
| | - បញ្ចប់ការដោះស្រាយ | ៦ | ០ | ៦ |
| | - កំពុងដោះស្រាយ (នៅសល់) | ០ | ០ | ០ |
| ១.២ | បណ្តឹងក្រៅសមត្ថកិច្ច | ៨ | ០ | ៨ |
| ២ | ព័ត៌មានផ្សេងៗ | ១០០ | ២៤ | ១២៤ |
| **សរុបរួម(១+២)** | | **១១៥** | **២៤** | **១៣៩** |

## ១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- ពុំមាន។

## ១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

### ១.៨.១-ច្រកទ្វារព្រំដែនដែលកំពុងដំណើរការ

- មានច្រកទ្វារព្រំដែនអន្តរជាតិចំនួន១កំពុងដំណើរការ គឺទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម។

### ១.៨.២-សន្តិសុខ និងសណ្តាប់ធ្នាប់តាមព្រំដែន

- បញ្ហាសន្តិសុខ៖ (ពុំមានអ្វីកើតឡើងគួរឱ្យកត់សម្គាល់)។
- សណ្តាប់ធ្នាប់៖ បានរៀបចំសណ្តាប់ធ្នាប់ និងសម្អាតអនាម័យបរិស្ថាននៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាមជាប្រចាំ។

### ១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ)

- អំពីមនុស្ស៖
    - ពលរដ្ឋខ្មែរចូល៖ ចំនួន៧.១៧២នាក់ ស្រី៣.៩៨៥នាក់
    - ជនបរទេសចូល៖ ចំនួន៥.១៩៧នាក់ ស្រី១.៤២៣នាក់ មាន៤៤សញ្ជាតិ
    - ពលរដ្ឋខ្មែរចេញ៖ ចំនួន៨.៤០៩នាក់ ស្រី៤.២៤៤នាក់
    - ជនបរទេសចេញ៖ ចំនួន៤.៩៩៩នាក់ ស្រី១.៥០០នាក់ មាន៥៤សញ្ជាតិ។
- អំពីមធ្យោបាយ៖
    - រថយន្តចូល៖ ចំនួន២.៣៩៥គ្រឿង
    - ទោចក្រយានយន្តចូល៖ ចំនួន២៤គ្រឿង
    - រថយន្តចេញ៖ ចំនួន២.២៦៣គ្រឿង
    - ទោចក្រយានយន្តចេញ៖ ចំនួន៣០គ្រឿង។

### ១.៨.៤-ការផ្លាស់ប្តូរទំនិញ

- ទំនិញនាំចូល ៖ កូនឈើ កូនផ្កា ផ្លែឈើចម្រុះ ត្រី សាច់ បន្លែ គេសជ្ជៈ ជ័រប្លាស្ទីក ម៉ូតូ គ្រឿងអេឡិចត្រូនិច និងគ្រឿងសំណង់ ។ល។
- ទំនិញនាំចេញ ៖ ផលនេសាទ។

១.៨.៥-កិច្ចសហប្រតិបត្តិការ

- សហការទំនាក់ទំនងល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាការណែនាំរបស់អាជ្ញាធរខេត្ត។ មន្ត្រីជំនាញប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានផ្តល់សេវាងាយស្រួលដល់ភ្ញៀវជាតិ និងអន្តរជាតិ ទាំងធ្វើដំណើរចូល និងធ្វើដំណើរចេញបានល្អប្រសើរ
- បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដោយឈរលើគោលជំហរគោរពបូរណភាពទឹកដី នៃប្រទេសទាំងពីរក្នុងតំបន់ព្រំដែន
- បានសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋប្រកបរបរស្របច្បាប់ប្រចាំថ្ងៃតាមព្រំដែន។

## ១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ

### ១.៩.១-ការងារហិរញ្ញវត្ថុ

- ការអនុវត្តចំណូល និងចំណាយរបស់រដ្ឋបាលខេត្តប្រចាំខែឧសភា ឆ្នាំ២០២៤ ទីចាត់ការហិរញ្ញវត្ថុ សម្រេចបានការងារប្រមូលចំណូល និងចំណាយដែលមានទឹកប្រាក់ ដូចខាងក្រោម

តារាងទី២១៖ការអនុវត្តចំណូល និងចំណាយ

| ជំពូក | ចំណាត់ថ្នាក់ | ច្បាប់ដើមឆ្នាំ | ច្បាប់កែតម្រូវ | អនុវត្ត | ភាគរយ |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=3/2 |
| <u>ផ្នែកចំណូល</u> | | | | | |
| 70 | ចំណូលសារពើពន្ធ | ៨.៩៩៣.០០០.០០០ | ៨.៩៩៣.០០០.០០០ | - | 0% |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | ៣៣៨.៦០០.០០០ | ៣៣៨.៦០០.០០០ | ២០០.៤០៥.៦៦៨ | ៥៩% |
| 73 | ផលទុនលើការលក់-ជួលទ្រព្យ | ១.៩៧៧.៤០០.០០០ | ១.៩៧៧.៤០០.០០០ | ៤២.១៧០.៩២៩ | ២,១៣% |
| 74 | ផលពីការពិន័យ និងការដាក់ | ៥០.០០០.០០០ | ៥០.០០០.០០០ | - | 0% |
| 75 | ការឧត្ថម្ភធន(អំណោយ) | ១៣.៥០០.០០០.០០០ | ១៣.៥០០.០០០.០០០ | ៨៥០.០០០.០០០ | ៦,៣០% |
| 76 | ផលហិរញ្ញវត្ថុ | - | - | - | - |
| 77 | ផលផ្សេងៗ និងផលពិសេស | - | - | - | - |
| **សរុបរួមចំណូល** | | **<u>២៤.៨៥៩.០០០.០០០</u>** | **<u>២៤.៨៥៩.០០០.០០០</u>** | **<u>១.០៩២.៥៧៦.៥៩៧</u>** | **<u>៤,៤០%</u>** |
| <u>ផ្នែកចំណាយ</u> | | | | | |
| 60 | ការទិញ | ១.៦៨៨.០០០.០០០ | ១.៦៨៨.០០០.០០០ | ៨៩.១៩៦.៦០០ | ៥,២៨% |
| 61 | សេវាកម្ម | ១៤.៣៦៩.២០០.០០០ | ១៦.៣៦៩.២០០.០០០ | ៦៦.១៨៨.៣០០ | 0,៤0% |
| 62 | អត្ថប្រយោជន៍សង្គម | ៦១០.០០០.០០០ | ៦១០.០០០.០០០ | ២.១០០.០០០ | 0,៣៤% |
| 63 | ពន្ធ និងអាករ | ៨០០.០០០ | ៨០០.០០០ | - | 0% |
| 64 | បន្ទុកបុគ្គលិក | ៣.៨៤៦.០០០.០០០ | ៣.៨៤៦.០០០.០០០ | ៥១៦.៩៦៥.៣០០ | ១៣,៤៤% |
| 65 | ឧបត្ថម្ភធននិងជំនួយសង្គម | ២០២.០០០.០០០ | ៩៦៩.០០០.០០០ | - | 0% |
| 66 | បន្ទុកហិរញ្ញវត្ថុ | - | - | - | - |
| 67 | បន្ទុកពិសេស | - | - | - | - |
| 68 | ទាយជ្ជទានឱ្យដល់រំលស់អចលនកម្ម | - | - | - | - |
| 69 | ចំណាយមិនបានគ្រោងទុក | ៧៤៣.០០០.០០០ | ៧៤៣.០០០.០០០ | - | 0% |
| 20 | អចលកម្មអរូបី | - | - | - | - |
| 21 | អចលកម្មរូបី | ១.៧៤០.០០០.០០០ | ១.៧៤០.០០០.០០០ | - | 0% |
| 23 | អចលកម្មកំពុងដំណើរការ | - | - | - | - |
| **សរុបចំណាយ** | | **<u>២៣.១៩៩.០០០.០០០</u>** | **<u>២៥.៩៦៦.០០០.០០០</u>** | **<u>៦៧៤.៤៥០.២០០</u>** | **<u>២,៦0%</u>** |

### ១.៩.២-ការងារគណនេយ្យ

- បានរៀបចំអាណត្តិបើកបៀវត្សប្រចាំខែឧសភា ឆ្នាំ២០២៤ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ព្រមទាំងមន្ត្រីជាប់កិច្ចសន្យារួចរាល់
- បានរៀបចំឯកសារទូទាត់ប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

### ១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ

តារាងទី២២៖ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ. | ការបរិយាយ | ឯកតា | ចំនួន | | | ស្ថានភាព |
|---|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | បូកយោង | |
| ១-អចលនទ្រព្យ | | | | | | |
| ១ | ដី ស្ថិតនៅភូមិ១ ស្នាច់មានជ័យ | ម២ | ១៩.០៤៧ | ០ | ១៩.០៤៧ | |
| | អគារ | ខ្នង | ៣ | ០ | ៣ | |
| ២ | ដី ស្ថិតនៅភូមិ១ ស្នាច់មានជ័យ | ម២ | ១១.៤០៣ | ០ | ១១.៤០៣ | |
| | អគារ | ខ្នង | ១ | ០ | ១ | |
| ៣ | ដី ភូមិ១ ស្នាច់មានជ័យ | ម២ | ៤.៩៣៩ | ០ | ៤.៩៣៩ | |
| | អគារ | ខ្នង | ១ | ០ | ១ | |
| ៤ | ដី ភូមិ៣ ស្នាច់មានជ័យ | ម២ | ៤.១១៧ | ០ | ៤.១១៧ | |
| | អគារ | ខ្នង | ២ | ០ | ២ | |
| ៥ | ដី ស្ថិតនៅភូមិ១ ស្នាច់មានជ័យ | ម២ | ៩.៨០១ | ០ | ៩.៨០១ | |
| | អគារ | ខ្នង | ៣ | ០ | ៣ | |
| ២-ឧបករណ៍ សម្ភារ និងបរិក្ខារ(យានយន្ត ម៉ាស៊ីន តុ ...) | | | | | | |
| ១ | ម៉ាស៊ីនភ្លើង | គ្រឿង | ៣ | ០ | ៣ | |
| ២ | ទូបញ្ជាម៉ាស៊ីនភ្លើង | គ្រឿង | ១ | ០ | ១ | |

### ១.១០-ការងារលទ្ធកម្ម

- បានប្រជុំរៀបចំសំណើសុំគោលការណ៍ចរចាថ្លៃទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុវត្តការងារជួសជុលផ្លូវដោយចាក់កៅស៊ូ AC ចំនួន១ខ្សែ ប្រវែង១.៧៨៦ម ទទឹង៧ម កម្រាស់៧០ម.ម ទំហំសរុប១២.៥០២ម$^{២}$នៅលើកំណាត់ផ្លូវសេរីកា ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ។

### ១.១១-ការងារសុខាភិបាល

- បានពិនិត្យ និងពិគ្រោះជំងឺក្រៅសរុបចំនួន៦.១៣៦ករណី (ករណីថ្មីចំនួន៥.៦០៨ករណី) ជូនប្រជាជន ដូចខាងក្រោម ៖
    - បង់លុយដោយខ្លួនឯងមានចំនួន៣.៩២៣ករណី
    - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន១.០៩៦ករណី
    - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន៣៣០ករណី
    - ករណីលើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន៧៨៧ករណី
- ករណីអ្នកជំងឺសម្រាកពេទ្យសរុបចំនួន៤៨៥នាក់ រួមមាន ៖
    - បង់លុយដោយខ្លួនឯងមានចំនួន២១៤ករណី

- គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ២៣៣ករណី
- គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ២៨ករណី
- លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន១០ករណី

- ការសម្រាលកូនសរុបចំនួន២០៤នាក់ (សម្រាលនៅមណ្ឌលសុខភាពចំនួន៨២នាក់) មានដូចខាងក្រោម ៖
  - បង់លុយដោយខ្លួនឯងមានចំនួន៨៨នាក់
  - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ៦០នាក់
  - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ៥៣នាក់
  - លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន៣នាក់
- ផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះសរុបចំនួន២៧៧ដូស
- ស្ត្រីបានមកពិនិត្យផ្ទៃពោះមុនសម្រាលកូនសរុបចំនួន១.១៦៨លើក
- ស្ត្រីបានមកពិនិត្យផ្ទៃពោះក្រោយសម្រាលកូនចំនួន២៨៤លើក
- កុមារបានចាក់ថ្នាំបង្ការ១១មុខគ្រប់ចំនួន២៤៤នាក់
- ស្ត្រីពន្យារកំណើតបន្តសរុបចំនួន២.៥០៨នាក់
- ក្រុមការងារចត្តាឡីស័កប្រចាំការនៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាមបានអនុវត្តការងារ គិតចាប់ពី(ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤) ដូចខាងក្រោម៖
  - បានពិនិត្យកម្តៅលើអ្នកបើកបររថយន្តដឹកទំនិញចូលខេត្តកោះកុងសរុបចំនួន១.៥៣៥នាក់ ស្រី៣៤នាក់
  - បានបាញ់ថ្នាំសម្លាប់មេរោគលើរថយន្តដឹកទំនិញចូលខេត្តកោះកុង សរុបចំនួន១.៥៣៥គ្រឿង
  - បានបាញ់ថ្នាំសម្លាប់មេរោគលើរថយន្តទេសចរណ៍ចូលខេត្តកោះកុង សរុបចំនួន៨៧២គ្រឿង
  - បានពិនិត្យកម្តៅអ្នកធ្វើដំណើរចេញពីខេត្តកោះកុង សរុបចំនួន១៣.៤៦១នាក់ ស្រី៥.៧១១នាក់
  - បានពិនិត្យកម្តៅអ្នកធ្វើដំណើរចូលខេត្តកោះកុង សរុបចំនួន១២.៣២៤នាក់ ស្រី៥.៣៣៤នាក់
  - បានពិនិត្យកម្តៅពលករខ្មែរចូលខេត្តកោះកុង សរុបចំនួន២២នាក់ ស្រី៥នាក់
  - បានពិនិត្យកម្តៅកុមារមកជាមួយពលករខ្មែរចូលខេត្តកោះកុងចំនួន១នាក់ស្រី
  - បានពិនិត្យសពដឹកចូលខេត្តកោះកុងចំនួន១នាក់
  - បានពិនិត្យអ្នកជំងឺចូលខេត្តកោះកុង សរុបចំនួន២នាក់ស្រី
  - បានពិនិត្យអ្នកជំងឺចេញខេត្តកោះកុង សរុបចំនួន៣នាក់ ស្រី១នាក់។

## ១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល

- បានអញ្ជើញអមដំណើរសម្តេចពិជ័យសេនា **ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធមហាដួង និងសមិទ្ធផលនានា នៅវត្តគិរីតេជោ (ហៅវត្តកូនកុក) ស្ថិតក្នុងភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង
- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដើម្បីពិភាក្សាលើគម្រោងសាងសង់លូជ្រុងភ្លោះ និងលូមូលកាត់ផ្លូវមុខបី ស្ថិតនៅភូមិតានី និងភូមិកៀនក្រឡាញ់ ឃុំភ្ញីមាស ស្រុកគិរីសាគរ ខេត្តកោះកុង និងយន្តការគ្រប់គ្រងចំណូល នៃការសាងសង់សមិទ្ធផលនានា នៅវត្តគិរីតេជោ (ហៅវត្តកូនកុក)។

## ១.១៣-ការងារផ្សេងៗ

- (ពុំមាន)។

# ផ្នែកទី២៖សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ

## ២.១-ផ្នែកសេដ្ឋកិច្ច

### ២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក. ការងារកសិកម្ម**

- ចលនាដឹកនាំសត្វ និងផលិតផលមានដើមកំណើតពីសត្វចំនួន២.៦៤៥ក្បាល និង២១៥គ.ក្រ ក្នុងនោះ៖
  - ជ្រូកសាច់នាំចូល ចំនួន៥៤៥ក្បាល
  - មាន់រស់នាំចូល ចំនួន២.១០០ក្បាល
  - ប្រហិតនាំចូល ចំនួន១១០គ.ក្រ
  - សាច់គ្រួចនាំចូល ចំនួន១០៥គ.ក្រ
- ចាក់ថ្នាំការពារសត្វសរុបបានចំនួន១.៧៩៧ក្បាល ក្នុងនោះ៖
  - គោ ចំនួន ៩ក្បាល (សាទឹក)
  - ក្របី ចំនួន ១៣ក្បាល (សាទឹក)
  - ជ្រូក ចំនួន ១៧៥ក្បាល (ជំងឺ ៣មុខ)
  - ឆ្កែ ចំនួន ១៨ក្បាល (ជំងឺ ៦មុខ)
  - ឆ្មា ចំនួន ១០ក្បាល (ជំងឺ ៤មុខ)
  - សត្វស្លាប ចំនួន ១.៥៧២ក្បាល (ជំងឺ ៣មុខ)
- ព្យាបាលសត្វសរុបបានចំនួន ៣៧៧ក្បាល ក្នុងនោះ៖
  - គោ ចំនួន ៤៩ក្បាល
  - ក្របី ចំនួន ២៣ក្បាល
  - ជ្រូក ចំនួន ២៦ក្បាល
  - ឆ្កែ ចំនួន ២៤ក្បាល
  - សត្វស្លាប ចំនួន ២៥៥ក្បាល
- សត្វងាប់ដោយជំងឺសរុបមានចំនួន ១៩៨ក្បាល ក្នុងនោះ៖
  - ជ្រូក ចំនួន ៤ក្បាល
  - ឆ្កែ ចំនួន ៧ក្បាល
  - សត្វស្លាប ចំនួន ១៨៧ក្បាល
- ស្ថិតិពិឃាដសត្វសរុបមានចំនួន ៤.១៥១ក្បាល ក្នុងនោះ៖
  - គោ ចំនួន ១១៨ក្បាល
  - ក្របី ចំនួន ៤៣ក្បាល
  - ជ្រូក ចំនួន ៨៨៤ក្បាល
  - មាន់ ចំនួន ២.៨១០ក្បាល
  - ទា ចំនួន ២៩៦ក្បាល
- ការងារភ្ជួររាស់អនុវត្តបានសរុបចំនួន ១.០០០ហ.ត(គ្រឿងចក្រ)
- ដំណាំស្រូវអនុវត្តបានសរុបចំនួន ៩៤៣ហ.ត(ស្រូវកណ្ដាល ៩១៣ហ.ត, ស្រូវចម្ការ ៣០ហ.ត)
- ដំណាំបន្លែអនុវត្តបានសរុបចំនួន ១៤ហ.ត
- ដំណាំឈើហូបផ្លែអនុវត្តបានសរុបចំនួន ៩ហ.ត
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥ហ.ត
- បរិមាណកសិផលនាំចេញ និងប្រើប្រាស់ក្នុងខេត្តសរុបបានចំនួន៤៨៤តោន និងផ្លែដូងចំនួន១.៧០០ផ្លែ

- ចុះត្រួតពិនិត្យតាមដាន និងផ្តល់បច្ចេកទេសដាំដុះដំណាំបន្លែ ចំនួន៤លើក បានចំនួន២៣គ្រួសារ នៅស្រុកថ្មបាំង និងស្រុកបូទុមសាគរ
- បានចុះធ្វើបញ្ជីសំណួរអង្កេតទិន្នន័យសហគមន៍កសិកម្មប្រចាំឆ្នាំ២០២៣ ក្រោយពីធ្វើមហាសន្និបាតប្រចាំឆ្នាំ ២០២៣រួចរាល់ របស់សហគមន៍អភិវឌ្ឍន៍កសិកម្មសាមគ្គីធម៌ នៅឃុំបឹងព្រាវ ស្រុកស្រែអំបិល មានអ្នកចូលរួម សរុបចំនួន៨នាក់ ស្រី៣នាក់
- បានចុះបើកវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធកសិកម្មចម្រុះ ចំនួន១វគ្គ នៅឃុំកណ្តោល ស្រុកបូទុមសាគរ មានអ្នក ចូលរួមសរុប២០នាក់ ស្រី១៥នាក់
- បានចុះបើកវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសកែច្នៃផលិតផលកសិកម្មការធ្វើចេកឆាប និងជ្រក់ត្រសក់ ចំនួន ១វគ្គ នៅឃុំឫស្សីជ្រុំ ស្រុកថ្មបាំង មានអ្នកចូលរួមសរុប២៥នាក់ ស្រី១៣នាក់
- បានសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិ FFI ចុះបើកវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំរបាយការណ៍ និងការធ្វើកំណត់ហេតុដល់គណៈកម្មការសហគមន៍នេសាទ ចំនួន៣វគ្គ រួមមាន៖ សហគមន៍នេសាទឃុំព្រែកខ្សាច់ សហគមន៍នេសាទឃុំជ្រោយប្រស់ និងសហគមន៍នេសាទឃុំពាមក្រសោប មានអ្នកចូលរួមសរុបចំនួន៣១នាក់ ស្រី៨នាក់។

**ខ.ការងារខណ្ឌរដ្ឋបាលជលផល**

- បានចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងដែនសមត្ថកិច្ចចំនួន៥លើក ជួបប្រទះបទល្មើស៥ករណី ក្នុងនោះ៖
    - ដកហូតលបកន្ទុយកណ្តុរ ចំនួន៣៨២ខ្សែ ប្រវែង៣.០៥៦ម ស្មើនឹង២ករណី
    - ឃាត់ចាប់ទូកនេសាទដោយអួនអូសក្រៅតំបន់អនុញ្ញាតឱ្យធ្វើនេសាទ និងប្រើប្រាស់នាវានេសាទ ធ្វើ នេសាទក្នុងដែននេសាទគ្មានលិខិតអនុញ្ញាត ចំនួន៣គ្រឿង ស្មើនឹង៣ករណី
- ដាក់មេក្តាមពងចូលក្នុងធនាគារក្តាម បានចំនួន១៤៧ ស្មើនឹង១៤,៦០គ.ក្រ
- បានចុះទស្សនកិច្ចមជ្ឈមណ្ឌល អភិរក្សសត្វល្មូនខេត្តកោះកុង របស់អង្គការសមាគមអភិរក្សសត្វព្រៃ(WCS) ស្ថិតនៅភូមិទួលគគីរក្រោម ឃុំទួលគគីរ ស្រុកមណ្ឌលសីមា មានអ្នកចូលរួមសរុបចំនួន១៤នាក់ ស្រី៥នាក់។ ជាលទ្ធផលឃើញថា មជ្ឈមណ្ឌលអភិរក្សនេះកំពុងថែទាំអណ្តើកហ្លួងសរុប២៤៥ក្បាល ក្នុងនោះ មានមេពូជ ចំនួន៥០ក្បាល (ញី២៥ក្បាល) និងកូនអណ្តើកហ្លួងទើបញាស់ចំនួន១២៣ក្បាល។ សព្វថ្ងៃមជ្ឈមណ្ឌលនេះ កំពុងដំណើរការសាងសង់ស្រះថែបំប៉នមេពូជចំនួន២ស្រះបន្ថែមទៀត ដើម្បីបង្កាត់ពូជបង្កើនចំនួនពងកូន សម្រាប់លែងចូលទីជម្រកធម្មជាតិវិញ
- បានសហការជាមួយក្រុមការងារថ្នាក់ខេត្ត ចុះរៀបចំផ្តល់សេវាកម្មចុះបញ្ជីជលយានគ្រប់ប្រភេទ ជូនដល់ប្រជា-ពលរដ្ឋនៅក្នុងក្រុងខេមរភូមិន្ទ បានចំនួន៦៤គ្រឿង និងស្នើសុំពាក្យធ្វើអាជីកម្មនេសាទសមុទ្រប្រចាំឆ្នាំ២០២៤ បានចំនួន៦គ្រឿង
- ផលនេសាទទឹកសាបអនុវត្តបានចំនួន២តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន៤.៣០០តោន (សិប្បកម្មចំនួន៣.៨៦៦តោន)
- ការកែច្នៃផលិតផលជលផលអនុវត្តបានចំនួន១០២តោន និងផលិតផលទឹកត្រីអនុវត្តបាន៣.០០០លីត្រ
- ផលវារីវប្បកម្មអនុវត្តបានចំនួ២.៤០០តោន
- ការចរាចរផលនេសាទទៅតាមបណ្តារាជធានី/ខេត្តសរុបចំនួន៣.៤៧៥តោន(កែច្នៃចំនួន៩០តោន)។

**គ. ការងារខណ្ឌរដ្ឋបាលព្រៃឈើ**

- បានចុះសិក្សាវាយតម្លៃឈើអាកាស្យា នៃស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើជីផាត (ទំហំ៤០០ហិកតា) ដែល បានចុះកិច្ចសន្យាលក់-ទិញដើមឈើអាកាស្យា និងប្រេងខ្យល់ជាមួយក្រុមហ៊ុន អេច អិម អិម អ៊ិនជើណេសិនណល ស្ថិតនៅឃុំជីផាត ស្រុកថ្មបាំង។ បច្ចុប្បន្ន ក្រុមហ៊ុននេះ បានសហការជាមួយក្រុមហ៊ុន វីអិនជីស៊ី អ៊ីមផត អិចផត ក្នុងការកាប់ប្រមូលផលឈើអាកាស្យា ដើម្បីធ្វើការកែច្នៃ និងនាំចេញទៅកាន់ទីផ្សារក្រៅប្រទេស

- បានចុះពិនិត្យទីតាំងស្នើសុំកាប់ប្រមូលផលឈើអាកាស្យា ក្នុងតំបន់ដីកាត់ឆ្វៀលចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្គ្រីនរិច គ្រុប ស្ថិតក្នុងភូមិសាស្ត្រឃុំជ្រោយប្រស់ ស្រុកកោះកុង តាមអនុក្រឹត្យលេខ៤៦ អនក្រ.បក ដែលប៉ះពាល់ដល់ចម្ការឈើអាកាស្យារបស់ក្រុមហ៊ុនចំនួន២.៤០០ហ.ត។ ក្រុមការងារបានសិក្សាវាយតម្លៃធនធានឈើអាកាស្យាឃើញថា ដើមឈើអាកាស្យាដែលអាចប្រមូលផលបានមានប្រមាណពី៥០០ដើម ទៅ៦៨៥ដើម/ហ.ត និងដើមឈើអាកាស្យាដែលត្រូវបានបំផ្លាញដោយសារភ្លើងឆេះព្រៃ និងការកាប់ទន្រ្ទានវាតយកដីធ្វើជាកម្មសិទ្ធិមានប្រមាណពី៩៨០ដើម ទៅ១.១៦៦ដើម/ហ.ត
- បានចេញលិខិតដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនដល់ក្រុមហ៊ុនវារីអគ្គិសនីស្ទឹងមេទឹក ដែលទទួលសិទ្ធិក្នុងការប្រមូលផលអនុផលព្រៃឈើ និងបង្កើតរោងម៉ាស៊ីនអារ កែច្នៃឈើបណ្ដោះអាសន្ន ក្នុងតំបន់បាតអាងវារីអគ្គិសនីស្ទឹងមេទឹក ក្នុងខេត្តពោធិ៍សាត់ និងខេត្តកោះកុង ដូចខាងក្រោម៖
  - កូនឈើអង្កត់ផ្ចិតទំហំគល់ពី១៥ស.ម ដល់៣០ស.ម ចំនួន៦០២ដើម ចូលរោងម៉ាស៊ីនអារ កែច្នៃឈើបណ្ដោះអាសន្ន ក្នុងតំបន់បាតអាងវារីអគ្គិសនីស្ទឹងមេទឹក ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - ឈើហ៊ុបមូល ចំនួន៦៤៣កំណាត់ ស្មើនឹង៣៣៩ម³០៨៦ ចូលរោងម៉ាស៊ីនអារ កែច្នៃឈើបណ្ដោះអាសន្ន ក្នុងតំបន់បាតអាងវារីអគ្គិសនីស្ទឹងមេទឹក ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - ឈើអារប្រភេទលេខ២ចំនួន៥៦៣ដើម ស្មើនឹង២០ម³៣៩៤ ចេញពីរោងម៉ាស៊ីនអារ កែច្នៃឈើ បណ្ដោះអាសន្ន ក្នុងតំបន់បាតអាងវារីអគ្គិសនីស្ទឹងមេទឹក ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ឆ្ពោះទៅគោលដៅប្រើប្រាស់ភូមិត្រពាំងពោន ឃុំបន្ទាយមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត។
- បានចុះតាមដានត្រួតពិនិត្យ និងទប់ស្កាត់ការទន្រ្ទានកាន់កាប់ដីពីសំណាក់ប្រជាពលរដ្ឋ លើចម្ការឈើអាកាស្យាស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ចំនួន២លើក ដោយពុំបានជួបប្រទះនូវសកម្មភាពណាមួយគួរឱ្យកត់សម្គាល់ឡើយ។

## ២.១.២-ការងារធនធានទឹក និងឧតុនិយម

- បានចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្លុង ស្ថិតនៅភូមិខ្លុង ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្ដោល ស្ថិតនៅភូមិឆ្នង់ និងភូមិកណ្ដោល ឃុំកណ្ដោល ស្រុកបូទុមសាគរ
- បានប្រមូលទិន្នន័យឧតុនិយមនៅតាមបណ្ដាស្រុក ដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃជីត្រេះ ប្រវែង៦.២០០ម ស្ថិតក្នុងអណ្ដូងទឹក ស្រុកបូទុមសាគរ សម្រេចបាន១០០%
- បានជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃជីមាល ប្រវែង៤.២០០ម ស្ថិតក្នុងឃុំអណ្ដូងទឹក ស្រុកបូទុម-សាគរ សម្រេចបាន១០០%
- បានសាងសង់សំណង់លូទឹក១កន្លែង ស្ថិតក្នុងឃុំដងពែង ស្រុកស្រែអំបិល សម្រេចបាន១០០%
- បានចុះពិនិត្យស្ថានភាពអាងទឹក និងទឹកប្រើប្រាស់ក្នុងភូមិសាស្ត្រខេត្តកោះកុង។

## ២.១.៣-ការងារអភិវឌ្ឍជនបទ

- បានចុះត្រួតពិនិត្យ និងស្រង់ទិន្នន័យចំនួនស្រះទឹក អណ្ដូងទឹក និងប្រព័ន្ធចែកចាយទឹកដែលមានស្ថានភាពរីងស្ងួតនៅទូទាំងខេត្តកោះកុង ដូចខាងក្រោម៖
  - ចំនួនស្រះទឹកសរុប៥០៨ស្រះ រីងស្ងួតចំនួន២៧៦ស្រះ
  - ចំនួនអណ្ដូងលូសរុប៣.០៤២ រីងស្ងួតចំនួន១.០៦០អណ្ដូង និងខូចចំនួន៤៩អណ្ដូង
  - ចំនួនអណ្ដូងស្នប់សរុប៥៨៧អណ្ដូង រីងស្ងួតចំនួន១២៧អណ្ដូង និងខូចចំនួន១១១អណ្ដូង
- បានចុះចែកសម្ភារបង្គន់អនាម័យជាលក្ខណៈគ្រួសារជូនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិអន្លង់វ៉ាក់ចំនួន៤០បង្គន់ និងភូមិកោះអណ្ដែតចំនួន៤០បង្គន់ សរុបចំនួន៨០បង្គន់ នៅស្ថិតឃុំតាតៃក្រោម ស្រុកកោះកុង។

## ២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេងឥន្ធនៈក្នុងស្រុកគិរីសាគរ បានចំនួន២មូលដ្ឋាន ដែលមានដៃបាញ់ប្រេងសរុបចំនួន១០ដៃ។ ជាលទ្ធផល ដៃបាញ់ប្រេងទាំងអស់ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដែលអាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបាន
- បានយកសំណាកផលិតផលទៅវិភាគគុណភាព នៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ បានចំនួន៣មូលដ្ឋាន ស្មើនឹង៤ប៉ាន់គំរូ ជាលទ្ធផល អនុលោមតាមគុណភាពស្តង់ដារដែលបានកំណត់
- បានចេញសេចក្តីសម្រេចបង្កើតសហគ្រាស/សិប្បកម្ម ដោយយន្តការច្រកចេញចូលតែមួយរបស់មន្ទីរ ជូនម្ចាស់សហគ្រាស/សិប្បកម្ម បានចំនួន១មូលដ្ឋាន គឺសិប្បកម្មកែច្នៃដើមខ្លឹមចន្ទន៍ក្រស្នា ស្ថិតនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- បានចុះត្រួតពិនិត្យប្រភពទឹក របស់ក្រុមហ៊ុន/ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន៣មូលដ្ឋាន មានដូចខាងក្រោម៖
    - ក្រុមហ៊ុនអិល វ៉ាយ ភីគ្រុប ខូអិលធីឌី (L.Y.P Group Co.,Ltd) ស្ថិតនៅភូមិបឹងឃុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ ជាលទ្ធផល ស្ថានភាពទឹកក្នុងទំនប់ជ្រោះតាប៉ន មានកម្ពស់ប្រហែល៧ម និងស្ថានភាពទឹកក្នុងស្រះភូមិថ្មី មានកម្ពស់ប្រហែល៣,៧០ម
    - ក្រុមហ៊ុន កើត ខនស្ត្រាក់សិន ស្ថិតនៅភូមិបឹងព្រាវ ឃុំបឹងព្រាវ ស្រុកស្រែអំបិល។ ជាលទ្ធផល ស្ថានភាពទឹកក្នុងបឹងមានកម្ពស់ប្រហែល៧ម និងបានណែនាំម្ចាស់ក្រុមហ៊ុន ធ្វើសេចក្តីជូនដំណឹងស្តីពីការកំណត់ម៉ោងបើក បិទទឹកស្អាតសម្រាប់អតិថិជនប្រើប្រាស់
    - ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត លោកស្រី ហុង មុំ ស្ថិតនៅភូមិថ្មស ឃុំថ្មស ស្រុមបូទុមសាគរ ។ ជាលទ្ធផល ស្ថានភាពទឹកក្នុងស្រះមានតិចតួច និងបានបុកអណ្តូងទឹកចំនួន៣ ដោយបូមទឹកបាន១៥ម$^{៣}$/ម៉ោង និងបានណែនាំម្ចាស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ធ្វើសេចក្តីជូនដំណឹង ស្តីពីការកំណត់ម៉ោងបើក បិទទឹកស្អាតសម្រាប់អតិថិជនប្រើប្រាស់។

## ២.១.៥-ការងាររ៉ែ និងថាមពល

- ចុះពិនិត្យ និងណែនាំដល់អាជីវករ ជីកយកអាចម៍ដីក្រហម ដើម្បីស្ថាបនាផ្លូវជាតិលេខ៤៨ ចំនួន៣ទីតាំង រួមមាន៖
    - លោកស្រី យ៉ែម ស្រីនាថ មានទីតាំងនៅភូមិជីមាល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
    - លោក សុខ គឹមសាន មានទីតាំងនៅភូមិដីជំនាប ឃុំត្រពាំងរូង ស្រុកកោះកុង
    - លោកស្រី ងួន ស្រីនិច មានទីតាំងនៅភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង

  ជាលទ្ធផល បានអនុវត្តត្រឹមត្រូវតាមសារាចរ និងសេចក្តីណែនាំ របស់មន្ទីររ៉ែ និងថាមពលខេត្ត
- បានចុះពិនិត្យទីតាំងកំណត់ដែនអាជ្ញាប័ណ្ណរវាងសេវាអគ្គិសនីលោកស្រី ម៉ែន កែវភិរម្យ និងក្រុមហ៊ុនអិល វ៉ាយ ភី គ្រុប ខូ អិល ធី ឌី ក្នុងស្រុកមណ្ឌលសីមា ជូនអាជ្ញាធរអគ្គិសនីកម្ពុជា
- បានចូលរួមសហការជាមួយក្រុមការងារក្រសួងរ៉ែ និងថាមពល ចុះស្រង់ទិន្នន័យវិទ្យុសកម្ម នៅមន្ទីររ៉ែ និងថាមពលខេត្តកោះកុង
- បានចុះពិនិត្យ និងវាយតម្លៃតាមការដ្ឋានធ្វើអាជីវកម្មបូមខ្សាច់សំណង់ និងអាចម៍ដីរបស់អាជីវករ ដើម្បីកំណត់សួយសារធនធានរ៉ែបង់ចូលថវិការដ្ឋ បានចំនួន១០៩.៤៥៥,០៦រៀល។

## ២.១.៦-ការងារពាណិជ្ជកម្ម

- បានទទួលទិន្នន័យចុះបញ្ជីពាណិជ្ជកម្ម សរុប៩ក្រុមហ៊ុន/សហគ្រាស ក្នុងនោះ ក្រុមហ៊ុនបើកថ្មីចំនួន១ក្រុមហ៊ុន និងសហគ្រាសឯកបុគ្គលបើកថ្មី ចំនួន៨សហគ្រាស
- បានធ្វើរបាយការណ៍ ស្ដីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ចំនួន១១៩មុខ ផ្ញើជូននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្ម
- បានចុះតាមដានស្រង់តម្លៃទំនិញសំខាន់ៗទាំង៣៨មុខជារៀងរាល់ថ្ងៃ នៅក្នុងផ្សារដងទង់ ក្រុងខេមរភូមិន្ទ ផ្ញើជូនក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលខេត្ត
- បានតាមដានការផ្គត់ផ្គង់ និងតម្រូវការផលិតផលក្នុងស្រុកចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ (អង្ករ សាច់មាន់-ទា ស៊ុតមាន់-ទា សាច់គោ សាច់ជ្រូក ទឹកត្រី....) ដើម្បីធ្វើរបាយការណ៍ជូនអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស រៀងរាល់ថ្ងៃចន្ទ និងថ្ងៃព្រហស្បតិ៍
- បានតាមដានទិន្នន័យព័ត៌មានទីផ្សារសាច់មាន់ សាច់ទា និងពងមាន់ ពងទា ប្រចាំខែជូនអគ្គនាយកដ្ឋានពាណិជ្ជកម្ម ក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម
- បានចុះចែកសេចក្ដីជូនដំណឹងស្ដីពីតម្លៃលក់រាយប្រេងឥន្ធនៈចំនួន៣លើក តាមស្ថានីយ និងដេប៉ូលក់រាយប្រេងឥន្ធនៈ សរុបចំនួន៣៣ស្ថានីយ/ដេប៉ូ ក្នុងនោះមាន ៖
  - ក្រុងខេមរភូមិន្ទ ចំនួន៤ស្ថានីយ និង៧ដេប៉ូ
  - ស្រុកមណ្ឌលសីមា ចំនួន៣ដេប៉ូ
  - ស្រុកកោះកុង ចំនួន១ស្ថានីយ
  - ស្រុកបូទុមសាគរ ចំនួន៥ដេប៉ូ
  - ស្រុកថ្មបាំង ចំនួន២ដេប៉ូ
  - ស្រុកគិរីសាគរ ចំនួន១ដេប៉ូ
  - ស្រុកស្រែអំបិល ចំនួន២ស្ថានីយ និង៨ដេប៉ូ
- បានចុះតាមដានតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ និងដេប៉ូលក់ប្រេងឥន្ធនៈរៀងរាល់ថ្ងៃ ក្នុងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា។ ជាលទ្ធផល បានពិនិត្យឃើញថា ម្ចាស់ស្ថានីយ/ដេប៉ូ ពុំបានលក់លើសពីតម្លៃដែលក្រសួងបានកំណត់ឡើយ
- បានចូលរួមសហការជាមួយសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ដើម្បីចុះត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារ និងទំនិញហួសកាលបរិច្ឆេទប្រើប្រាស់ចំនួន១លើក ក្នុងស្រុកមណ្ឌសីមា
- បានចុះសិក្សា និងសាកសួរព័ត៌មានពីលោក វង្ស ដារ៉ា អនុប្រធានសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប អំពី ក្ដាមថ្ម បង្គាក្រៀម គ្រំចំពុះទា ដើម្បីរៀបចំធ្វើខិត្តប័ណ្ណផ្សព្វផ្សាយពីផលិតផលសក្ដានុពលក្នុងខេត្ត នៅក្នុងស្រុកមណ្ឌលសីមា
- បានចូលរួមកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំវេទិកាផ្គូផ្គងរវាងអ្នកលក់ និងអ្នកទិញ ក្រោមគម្រោងអភិវឌ្ឍអាជីវកម្ម និងការទទួលបានទីផ្សារសម្រាប់អ្នកផលិតក្នុងស្រុក និងM/SMEs និងនាំចេញនៅនឹងកន្លែង នៅសាលប្រជុំ(ខ) សាលាខេត្ត
- បានចុះតាមដានស្ថានភាពជួញដូរទំនិញ នៅតាមច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាមប្រចាំសប្ដាហ៍ ដើម្បីរាយការណ៍ជូនអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម។

### ២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ

#### ២.១.៧.១-ការងារហិរញ្ញវត្ថុ

- ចំណូលថវិកាពីមន្ទីរជំនាញ មានចំនួន ៦៥.២៨១.២០៦រៀល
- ចំណាយថវិការបស់មន្ទីរជំនាញ មានចំនួន ២.៦៨៤.៥៦៩.០៧៩រៀល
- ចំណូលមិនមែនសារពើពន្ធ មានចំនួន ៦.៥១៧.៧០៩រៀល
- ចំណូលថវិការបស់ក្រុង ស្រុក មានចំនួន ១.៧៩៧.០២៦.០១០រៀល
- ចំណាយថវិការបស់ក្រុង ស្រុក មានចំនួន ២.៧៤៣.៨៤២.៣១៤រៀល
- បានពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈជាប្រចាំ
- បានរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ជាប្រចាំ។

#### ២.១.៧.២-ការងារពន្ធដារ

- បានប្រមូលចំណូលពន្ធដើម្បីបែងចែកចូលថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន៦១៩.១២៨.៩៤៣រៀល ស្មើនឹង៤,៤៤% នៃផែនការឆ្នាំក្នុងនោះ ៖
  - ចំណូលបង់ចូលថវិកាថ្នាក់ជាតិមានចំនួន២៦៥.៩២២.៦២៩រៀល ស្មើនឹង៥,៣៨% នៃផែនការឆ្នាំ
  - ចំណូលបង់ចូលថវិកាថ្នាក់ក្រោមជាតិមានចំនួន៣៥៣.២០៦.៣១៤ រៀល ស្មើនឹង៣,៩៣%នៃផែនការឆ្នាំ។

#### ២.១.៧.៣-ការងារគយ និងរដ្ឋាករ

- ប្រមូលចំណូលសរុបបានចំនួន១៤.៨៦៥.៤១៨.៥០០រៀល ស្មើនឹង១០២,៥២% នៃផែនការប្រចាំខែ ប្រៀបធៀបនឹងខែមេសា ឆ្នាំ២០២៤ ចំនួន១១.៦១១.៣៨៣.៤០០រៀល កើនឡើងចំនួន៣២,៥៤%
- បានសហការជាមួយកងកម្លាំងប្រដាប់អាវុធខេត្តកោះកុង ដើម្បីទប់ស្កាត់ទំនិញល្មើសច្បាប់នៅផ្លូវជាតិ៤៨ ចំណុចអណ្តូងទឹក ស្ថិតក្នុងភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ និងច្រករបៀង
- ការបង្ក្រាបបទល្មើសប្រចាំខែ មាន៖
  - រថយន្ត ចំនួន៤គ្រឿង
  - ម៉ូតូ ចំនួន៣៤១គ្រឿង
  - បារី ចំនួន២.៥៦១កេស
- បានពង្រឹងការគ្រប់គ្រងឯកសារប្រតិវេទន៍គយ គ្រប់គ្រងការបិទតែមគយ និងត្រួតពិនិត្យទំនិញបានហ្មត់ចត់
- បានពង្រឹងការធ្វើប្រតិវេទន៍គយឱ្យបានសុក្រឹតតាមការណែនាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

### ២.១.៨-ការងារទេសចរណ៍

- បានផ្សព្វផ្សាយសក្តានុពលទេសចរណ៍ក្នុងខេត្តតាមរយៈសៀវភៅផ្ទត់ គេហទំព័រ Mobile App (Visit Cambodia) និងហ្វេសប៊ុក ដល់ភ្ញៀវទេសចរ
- បានចុះស្រង់ទិន្នន័យស្ថិតិភ្ញៀវទេសចរមកកម្សាន្ត និងស្នាក់នៅក្នុងខេត្ត៖
  - ភ្ញៀវទេសចរជាតិស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន៦១.៩៣៣នាក់ កើនឡើង ១៥.៩០៨នាក់ ស្មើនឹង៣៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣
  - ភ្ញៀវទេសចរបរទេសស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន១.៧៦១នាក់ កើនឡើង ៩៥២ នាក់ ស្មើនឹង ១១៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣
  - ➢ សរុបភ្ញៀវទេសចរជាតិ និងបរទេសចំនួន៦៣.៦៩៤នាក់ កើនឡើង១៦.៨៦០ នាក់ ស្មើនឹង៣៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៣

- ភ្ញៀវទេសចរមកកម្សាន្តតាមសហគមន៍៖
  - ភ្ញៀវទេសចរជាតិ មានចំនួន១៣.២៤៦នាក់
  - ភ្ញៀវទេសចរបរទេស មានចំនួន៤៩២នាក់
- បានផ្តល់អាជ្ញាប័ណ្ណជូនអាជីវករចំនួន៩កន្លែង តាមរយៈក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ខេត្ត អង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ក្នុងនោះមាន៖
  - ក្រសួងទេសចរណ៍
    - សណ្ឋាគារ ចំនួន ១ កន្លែង (បន្ត)
  - អង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត
    - ផ្ទះសំណាក់ ចំនួន ២ កន្លែង (បន្ត១ , ថ្មី១)
    - បៀហ្គាឌិន ចំនួន ១ កន្លែង (ថ្មី)
  - ការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ
    - ខារ៉ាអូខេ ចំនួន ១ កន្លែង (ថ្មី)
  - ការិយាល័យច្រកចេញចូលតែមួយស្រុកមណ្ឌលសីមា
    - ផ្ទះសំណាក់ ចំនួន ១ កន្លែង (ថ្មី)
    - បន្ទប់ជួល ចំនួន ២ កន្លែង (បន្ត១ ,ថ្មី១)
    - ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ចំនួន ១ កន្លែង (បន្ត)
- បានចុះស្រង់ស្ថិតិអាជីវកម្ម សេវាកម្មទេសចរណ៍ និងចុះធ្វើបច្ចុប្បន្នភាពបុគ្គលិកបម្រើការ ក្នុងវិស័យទេសចរណ៍ ក្នុងមូលដ្ឋានស្រុកស្រែអំបិល និងស្រុកគិរីសាគរ
- បានចុះត្រួតពិនិត្យទីតាំងស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ថ្មី ចំនួន២កន្លែង ក្នុងនោះ មានភោជនីយដ្ឋានទេសចរណ៍ចំនួន១ទីតាំង ស្ថិតក្នុងភូមិនាងកុក ឃុំប៉ាក់ខ្លង និងផ្ទះសំណាក់១ទីតាំង ស្ថិតក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានចុះសម្ភាសកម្រងសំណួរស្តីពី "ការសិក្សាកម្លាំងពលកម្ម និងការបណ្តុះបណ្តាលក្នុងមូលដ្ឋានអាជីវកម្មទេសចរណ៍" ដែលស្ថិតក្នុងស្រុកកោះកុង សរុបចំនួន១៨កន្លែង ក្នុងនោះរួមមាន ផ្ទះសំណាក់៦កន្លែង ផ្ទះស្នាក់២កន្លែង និងភោជនីយដ្ឋាន អាហារដ្ឋាន១០កន្លែង
- បានបើកវគ្គបណ្តុះបណ្តាលស្តីពី "មគ្គុទេសក៏ទេសចរណ៍សហគមន៍" ជូនដល់សហគមន៍តំបន់ការពារធម្មជាតិភ្នំទំពដាង ឃុំជងពែង ស្រុកស្រែអំបិល
- បានសហការជាមួយរដ្ឋបាលស្រុកថ្មបាំង និងសហគមន៍អេកូទេសចរណ៍ជីផាត រៀបចំកិច្ចប្រជុំផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីអនាម័យបរិស្ថាន ការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងលើកកម្ពស់សោភ័ណភាពសហគមន៍ មានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ប្រជាសហគមន៍ សិស្សានុសិស្ស និងយុវជន សសយក សរុប៧៣នាក់។

## ២.១.៩-ការងារផែនការ

- បានប្រមូល និងបញ្ចូលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ នៅផ្សារស្រែអំបិល ស្ថិតក្នុងស្រុកស្រែអំបិល និងផ្សារដងទង់ ស្ថិតក្នុងក្រុងខេមរភូមិន្ទ ប្រចាំខែឧសភា ឆ្នាំ២០២៤ រួចរាល់
- បានផលិតឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងឯកសារពិន្ទុវិស័យខេត្ត រួចរាល់
- បានផលិតឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ក្រុង ស្រុក និងឃុំ សង្កាត់ រួចរាល់
- បានចុះសម្របសម្រួលតាមដានត្រួតពិនិត្យការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យតាមបណ្តាឃុំ-សង្កាត់ រួចរាល់
- បានផលិតប័ណ្ណសមធម៌ជូនគ្រួសារក្រីក្រថ្មីចំនួន២០ប័ណ្ណ និងចេញប័ណ្ណចំនួន១១ប័ណ្ណ ផ្តល់ជូនគ្រួសារដែលបានបាត់ប័ណ្ណ។

### ២.១.១០-ការងារផ្សេងៗ

#### ២.១.១០.១-ការងារសាខាធនាគារជាតិនៃកម្ពុជា

- ចំណូលជាប្រាក់រៀលសរុបចំនួន៩.៤៥៨.៩៥០.០០០រៀល បើប្រៀបធៀបទៅនឹងខែមុនកើន១២,៣៧%
- ចំណូលជាប្រាក់ដុល្លារសរុបចំនួន៨.២៩៩.៩២៣ដុល្លារ បើប្រៀបធៀបទៅនឹងខែមុនកើន៥,៣៧%
- ចំណាយជាប្រាក់រៀលសរុបចំនួន៤.៣៩៩.០៨៩.៤០០រៀល បើប្រៀបធៀបទៅនឹងខែមុនថយ៤៣,៤៦%
- ចំណាយជាប្រាក់ដុល្លារចំនួន៧០០.០០០ដុល្លារ បើប្រៀបធៀបទៅនឹងខែមុនថេរ
- បានប្តូរប្រាក់រៀល ចាស់ រហែក ទក់ សរុបចំនួន១.០២៩.៨០០.០០០រៀល
- បានចេញលិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់មានសុពលភាពដើមគ្រាសរុប ចំនួន៥២ច្បាប់
- បានចេញលិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់មានសុពលភាពចុងគ្រាសរុប ចំនួន៥២ច្បាប់។

#### ២.១.១០.២-ការងាររតនាគារ

- បានពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធ FMIS ជូនមន្រ្តីជំនាញជាបន្តបន្ទាប់
- បានពង្រឹងការអនុវត្តការកត់ត្រាចំណូលចំណាយតាមប្រព័ន្ធ FMIS ជូនមន្ត្រីបានកាន់តែប្រសើរ
- បានពង្រឹងការអនុវត្តនូវសារាចរណែនាំស្តីពីការអនុវត្តនីតិវិធីបើកផ្តល់ប្រាក់បៀវត្សរាល់ ២សប្តាហ៍ម្តង ក្នុងខែនីមួយៗជូនមន្ត្រីរាជការបានទាន់ពេលវេលា
- បានពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល( FMIS Portal )ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ បានកាន់តែប្រសើរ
- ចំណូលសរុបមានចំនួន២៧.២០៥លានរៀល ក្នុងនោះ៖
  - ចំណូលពីអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន៧.៣២៦លានរៀល
  - ចំណូលមូលដ្ឋានមានចំនួន១៩.៨៧៩លានរៀល
- ចំណាយសរុបមានចំនួន២៩.០១០លានរៀល ក្នុងនោះ៖
  - ផ្ទេរទៅអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន២០.១៧៥លានរៀល
  - ចំណាយមូលដ្ឋានមានចំនួន៨.៨៣៥លានរៀល។

#### ២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំខេត្ត

- បានចុះត្រួតពិនិត្យទំនិញតាមផ្ទះលក់ដូរ ម៉ាត និងផ្សារ ចំនួន៤លើក
- បានផ្សព្វផ្សាយអំពីសុវត្ថិភាពម្ហូបអាហារដល់សិស្សវិទ្យាល័យ ជីផាត និង វិទ្យាល័យឫស្សីជ្រុំសរុប៥០០នាក់
- បានដកហូតទំនិញហួសកាលបរិច្ឆេទប្រើប្រាស់ និងទំនិញក្លែងក្លាយសរុបចំនួន១៤,៥គីឡូក្រាម
- បានចែក និងបិទផ្ទាំងផ្សព្វផ្សាយស្តីពីសុវត្ថិភាពម្ហូបអាហារបានចំនួន៣៥០ផ្ទាំង
- បានចុះត្រួតពិនិត្យតម្លៃលក់រាយប្រេងឥន្ធនៈតាមបណ្តាស្ថានីយ/ដេប៉ូក្នុងខេត្ត២លើក សរុបចំនួន១៦ស្ថានីយ/ដេប៉ូ ក្នុងនោះ ៤ទីតាំងលក់ស្មើតម្លៃដូចសេចក្តីជូនដំណឹង និង១២ទីតាំងទៀត លក់ទាបជាងសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម។

## ២.២-ផ្នែកសង្គមកិច្ច

### ២.២.១-ការងារអប់រំ យុវជន និងកីឡា

- បានចុះពិនិត្យស្ថានភាពទូទៅ និងវាយតម្លៃសុពលភាពគម្រោងសាងសង់ និងជួសជុលអគារសិក្សាមួយចំនួន នៅតាមគ្រឹះស្ថានសិក្សាក្នុងក្រុងខេមរភូមិន្ទ និងស្រុកស្រែអំបិល។ ជាលទ្ធផល ការងារសាងសង់ និងជួសជុលសំណង់អគារសិក្សានេះ សាលាទទួលបានផ្លូវបេតុងអាមេ ការចាក់សាប ដំបូល ជញ្ជាំង បង្គន់អនាម័យ និងបំពាក់គ្រឿងសង្ហារឹម បានសមស្របតាមតម្រូវការរបស់សាលា

- បានចុះអធិការកិច្ចតាមកាលកំណត់ នៅតាមគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា ក្នុងស្រុកមណ្ឌលសីមា និងស្រុកស្រែអំបិល។ ជាលទ្ធផល បានធ្វើតេស្តស្ទង់ជារសិស្សថ្នាក់ទី៦ និងថ្នាក់ទី១១ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា សម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ ផ្តែកលើសូចនាករធំ៤គឺ
    - លទ្ធផលសិក្សារបស់សិស្ស ការបង្រៀន រៀន និងការចូលរួមរបស់សហគមន៍
    - ដំណើរប្រតិបត្តិការ រដ្ឋបាលសាលារៀន និងគណនេយ្យភាព
    - អធិការកិច្ចថ្នាក់រៀន (ថ្នាក់ទី៤ ដល់ថ្នាក់ទី៦ និងមធ្យមសិក្សាថ្នាក់ទី១១)
    - ពិនិត្យ និងសង្កេតលើស្ថានភាពទូទៅរបស់សាលា
- បានសហការជាមួយក្រុមការងារនាយកដ្ឋានអប់រំកុមារតូច ចុះប្រមូលទិន្នន័យស្តីពី ការអនុវត្តជាសាលារៀនគំរូនៅតាមសាលាមត្តេយ្យសិក្សាប៉ាក់ខ្លង ស្រុកមណ្ឌលសីមា និងសាលាមត្តេយ្យសិក្សាថ្មស ស្រុកបូទុមសាគរ។ ជាលទ្ធផល ក្រុមការងារប្រមូលទិន្នន័យ និងប្រជុំបូកសរុបជ្រើសរើសយកសាលាមត្តេយ្យ សិក្សាថ្មស ដើម្បីដាក់ពាក្យស្នើសុំវាយតម្លៃសម្រាប់ថ្នាក់ជាតិ
- បានបើកវគ្គសិក្ខាសាលាណែនាំដល់ថ្នាក់សាលារៀន ស្តីពីការគ្រប់គ្រងទិន្នន័យមុខងារអប់រំផ្សារភ្ជាប់នវានុវត្តន៍នៃការគ្រប់គ្រងសាលារៀន នៅតាមសាលាបឋមសិក្សា គោលដៅទាំង២១ ក្នុងក្រុង/ស្រុកទាំង៧។ ជាលទ្ធផល ក្រោយបញ្ចប់វគ្គ នាយក លោកគ្រូ អ្នកគ្រូ ទាំង២១សាលា បានទទួលនូវកិច្ចការទាំង៦ របស់គម្រោងកែលម្អគុណភាពអប់រំ
- បានសហការជាមួយអង្គការ UNICEF ចុះផ្តល់ជំនួយបច្ចេកទេសលើការអនុវត្តកញ្ចប់សម្ភារៈអំណាន ថ្នាក់ដំបូងដល់លោកនាយក លោកគ្រូ អ្នកគ្រូ នៅសាលាបឋមសិក្សាឫស្សីជ្រុំ សាលាបឋមសិក្សាថ្មដូនពៅ និងសាលាបឋមសិក្សាភូមិកោះ ក្នុងស្រុកថ្មបាំង និងសាលាបឋមសិក្សាកោះស្រឡៅ ស្រុកកោះកុង។ ជាលទ្ធផល លោកនាយក និងលោកគ្រូ អ្នកគ្រូទទួលបានបច្ចេកទេសថ្មីៗបន្ថែមពីក្រុមការងារសម្រាប់អនុវត្តបន្ត
- បានដឹកនាំសិស្សពូកែថ្នាក់ខេត្ត ថ្នាក់ទី៩ និងថ្នាក់ទី១២ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា ចូលរួមប្រឡងថ្នាក់ជាតិ នៅរាជធានីភ្នំពេញ។ ជាលទ្ធផល សិស្សានុសិស្សមិនទទួលបានលទ្ធផលនៃការប្រឡងនោះទេ
- បានចុះពិនិត្យតាមដានដំណើរការបើកប្រាក់អាហារូបករណ៍រាជរដ្ឋាភិបាលឆ្នាំសិក្សា ២០២៣-២០២៤ ក្នុងក្រុងខេមរភូមិន្ទ។ ជាលទ្ធផល សិស្សានុសិស្សបានទទួលថវិកាអាហារូបករណ៍បានគ្រប់ចំនួន និងមានការចូលរួមពីអាជ្ញាធរ ឃុំ/សង្កាត់ មាតាបិតា អាណាព្យាបាលសិស្សផ្ទាល់
- បានចុះពិនិត្យតាមដានលើការងារអប់រំកាយ-កីឡា និងអនុវត្តកម្មវិធីអភិវឌ្ឍបាល់ទាត់ បង្កើតApp FIFA Football for Schools នៅសាលាបឋមសិក្សារុងផ្លាមកេសន ស្រុកកោះកុង។ ជាលទ្ធផល គ្រូយល់ពីកម្មវិធីបាល់ទាត់ និងចេះប្រើប្រាស់កម្មវិធី Football for Schools បានល្អប្រសើរ
- បានដឹកនាំក្រុមភ្លេងកាយរឹទ្ធិ ចូលរួមប្រកួតកាយរឹទ្ធថ្នាក់ជាតិលើកទី១ ក្រោមប្រធានបទ ភ្លេងក្នុងសន្តិភាព នៅរាជធានីភ្នំពេញ។

## ២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានសហការជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត និងអាជ្ញាធរឃុំ សង្កាត់ អនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ គ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ ទូទាំងខេត្ត មានចំនួនដូចខាងក្រោម ៖

    ក.ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ សរុបចំនួន៦១៩នាក់ ក្នុងនោះ ៖
    - ស្ត្រីមានផ្ទៃពោះសរុបចំនួន១៤៣នាក់
    - កុមារសរុបចំនួន៣៥៣នាក់
    - សម្រាលកូនសរុបចំនួន១២៣នាក់
    - ថវិកាចំណាយសរុប៨៨.៨៨០.០០០រៀល

ខ.ការអនុវត្តការបើកផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ មានចំនួនដូចខាងក្រោម៖

| ល.រ | ចំនួនយុវជនចុះឈ្មោះ | លទ្ធផលអនុវត្តកម្មវិធី (ចំនួនយុវជនកំពុងសិក្សា) | ថវិកាចំណាយ |
|---|---|---|---|
| ១ | យុវជនក្នុងគ្រួសារក្រីក្រមានប័ណ្ណសមធម៌ចំនួន២០១នាក់ | យុវជនក្នុងគ្រួសារក្រីក្រមានប័ណ្ណសមធម៌ចំនួន៨៩នាក់ | ២៣.៧៧២.០០០៛ |
| ២ | យុវជនក្នុងគ្រួសារមានប័ណ្ណសម្គាល់ហានិភ័យចំនួន១១នាក់ | យុវជនក្នុងគ្រួសារមានប័ណ្ណសម្គាល់ហានិភ័យ ចំនួន១២នាក់ | |
| ៣ | វគ្គសិក្សាដែលបានចុះឈ្មោះចូលកម្មវិធី១០១វគ្គ | វគ្គសិក្សាដែលបានចុះឈ្មោះចូលកម្មវិធីចំនួន៧វគ្គ | |

គ.បានផ្តល់កាតរីងជូនដល់អាជ្ញាធរឃុំ-សង្កាត់ ដើម្បីបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ សរុបចំនួន៨០កាត ក្នុងក្រុងខេមរភូមិន្ទ ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ក្នុងនោះមាន សង្កាត់ស្ទឹងវែង១០កាត ឃុំជ្រោយស្វាយ១០កាតឃុំកណ្តោល២០កាត ឃុំដងពែង១៥កាត ឃុំស្រែអំបិល១៥កាត និងឃុំជីខក្រោម១០កាត

- បានចុះតាមដាន និងត្រួតពិនិត្យក្នុងការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកទទួលបន្ទុកអនុវត្តកម្មវិធី នៅឃុំពាមក្រសោប ស្រុកមណ្ឌលសីមា និងសង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
- បានចុះអប់រំ ផ្សព្វផ្សាយសុខភាពមាតា ទារក និងអាហារូបត្ថម្ភសម្រាប់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារចំនួន១សង្កាត់ (សង្កាត់ស្ទឹងវែង) និង៣ឃុំ (ឃុំទួលគគីរ ឃុំត្រពាំងរូង និងឃុំជ្រោយស្វាយ)
- បានចុះជួបជាមួយសាច់ញាតិរបស់កុមារ និងកុមារចំនួន៧នាក់ ស្រី១នាក់ ដែលបានសមាហរណកម្មពីអង្គការម្លប់តាប៉ាងខេត្តព្រះសីហនុ មកស្នាក់នៅភូមិ២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ជាលទ្ធផល កុមារមានសុខភាពល្អ ប៉ុន្តែពុំសូវបានទៅរៀនទៀងទាត់ទេ ម្យ៉ាងវិញទៀតសាច់ញាតិរបស់កុមារពុំសូវមានលទ្ធភាពចិញ្ចឹមបីបាច់កុមារ ក្នុងនោះ មន្ទីរបានផ្តល់គ្រឿងឧបភោគបរិភោគមួយចំនួន និងអង្ករ២៥គ.ក្រ
- បាននាំកុមារីឈ្មោះ ពៅ កញ្ញា អាយុ៤ឆ្នាំ ស្នាក់នៅមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋខេត្តកោះកុង ជួបសួរសុខទុក្ខ ម្តាយឈ្មោះ ធ.ស.ព អាយុ៤៧ឆ្នាំ ជាប់ពន្ធនាគារ និងបានផ្តល់នំចំណី មី និងទឹកដោះគោមួយចំនួន ដល់កុមារអាយុ៣ឆ្នាំ ស្រី១នាក់ និងបានប្រឹក្សាយោបល់ពីការទុកដាក់កុមារជាមួយសាច់ញាតិនៅក្នុងសហគមន៍វិញ
- បានចុះផ្សព្វផ្សាយស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនមានពិការភាពដល់ជនមានពិការភាពចំនួន៨០នាក់ ស្រី៣៣នាក់ នៅសាលប្រជុំសាលាស្រុកមណ្ឌលសីមា
- បានចូលរួមបើកប្រាក់បេឡាមរណៈសង្គ្រោះជូនដល់គេហដ្ឋានគ្រួសារនៃសព លោក ធឹយ ស៊ីវន ជានិវត្តជន យោធា ដែលបានទទួលមរណភាពនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤ នៅភូមិជីមាល ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ។

## ២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម

### ២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- នៅក្នុងខែឧសភា ឆ្នាំ២០២៤ នេះ ស្ថិតិសហគ្រាស/គ្រឹះស្ថាន ក្នុងខេត្តសរុបចំនួន៦៦ ដែលមានកម្មករនិយោជិតកំពុងបម្រើការងារសរុបចំនួន១៦.៤១១នាក់ ស្រី៨.១៨៣នាក់ ក្នុងនោះមាន៖
    - កម្មករនិយោជិតខ្មែរចំនួន១៤.០៤៦នាក់ ស្រី៧.៦៩១នាក់
    - ពលករបរទេសចំនួន២.៣៦៥នាក់ ស្រី៤៩២នាក់

- បានចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក (ចេញ-ចូល) ចំនួន៥សហគ្រាស/គ្រឹះស្ថាន រួមមាន៖
  - ចលនាចេញចំនួន៥៧២នាក់ ស្រី៣៤៨នាក់
  - ចលនាចូលចំនួន៥៣៩នាក់ ស្រី៣០៦នាក់
- បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការងារដល់កម្មករនិយោជិត និងនិយោជក នៅតាមរោងចក្រ សហគ្រាស ក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង ដើម្បីឱ្យកាន់តែយល់ច្បាស់ក្នុងការអនុវត្តច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិផ្សេងៗ
- បានចុះត្រួតពិនិត្យប្រព័ន្ធសុវត្ថិភាពការងារ នៅតាមច្រកទ្វារពេលមានអាសន្ន និងបំពង់ពន្លត់អគ្គីភ័យបាន៥រោងចក្រ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង
- បានចុះផ្សព្វផ្សាយសេចក្តីណែនាំលេខ ០៥០/២៤ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីវិធានការអនុវត្តបន្ទាន់ នៅតាមរោងចក្រក្នុងអំឡុងពេលអាកាសធាតុក្តៅ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង
- បានចុះសម្របសម្រួលជាមួយរោងចក្រហាណាមីក្រូអេឡេចត្រូនិក ដើម្បីសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលវិញមុនកាលកំណត់)
- បានសហការជាមួយរដ្ឋបាលខេត្ត រៀបចំពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៨ ទិវាពលកម្មអន្តរជាតិ១ឧសភា ឆ្នាំ២០២៤ ក្រោមប្រធានបទ សន្តិភាព ស្ថិរភាព មុខរបរ និងការងារ ក្នុងបរិវេណរោងចក្រយ៉ាហ្សាគី ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង និងមានអ្នកចូលរួមចំនួន៥០០នាក់
- បានពង្រឹងដល់មន្ត្រីរបស់មន្ទីរដែលប្រចាំការជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយបន្តយកចិត្តទុកដាក់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព គុណភាព និងភាពស្មោះត្រង់។

### ២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម

- បានចុះតាមដាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលសេវាសន្តិសុខសង្គមទាំងបួនផ្នែកដូចជា៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំ ផ្នែកសោធន (បង់ភាគទានផ្នែកសោធនស្ម័គ្រចិត្ត) និងស្វ័យនិយោជន៍ មានដូចខាងក្រោម ៖
  - សហគ្រាស/គ្រឹះស្ថាន ដែលបានចុះបញ្ជីផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងស្វ័យនិយោជន៍ ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ
  - បានធ្វើបច្ចុប្បន្នភាពសហគ្រាស/គ្រឹះស្ថាន ដែលបានជាប់វិភាគទានក្នុងខែឧសភា ឆ្នាំ២០២៤ មានចំនួន១០២សហគ្រាស/គ្រឹះស្ថាន សមាជិកសរុបចំនួន១២.៨៦៦នាក់ ស្រី៧.៥០៤នាក់
  - បានទទួលសមាជិកដែលជាបុគ្គលស្វ័យនិយោជន៍ និងបានបង់វិភាគទានចំនួន៦៦៨នាក់ ស្រី៤៥០នាក់ និងសមាជិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តចំនួន៥៥នាក់ ស្រី១៧នាក់
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកហានិភ័យការងារទទួលបានតាវកាលិកចំនួន១នាក់ស្រី
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកថែទាំសុខភាព ទទួលបានតាវកាលិកចំនួន៤៧នាក់ ស្រី៤៣នាក់
  - បានសម្របសម្រួលដល់សមាជិកប.ស.ស.ទាំងវិស័យសាធារណៈ និងវិស័យឯកជនជាស្ត្រីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល មុនសម្រាល និងក្រោយសម្រាលកូន ចំនួន៦៦៤នាក់
  - បានស្នើសុំធ្វើប័ណ្ណទុតិយតាវិស័យសាធារណៈមានចំនួន៦នាក់ ស្រី១នាក់
  - បានចុះបញ្ជិកាសមាជិក ប.ស.ស.វិស័យឯកជន(កម្មករ)ចំនួន៣០៣នាក់ ស្រី៩៦នាក់ ស្វ័យនិយោជន៍ ១៣១នាក់ ស្រី៨១នាក់ និងអ្នកក្នុងបន្ទុក១៨នាក់ ស្រី១០នាក់
  - បានចុះបញ្ជិកាសមាជិក ប.ស.ស.ជាមន្ត្រីសាធារណៈមានចំនួន៩៤នាក់ ស្រី៤៦នាក់ និងអ្នកក្នុងបន្ទុក ៨៥នាក់ ស្រី៥៤។

## ២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- ការតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ចេញពីសំពៅលិច វត្ថុជាតិពន្ធុ និងវត្ថុដែលមាននៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ ខេត្តកោះកុង មានភ្ញៀវចូលទស្សនាចំនួន៤៦នាក់ ស្រី២១នាក់ និងភ្ញៀវបរទេសចំនួន១នាក់
- បានបន្តរៀបចំប្លូរកាតសមុច្ច័យដែលពុកផុយ និងតាំងបង្ហាញប័ណ្ណព័ត៌មានថ្មីលើជញ្ជាំង ចំនួន៣១ផ្ទាំង
- បានរៀបចំសិក្ខាសាលាស្តីពី មូលដ្ឋាននៃការបង្កើត និងការគ្រប់គ្រងសារមន្ទីរប្រកបដោយចីរភាព និងបានធ្វើបទបង្ហាញស្តីពី សក្តានុពលបេតិកភណ្ឌវប្បធម៌នៅខេត្តកោះកុង នាសាលមហោស្រពខេត្តកោះកុង
- បានចុះស្រង់ស្ថិតិទាក់ទងនឹងវិស័យវប្បធម៌ នៅក្រុងខេមរភូមិន្ទ
- បានបង្ហាត់របាំដល់សិស្សចាស់ចំនួន២៦នាក់ ស្រី១៣នាក់ រៀងរាល់ថ្ងៃអាទិត្យ និងមានសិស្សថ្មីហាត់របាំចំនួន ១៦នាក់ស្រី។

## ២.២.៥-ការងារព័ត៌មាន

- ទទួលអ្នកសារព័ត៌មានមកយកព័ត៌មានក្នុងខេត្តកោះកុងសរុបចំនួន២នាក់ មកផ្នែកសារព័ត៌មានជីវីអែនឡាញ
- **ការចុះជំរុញយកព័ត៌មានតាមរយៈការថតវីដេអូ បានចំនួន២៧ព័ត៌មាន និងបានផ្សាយ ៖**
  - តាមរយៈទូរទស្សន៍ជាតិកម្ពុជា (ទទក) បានចំនួន៦ព័ត៌មាន
  - តាមរយៈទូរទស្សន៍បាយ័នបានចំនួន២១ព័ត៌មាន
  - ឆ្លើយឆ្លងព័ត៌មានទទក ព័ត៌មានពេលព្រឹកចំនួន១លើក
- **ផ្សាយបន្តផ្ទាល់ពីវិទ្យុជាតិ៖**
  - ព័ត៌មានជាតិបានចំនួន៦៨ព័ត៌មាន
  - ព័ត៌មានអន្តរជាតិបានចំនួន៣៤ព័ត៌មាន
  - កម្មវិធីសន្ទនាមតិ "ជីវិតយើងសង្គមយើង" បានចំនួន១៧លើក
- **ព័ត៌មានផ្សាយរបស់វិទ្យុសាគរកោះកុង៖**
  - ព្រឹត្តិការណ៍សំខាន់ៗចំនួន៥ព័ត៌មាន
  - សារសំឡេងខ្លីសំខាន់ៗរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត ចំនួន២ព័ត៌មាន
  - ប្រសាសន៍របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មានចំនួន២ព័ត៌មាន
  - ទំព័រហ្វេសប៊ុកផេកវិទ្យុសាគរកោះកុងចំនួន១២០ព័ត៌មាន
  - ព័ត៌មានក្នុងខេត្តចំនួន១៨ព័ត៌មាន
  - ព័ត៌មានជាតិចំនួន១៨ព័ត៌មាន
  - ព័ត៌មានអន្តរជាតិចំនួន១៨ព័ត៌មាន
  - ព័ត៌មានថតផ្សាយជាសំឡេងចំនួន៣៦ព័ត៌មាន
  - ព័ត៌មានពេលព្រឹករយៈពេល៣០នាទីចំនួន៤៩ព័ត៌មាន
  - សេចក្តីជូនដំណឹងផ្សេងៗចំនួន១២អត្ថបទ
  - នាទីព្រះពុទ្ធសាសនាចំនួន១៥ម៉ោង
  - នាទីកម្សាន្តមរតកដើមរួមមាន អាយ៉ៃ យីកេ ល្ខោនបាសាក់ និងល្ខោននិយាយបានចំនួន៣០ម៉ោង
- **អំពីការផ្សាយតាមរយៈផេកហ្វេសប៊ុកទូរទស្សន៍ជាតិខេត្តកោះកុង នៃមន្ទីរព័ត៌មានខេត្ត៖**
  - ផ្សាយព័ត៌មានក្នុងផេកសរុបចំនួន៧៧ព័ត៌មាន
  - ផ្សាយប្រសាសន៍សម្តេចតេជោ ហ៊ុន សែន និងសម្តេចធិបតី ហ៊ុន ម៉ាណែត ចំនួន៣០លើក
  - ផ្សាយព័ត៌មានបន្ត សេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗចំនួន៤៧លើក
  - ផ្សាយតាមរយៈផេកហ្វេសប៊ុករបស់មន្ទីរព័ត៌មានខេត្តកោះកុងចំនួន៣៥០ព័ត៌មាន

- **ឆ្លើយឆ្លងព័ត៌មានពេលព្រឹក និងរាយការណ៍គ្រឿងញៀនតាមវិទ្យុសាគរកោះកុង ៖**
  - ព័ត៌មានតាម WhatsApp ជូនលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន១៦លើក
  - ព័ត៌មានតាមហ្វេសប៊ុកចំនួន១០លើក
- **ផ្សព្វផ្សាយសារអប់រំ និងស្ប៉តៈ**
  - សារអប់រំ និងស្ប៉តស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀនបានចំនួន៦០០លើក
  - សារអប់រំ និងស្ប៉តស្តីពី ពិសាគ្រឿងស្រវឹងសូមកុំបើកបរ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានចំនួន៦០០លើក
  - សារអប់រំអំពីបញ្ហាជំងឺអេដស៍បានចំនួន៣០០លើក
  - សារអប់រំអំពីជំងឺគ្រុនចាញ់បានចំនួន៣០០លើក
  - ស្ប៉តសុខភាព (ញ៉ាំសាប) បានចំនួន១៥០លើក
  - ស្ប៉តស្តីពី ការបញ្ឈប់អំពើហិង្សាលើស្ត្រីបានចំនួន៣០០លើក
  - ស្ប៉តអប់រំក៏ដូចជាវិធីការពារជំងឺកូវីដ-១៩ បានចំនួន៤៥០លើក
  - សារអប់រំស្តីពី ការជួញដូរមនុស្សជាអំពើខុសច្បាប់បានចំនួន១៨០លើក
- **ទីភ្នាក់ងារសារព័ត៌មានកម្ពុជាៈ**
  - បានបញ្ជូនព័ត៌មានជូនអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជានៃក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយតាម APP ចំនួន១៣ព័ត៌មាន
  - បានផ្សាយព័ត៌មានតាមរយៈផេកហ្វេសប៊ុក AKP របស់មន្ទីរព័ត៌មានខេត្តចំនួន១១៤ព័ត៌មាន
  - បានចុះចែកទស្សនាវដ្តីជូនរដ្ឋបាលខេត្តកោះកុងចំនួន១លើក
- បានជំរុញដល់មន្ត្រីជំនាញសិក្សាស្រាវជ្រាវលើបច្ចេកទេសថ្មីៗ
- បានជំរុញ និងពង្រឹងដល់មន្ត្រីជំនាញទទួលបន្ទុកក្នុងការកែលម្អកម្មវិធីផ្សាយឱ្យបានល្អប្រសើរ។

### ២.២.៦-ការងារកិច្ចការនារី

- បានផ្សព្វផ្សាយស្តីពី ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដល់សិស្សានុសិស្ស នៅវិទ្យាល័យប៉ាក់ខ្លង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ដែលមានអ្នកចូលរួមសរុប៨០នាក់ ស្រី៤៦នាក់។ ក្នុងគោលបំណងរួមចំណែក និងបង្កើនការយល់ដឹង ដល់សិស្សានុសិស្ស ធ្វើឱ្យប្រសើរឡើងនូវសីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ និងឱ្យពួកគាត់ទទួលបាននូវសុជីវធម៌ គុណធម៌ និងភាពថ្លៃថ្នូរក្នុងសង្គម
- បានចុះផ្សព្វផ្សាយច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការចំណាកស្រុក និងការជួញដូរមនុស្សដល់ប្រជាពលរដ្ឋ នៅឃុំជីខក្រោម នៅស្រុកស្រែអំបិល មានអ្នកចូលរួមសរុប៥៩នាក់ ស្រី៤០នាក់។ ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ ការចំណាកស្រុកដោយប្រថុយប្រថាន ការជួញដូរមនុស្ស និងផ្សព្វផ្សាយបន្ថែមពីការផ្តល់សេវាមេធាវីជួយជនរងគ្រោះដោយអំពើហិង្សាធ្ងន់ធ្ងរដល់ស្ត្រីក្រីក្រ
- បានប្រឹក្សាយោបល់ករណីអំពើហិង្សាក្នុងគ្រួសារ១ករណី មានកូន៣នាក់ប្រុសក្នុងបន្ទុក មានទីលំនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ មូលហេតុ ប្តីប្រើអំពើហិង្សាលើប្រពន្ធ និងទាមទារទ្រព្យសម្បត្តិចុះចេញពីផ្ទះ។ ជាលទ្ធផល ពួកគាត់សម្រេចចិត្តលែងលះគ្នា និងបានធ្វើកិច្ចសន្យាបញ្ចប់រឿង នៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ស្មាច់មានជ័យ។

### ២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- បានទទួលប្រតិភូក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទឆ្នាំ២០២៣ និងបណ្តាឆ្នាំពាក់ព័ន្ធ

- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការ បណ្តុះបណ្តាល ខេត្តកោះកុង ស្តីពីវឌ្ឍនភាពការងារសម្រេចបានត្រីមាសទី១ និងលើកទិសដៅអនុវត្តបន្តត្រីមាសទី២ នៅសាលមហោស្រពខេត្ត
- បានចូលរួមកម្មវិធីស្តីពីការចុះពិនិត្យ ផ្ទៀងផ្ទាត់ វាយតម្លៃលើការរៀបចំ និងការគ្រប់គ្រងលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ(តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិ រដ្ឋប្រចាំឆ្នាំ២០២៣) នៅសាខាកាកបាទក្រហមកម្ពុជា ខេត្តកោះកុង
- បានចូលរួមកម្មវិធីស្តីពីការចុះពិនិត្យ ផ្ទៀងផ្ទាត់ វាយតម្លៃលើការរៀបចំ និងការគ្រប់គ្រងលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។

## ២.២.៨-ការងារធម្មការនិងសាសនា

- បានចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុគម្រប់៧១ យាងចូល៧២ព្រះវស្សា ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្ថិតនៅវត្តចន្ទមុនីរាម ភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- បានចូលរួមក្នុងពិធីសម្ពោធមហាដួង និងសមិទ្ធផលនានា នៅវត្តគិរីតេជោកូនកុក ស្ថិតនៅភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគិរីសាគរ
- បានចូលរួមពិធីបើកបវេសនកាលពុទ្ធិកបឋមសិក្សាឆ្នាំ២០២៤-២០២៥ នៅសាលាពុទ្ធិកបឋមសិក្សាវត្តចន្ទមុនីរាម ស្ថិតនៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ។

## ២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បានទទួល-បញ្ជូនបញ្ញើក្នុងប្រទេសចំនួន១៥.២៤៩ បញ្ញើស្មើនឹង២០.៣១៧,៣៧គ.ក្រ
- បានទទួល-បញ្ជូនបញ្ញើក្រៅប្រទេសចំនួន២៧២ បញ្ញើស្មើនឹង២៧៥.៦៣គ.ក្រ
- បានចុះពិនិត្យអាជីវកម្មរបស់ប្រតិបត្តិករប្រៃសណីយ៍ក្នុងការទទួល និងបញ្ជូនបញ្ញើគ្រប់ប្រភេទទាំងក្នុង និងក្រៅប្រទេស (គ្មានអ្វីគួរឱ្យសង្ស័យពាក់ព័ន្ធគ្រឿងញៀន)
- បានចុះពិនិត្យទីតាំងសាខាក្រុមហ៊ុន LODA ខេត្តកោះកុង និងបានណែនាំ ជំរុញឱ្យគាត់ស្នើសុំលិខិតអនុញ្ញាតពីមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត។ ជាលទ្ធផល សាខាក្រុមហ៊ុន LODA សុំពន្យារពេលធ្វើលិខិតអនុញ្ញាតច្បាប់បើកធ្វើសេវាអាជីវកម្មដល់ខែកក្កដា ឆ្នាំ២០២៤
- បានចុះត្រួតពិនិត្យសិក្សាទីតាំងសាងសង់ និងដំឡើងស្ថានីយបង្គោលអង់តែន ទូរស័ព្ទចល័ត និងបំពាក់ឧបករណ៍បច្ចេកទេសទូរគមនាគមន៍ ដើម្បីផ្តល់សេវាទូរស័ព្ទចល័ត និងសេវាអ៊ិនធឺណេតនៅស្ទឹងវាលថ្មកំបុត ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា និងទំនប់វារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាល ឃុំតាទៃលើ ស្រុកថ្មបាំង របស់ក្រុមហ៊ុនខ្មែរ អេឡិកទ្រីខល ផៅវ័រ (KEP)។ ជាលទ្ធផល តំណាងក្រុមហ៊ុនទូរស័ព្ទចល័តទាំង៣ក្រុមហ៊ុន នឹងពិភាក្សាជាមួយថ្នាក់ដឹកនាំ លើការឯកភាពគ្នាជ្រើសរើសយក៤ទីតាំង ដូចខាងក្រោម៖
    - ការដ្ឋានទំនប់វារីអគ្គិសនីស្ទឹងវាលថ្មកំបុត ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង មាន២ទីតាំង
        - ទីតាំងទី១ (Power House) ទីតាំងដែលមាននិយាមកា 11.732912-103.077702
        - ទីតាំងទី២ (Dam site) ទីតាំងដែលមាននិយាមកា 11.744526-103.122168
    - ការដ្ឋានទំនប់វារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាល ឃុំតាទៃលើ ស្រុកថ្មបាំង ខេត្តកោះកុង មាន២ទីតាំង
        - ទីតាំងទី១ (Power House)ទីតាំងដែលមាននិយាមកា 11.927743-103.220373
        - ទីតាំងទី២ (Dam site) ទីតាំងដែលមាននិយាមកា 11.908934-103.161723

- បានចុះត្រួតពិនិត្យទីតាំងស្នើសុំសាងសង់ស្ថានីយបង្គោលអង់តែនទូរស័ព្ទរបស់ក្រុមហ៊ុនអ៊ិដតខូ ស្ថិតនៅភូមិ៣ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ ជាលទ្ធផល ទីតាំងដីស្នើសុំមិនមានបញ្ហាអ្វីទេ តែក្រុមហ៊ុនត្រូវជូនដំណឹង និងចុះសាកសួរប្រជាពលរដ្ឋដែលរស់នៅជុំវិញទីតាំងដីនេះឱ្យមានការឯកភាពផងដែរ
- បានផ្សព្វផ្សាយ និងចែករំលែកបន្តផេកហ្វេសប៊ុករបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផេកហ្វេសប៊ុករបស់លោកជំទាវអភិបាល នៃគណៈអភិបាលខេត្តកោះកុង និងគេហទំព័រផ្សេងៗ តាមប្រព័ន្ធបណ្តាញសង្គម សរុបបានចំនួន៣២លើក។

## ២.២.១០-ការងារមុខងារសាធារណៈ:

- គិតត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ តាមតារាងទូទាត់ប្រាក់បៀវត្សប្រចាំខែឧសភា ឆ្នាំ២០២៤ មន្រ្តីរាជការស៊ីវិលនៅខេត្តកោះកុង មានចំនួន២.៧២៤នាក់ ស្រី១.០៣៩នាក់
    - ចំនួនរាយតាមប្រភេទក្របខ័ណ្ឌ៖
        - ក្របខ័ណ្ឌប្រភេទ "ក" ចំនួន៦១៦នាក់ ស្រ្តី១៦១ នាក់
        - ក្របខ័ណ្ឌប្រភេទ "ខ" ចំនួន១.០៣៣នាក់ ស្រ្តី៣៧១នាក់
        - ក្របខ័ណ្ឌប្រភេទ "គ" ចំនួន១.០៧៥នាក់ ស្រ្តី៥០៧នាក់
- បានត្រួតពិនិត្យទិដ្ឋាការលើសំណើសុំឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្រ្តីរាជការស៊ីវិលប្រចាំខែឧសភា ជូនមន្ទីរ អង្គភាពជុំវិញខេត្ត ដូចខាងក្រោម ៖

| ល.រ. | បរិយាយ | ដើមគ្រា | ក្នុងគ្រា(ខែនេះ) | បូកយោង | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ក្របខ័ណ្ឌថ្មី | ៨ | ៧៦ | ៨៤ | -មន្ទីរសេដ្ឋកិច្ច ២ករណី<br>-សាលាដំបូង ២ករណី<br>-មន្ទីរអប់រំយុវជន និងកីឡា ២៦ករណី<br>-រដ្ឋបាលស្រុកកោះកុង ១០ករណី<br>-រដ្ឋបាលស្រុកស្រែអំបិល ១៤ករណី<br>-រដ្ឋបាលស្រុកថ្មបាំង ៤ករណី<br>-រដ្ឋបាលស្រុកមណ្ឌលសីមា ២ករណី<br>-រដ្ឋបាស្រុកគិរីសាគរ ៥ករណី<br>-រដ្ឋបាលស្រុកបូទុមសាគរ ១១ករណី |
| ២ | តាំងស៊ប់ | ៣ | ០ | ៣ | |
| ៣ | ប្តូរប្រភេទក្របខ័ណ្ឌ | ០ | ០ | ០ | |
| ៤ | ឡើងថ្នាក់/និយ័តកម្មថ្នាក់ | ៥០ | ១ | ៥១ | |
| ៥ | តែងតាំង/ប្តូរប្រាក់មុខងារ | ៦៦ | ១ | ៦៧ | |
| ៦ | ឡើងឋានន្តរស័ក្តិ | ០ | ០ | | |
| ៧ | បញ្ចូលកូន | ៧៣ | ៦ | ៧៩ | |
| ៨ | បញ្ចូលប្រពន្ធ | ១៧ | ២ | ១៩ | |
| ៩ | ចូលនិវត្តន៍ | ៤ | ៥ | ៩ | -មន្ទីរបរិស្ថាន ១ករណី<br>-មន្ទីរសុខាភិបាល ២ករណី<br>-រដ្ឋបាលស្រុកកោះកុង ១ករណី<br>-រដ្ឋបាលក្រុងខេមរភូមិន្ទ ១ករណី |
| ១០ | ផ្ទេរចូល | ១៤ | ១ | ១៥ | -រដ្ឋបាលស្រុកគិរីសាគរ ១ករណី |

| | | | | | |
|---|---|---|---|---|---|
| ១១ | ផ្ទេរចេញ | ៤២ | ២ | ៤៤ | -មន្ទីរសុខាភិបាល ២ករណី |
| ១២ | នៅក្រៅក្របខ័ណ្ឌដើម | ១ | ០ | ១ | |
| ១៣ | ទំនេរគ្មានបៀវត្ស | ២ | ០ | ២ | |
| ១៤ | លុបឈ្មោះ | ៣ | ០ | ៣ | |
| ១៥ | ប្តូរកន្លែងការងារ | ៣ | ០ | ៣ | |
| ១៦ | តំបន់ដាច់ស្រយាល | ១៥ | ៤ | ១៩ | |
| ១៧ | ចូលបម្រើការងារវិញ | ២ | ០ | ២ | |
| ១៨ | រំលឹកប្រាក់ | ០ | ០ | ០ | |
| ១៩ | ថ្នាក់ពីរពេល | ០ | ០ | ០ | |
| ២០ | ថ្នាក់គួបពីរកម្រិត | ០ | ០ | ០ | |
| ២១ | ថ្នាក់គួបបីកម្រិត | ០ | ០ | ០ | |
| ២២ | បញ្ចូលប្រាក់មុខងារ | ១ | ០ | ១ | |
| ២៣ | លំហែមាតុភាព | ៥ | ៥ | ១០ | -សាលាដំបូង ៤ករណី<br>-រដ្ឋបាលស្រុកកោះកុង ១ករណី |
| ២៤ | ប្តូរប្រអប់ | ៤១៩ | ០ | ៤១៩ | |
| **សរុបរួម** | | **៧២៨** | **១០៣** | **៨៣១** | |

- បានត្រួតពិនិត្យ និងតាមដានលើការបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមប្រឹក្សា ការិយាល័យប្រជាពលរដ្ឋ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា លើកទី១ និងលើកទី២។

## ២.២.១១-ការងារផ្សេងៗ

### ២.២.១១.១-ការងារសាលាដំបូង

- **ផ្នែកចៅក្រមស៊ើបសួរ**
  - សំណុំរឿងសល់ពីមុន ចំនួន១០៦រឿង
  - សំណុំរឿងចូលថ្មី ចំនួន២៥រឿង
  - សំណុំរឿងចាត់ការរួច ចំនួន១០រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន១២១រឿង។
- **ផ្នែកចៅក្រមជំនុំជម្រះ**
  - សំណុំរឿងសល់ពីមុន ចំនួន៥៣រឿង
  - សំណុំរឿងចូលថ្មី ចំនួន២៣រឿង
  - សំណុំរឿងចាត់ការរួច ចំនួន២៩រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន៤៧រឿង។
- **ផ្នែកតុលាការរដ្ឋប្បវេណី**
  - សំណុំរឿងសល់ពីមុន ចំនួន៦២រឿង
  - សំណុំរឿងចូលថ្មី ចំនួន៣៩រឿង
  - សំណុំរឿងចាត់ការរួច ចំនួន២៩រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន៧២រឿង។

- **ការងារអេយ្យការអមសាលាដំបូង**
  - សំណុំរឿងសល់ពីមុន ចំនួន៣៧រឿង
  - សំណុំរឿងចូលថ្មី ចំនួន៣៩រឿង
  - សំណុំរឿងចាត់ការរួច ចំនួន៣៤រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន៤២រឿង។

## ២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

- បានទទួលកម្រៃសេវាសាធារណៈ (អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត) ដូចខាងក្រោម ៖
  - ការងារសំណង់ ទទួលបានកម្រៃសេវា ចំនួន៥.៣៥៨.០០០រៀល
    - ឯកសារចូលសរុប ចំនួន១ច្បាប់
    - ឯកសារចេញសរុប ចំនួន៣ច្បាប់
  - ការងារសុរិយោដី ទទួលបានកម្រៃសេវា ចំនួន៣៣.៩៨៦.៨៥០រៀល
    - ឯកសារចូលសរុប ចំនួន១៦៤ច្បាប់
    - ឯកសារចេញសរុប ចំនួន១៣៤ច្បាប់
- ការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ៖
  - ក្រុមទី១ បំពេញការងារនៅភូមិច្រកឫស្សី និងភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង
  - ក្រុមទី២ បំពេញការងារនៅភូមិតាចាត និងភូមិកោះចាក ឃុំទួលគគីរ ស្រុកមណ្ឌលសីមា
  - ក្រុមទី៣ បំពេញការងារនៅភូមិដីមាល ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ
  - ក្រុមទី៤ បំពេញការងារនៅភូមិត្រៀក និងភូមិត្រពាំង ឃុំស្រែអំបិល ស្រុកស្រែអំបិល
- ការងារចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ៖
  - ដីឯកជនចំនួន៤ក្បាលដី
- ការងារចុះបញ្ជីដីបន្ត ៖
  - អចលនវត្ថុចុះបញ្ជីជាប្រព័ន្ធ
    - ចុះបញ្ជីផ្ទេរសិទ្ធិបាន ចំនួន៨៤ក្បាលដី
    - ចុះបញ្ជីប្រាតិភោគបាន ចំនួន៥៤ក្បាលដី
- ក្រុមការងាររបស់មន្ទីរ នៅតែបន្តបំពេញការងារដូចខាងក្រោម៖
  - បានបំពេញទម្រង់បែបបទ ចំនួន៧១៥ក្បាលដី
  - បានគូសក្រាហ្វិក ចំនួន១៣៤ក្បាលដី
  - បានវាស់វែង ចំនួន១៨៧ក្បាលដី
  - បានបញ្ចូលទិន្នន័យ ចំនួន១២ក្បាលដី
  - បានចែកប័ណ្ណ ចំនួន៣ប័ណ្ណ
  - បានបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ចំនួន២ភូមិ នៅភូមិអណ្ដូងទឹក និងភូមិដីមាល ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ។

### ២.៣.២-ការងារបរិស្ថាន

- បានចាប់ឃាត់ឈើអារចំនួន២៣៤សន្លឹក (០.៤៩១០ម³) រណារយន្ត១៦គ្រឿង ទោចក្រយានយន្ត២គ្រឿង ធ្យូងបាវ១១បាវ រទេះ២គ្រឿង កាំភ្លើងកែច្នៃ១ដើម ម៉ាស៊ីនក្បាលបូមខ្សាច់១គ្រឿង អេស្កាវ៉ាទ័រ២គ្រឿង និងទុយោសម្រាប់បូមខ្សាច់ប្រវែង២០០ម៉ែត្រ
- បានរុះរើអន្ទាក់ចាប់សត្វព្រៃចំនួន៤៩៨ខ្សែ បង្គោលរបង៤៤១ដើម ខ្សែលួសបន្លា១.៧៦៨ម៉ែត្រ ដើមចេក៤៥ដើម និងខ្ទមចំនួន២
- បានបោះស្លាកសញ្ញាហាមកាប់រុករានដីព្រៃចំនួន៦ស្លាក
- បានពន្លត់ភ្លើងឆេះព្រៃចំនួន៣ករណី
- បានលែងសត្វព្រៃក្នុងព្រៃធម្មជាតិចំនួន១១ក្បាល
- បានពិនិត្យ និងបញ្ជាក់បច្ចេកទេសលើគម្រោងមូលនិធិឃុំចំនួន១គម្រោង (ពិនិត្យផលប៉ះពាល់ទៅលើតំបន់ការពារធម្មជាតិ) គឺគម្រោងសាងសង់ផ្លូវបេតុងអាមេ៣ខ្សែ នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានធ្វើកិច្ចសន្យាការពារបរិស្ថានលើអាជីវកម្មចំនួន៥ទីតាំង៖
    - អាជីវកម្មផ្ទះចិញ្ចឹមសត្វត្រចៀកកាំ នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ចំនួន១ទីតាំង
    - អាជីវកម្មផ្ទះចិញ្ចឹមសត្វត្រចៀកកាំ នៅឃុំទួលគគីរ ស្រុកមណ្ឌលសីមា ចំនួន២ទីតាំង
    - អាជីវកម្មខ្សាច់សំណង់ នៅឃុំតាទៃលើ ស្រុកថ្មបាំង ចំនួន២ទីតាំង
- បានចុះត្រួតពិនិត្យបញ្ហាការកកស្ទះសំរាមសំណល់រឹងនៅទីប្រជុំជន នៅតាមដងផ្លូវ និងទីសាធារណៈ នៅស្រុកមណ្ឌលសីមា។

### ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

- ការងារថែទាំប្រចាំឆ្នាំ២០២៤
    - ផ្លូវក្រាលកៅស៊ូលើផ្លូវជាតិ និងផ្លូវខេត្តចំនួន៦ខ្សែ ប្រវែងសរុប៧១,៦៩គីឡូម៉ែត្រ សម្រេចបាន៤៣,២៩%
    - ផ្លូវក្រាលដីល្បាយថ្មលើផ្លូវខេត្តចំនួន៣ខ្សែ ប្រវែងសរុប៧៧,១០គីឡូម៉ែត្រ សម្រេចបាន៤៣,២៩%
- ការងារថែទាំខួប ឆ្នាំ២០២៤
    - កំណាត់ផ្លូវជាតិលេខ៤៨-៥ ដោយក្រាលកៅស៊ូពីរជាន់(Reseal DBST)ប្រវែង៣.០០០ម ទទឹង១៦ម ទំហំ ៤៨.០០០ម² ចន្លោះគ.ម១៤+០០០-គ.ម១៧+០០០ ស្ថិតនៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ សម្រេចបាន៦៥,២១%
    - កំណាត់ផ្លូវជាតិលេខ៤៨ ដោយក្រាលកៅស៊ូពីរជាន់ (Reseal DBST) ប្រវែង២.០០០ម ទទឹង៧ម ទំហំ ១៤.០០០ម២ ចន្លោះគ.ម២+៧០០-គ.ម៤+៧០០ ស្ថិតនៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ សម្រេចបាន៦៥,២១%
- ការងារដឹកជញ្ជូនផ្លូវគោក៖
    - បានចុះបញ្ជីយានយន្តដឹកទំនិញធុនធំ ចំនួន១គ្រឿង
    - បានចុះបញ្ជីរថយន្តបែនធុនធ្ងន់ ចំនួន៥គ្រឿង
    - បានផ្ទេរកម្មសិទ្ធិក្នុងខេត្តប្រភេទទោលចក្រយាន្តយន្ត ចំនួន១គ្រឿង
    - បានផ្ទេរកម្មសិទ្ធិក្រៅខេត្តប្រភេទរថយន្តគ្រួសារ ចំនួន៣គ្រឿង
    - បានពន្យារសុពលភាពប័ណ្ណបើកបរ ប្រភេទ (ឃ២) ចំនួន១ប័ណ្ណ
    - ទុតិយតាប័ណ្ណប្រភេទ (ឃ២) ចំនួន១ប័ណ្ណ
    - ការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តចល័ត ចំនួន៣៩២គ្រឿង

- ការងារដឹកជញ្ជូនផ្លូវសមុទ្រ និងកំពង់ផែ៖
    - បានផ្តល់ប័ណ្ណសម្គាល់ដលយានយន្តទេសចរណ៍ ចំនួន១គ្រឿង
    - បានត្រួតពិនិត្យលក្ខណៈបច្ចេកទេសដលយានយន្តដឹកទំនិញ ចំនួន១គ្រឿង
    - បានត្រួតពិនិត្យលក្ខណៈបច្ចេកទេសដលយានយន្តនេសាទ ចំនួន៧១គ្រឿង
- ការងារសុវត្ថិភាពចរាចរណ៍៖
    - បានចុះត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស ចំនួន១លើក។
- **២.៣.៨-ការងារផ្សេងៗ**
- (ពុំមាន)។

**២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

**១.ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត ៖**

**ការពង្រឹងតួនាទី និងភារកិច្ច ៖** ការងារនេះថ្នាក់ដឹកនាំខេត្ត បានពង្រឹងតួនាទី និងភារកិច្ច តាំងពីថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក រហូតដល់ថ្នាក់មូលដ្ឋាន ពិសេសប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង សំដៅឆ្លុះបញ្ចាំងពីគុណភាព ប្រសិទ្ធភាព និងតម្លាភាព។ បន្ទាប់ពីបានអនុវត្តកន្លងមក ឃើញថា ប្រជាពលរដ្ឋមានការសប្បាយចិត្ត និងមានជំនឿទុកចិត្តកាន់តែច្រើនឡើង។

**២.សភាពការណ៍បទល្មើស និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍បទល្មើសព្រហ្មទណ្ឌ ៖** បទល្មើសព្រហ្មទណ្ឌកើតឡើង ចំនួន៨លើក ក្នុងនោះមាន៖

- បទល្មើសឧក្រិដ្ឋ ៖ ពុំមានអ្វីកត់សម្គាល់។
- បទល្មើសមជ្ឈិម ៖ កើតឡើង៨លើក
- ការខូចខាតបាត់បង់ ៖ បណ្តាលឱ្យរងរបួសស្រាល៣នាក់ ស្រី១នាក់។

**លទ្ធផលបង្ក្រាប ៖** បទល្មើសដែលបានកើតឡើងខាងលើ កម្លាំងមានសមត្ថកិច្ចបានបើកកិច្ចប្រតិបត្តិការយ៉ាងសកម្ម បង្ក្រាបបានចំនួន៨ករណី នៃបទល្មើសដែលបានកើតឡើង។ ឃាត់ខ្លួនជនសង្ស័យបានចំនួន១២នាក់ ស្រី១នាក់ ដកហូតវត្ថុតាង ម៉ូតូ១គ្រឿង និងសម្ភារមួយចំនួន និងបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**ខ. បទល្មើសគ្រឿងញៀន៖** បានធ្វើការបង្ក្រាបបទល្មើស រក្សាទុក ជួញដូរ និងប្រើប្រាស់នូវសារធាតុញៀនខុសច្បាប់ចំនួន៥ករណី ឃាត់ខ្លួនជនសង្ស័យបាន៩នាក់ ស្រី១នាក់។

- ដកហូតវត្ថុតាង៖ ថ្នាំញៀនប្រភេទ ICE=៣០,៦៣ក្រាម ម៉ូតូ១គ្រឿង ទូរស័ព្ទដៃ៦គ្រឿង និងឧបករណ៍ជក់ថ្នាំញៀនមួយចំនួន។ វត្ថុតាង និងមុខសញ្ញាជនសង្ស័យខាងលើ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**គ. ល្បែងស៊ីសងខុសច្បាប់ ៖** ពុំមានអ្វីកត់សម្គាល់។

**ឃ. បទល្មើសផ្សេងៗ ៖** ពុំមានអ្វីកត់សម្គាល់។

➢ *វិធានការបង្ការ ៖* កម្លាំងជំនាញនៅតាមបណ្តាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ចុះធ្វើការអប់រំណែនាំប្រជាពលរដ្ឋ ក្នុងតំបន់ណាដែលមានការសង្ស័យថាមានយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាម ឱ្យមានការប្រុងប្រយ័ត្ន ហើយបើបានប្រទះឃើញត្រូវរាយការណ៍ជូនកម្លាំងមានសមត្ថកិច្ច ដើម្បីមានវិធានការការពារ។

**៣. សភាពការណ៍សណ្តាប់ធ្នាប់ និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍គ្រោះថ្នាក់ចរាចរណ៍ ៖** ពុំមានអ្វីកត់សម្គាល់។

➢ *វិធានការបង្ការ ៖* បានបញ្ចុះកម្លាំងជំនាញសហការជាមួយកម្លាំងពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយអប់រំណែនាំដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទ នៅតាមទីប្រជុំជន តាមដងផ្លូវកែងសំខាន់ៗ និងចុះអប់រំអាជីវករលក់ដូរជុំវិញផ្សារលក់ដូរអមសងខាងផ្លូវឱ្យរៀបចំអីវ៉ាន់លក់ដូរឱ្យមានសណ្តាប់ធ្នាប់ល្អ សំដៅកាត់បន្ថយការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ដោយថាហេតុ។

**៤. បទល្មើសជួញដូរមនុស្ស ជួញដូរផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. បទល្មើសជួញដូរមនុស្ស និងជួញដូរផ្លូវភេទ ៖** ពុំមានអ្វីកត់សម្គាល់។

**ខ. អំពើហិង្សាក្នុងគ្រួសារ ៖** កើតឡើង៣លើក នៅក្រុងខេមរភូមិន្ទ ស្រុកបូទុមសាគរ និងស្រុកមណ្ឌលសីមា។ ជនសង្ស័យត្រូវបានឃាត់ខ្លួន និងបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តដើម្បីចាត់ការតាមនីតិវិធីច្បាប់បន្ត។

**គ. សកម្មភាពក្មេងទំនើង ៖** ពុំមានអ្វីកត់សម្គាល់។

*វិធានការការពារ៖* បានពង្រឹងកម្លាំងនៅថ្នាក់មូលដ្ឋាន ចុះល្បាតត្រួតពិនិត្យឃ្លាំមើលជាប្រចាំក្នុងមូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កឡើងដោយក្មេងទំនើង ឬជនទំនើង។

**៥. ការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ៖**

រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានខិតខំយកចិត្តទុកដាក់ពិនិត្យ សម្របសម្រួល និងដោះស្រាយជូនប្រជា-ពលរដ្ឋ និងមន្ត្រីរាជការ ដែលមានជម្លោះដីធ្លីនៅសេសសល់មួយចំនួនបន្តទៀត។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ៖**

ការងារនេះត្រូវបានពង្រឹងពីថ្នាក់ខេត្ត រហូតដល់ថ្នាក់មូលដ្ឋាន សំដៅគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិ បរិស្ថាន និងអនាម័យក្នុងភូមិ ឃុំ សង្កាត់ ប្រកបដោយប្រសិទ្ធភាព ពិសេសយើងបានអប់រំប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានាក្នុងការថែរក្សាបរិស្ថាន សុខភាព អនាម័យ និងសុវត្ថិភាពចំណីអាហារ ដើម្បីធ្វើឱ្យមូលដ្ឋានខេត្តទាំងមូលមានសោភ័ណភាពស្អាត រមណីយដ្ឋានល្អ ទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ មកកម្សាន្ត បានកាន់តែច្រើន។

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖**

**ក. សភាពការណ៍គ្រោះមហន្តរាយ ៖**

**១.ខ្យល់កន្ត្រាក់៖** កើតឡើង១លើក បណ្តាលឱ្យប៉ះពាល់ និងខូចខាតដល់ផ្ទះប្រជាពលរដ្ឋចំនួន១១ខ្នង ខូចខាតស័ង្កសីចំនួន៣០សន្លឹក និងហ្វីប្រូស៊ីម៉ង់តិ៍ចំនួន៧២សន្លឹក នៅក្រុងខេមរភូមិន្ទ។

**២.អគ្គិភ័យ៖** កើតឡើង១លើក បណ្តាលឱ្យខូចខាតទូទឹកកក១គ្រឿង កង្ហារ២គ្រឿង ស្រូវ និងសម្ភារប្រើប្រាស់មួយចំនួន។ មូលហេតុ បណ្តាលមកពីឆ្លងចរន្តអគ្គិសនី នៅស្រុកស្រែអំបិល។

**៣.រន្ទះបាញ់៖** កើតឡើង១លើក បណ្តាលឱ្យស្លាប់មនុស្សចំនួន២នាក់ប្រុស និងរបួសស្រាលចំនួន២នាក់ប្រុស នៅស្រុកគិរីសាគរ។

**ខ. ការឆ្លើយតប៖**

– សាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង និងអនុសាខាកាកបាទក្រហមកម្ពុជាក្រុងខេមរភូមិន្ទ បានចុះសួរសុខទុក្ខ និងផ្តល់អំណោយមនុស្សធម៌ ជួយដល់ជនរងគ្រោះដោយសារខ្យល់កន្ត្រាក់នៅក្រុងខេមរភូមិន្ទ។

**គ. ការត្រៀមបង្ការ៖**

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានត្រៀមលក្ខណៈជាប្រចាំ ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលមានគ្រោះមហន្តរាយកើតឡើង

– កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ បានចុះបំផុសអប់រំប្រជាពលរដ្ឋឱ្យមានការប្រុងប្រយ័ត្ន ចំពោះគ្រោះថ្នាក់អគ្គិភ័យ និងខ្យល់កន្ត្រាក់តាមរយៈវេទិកាផ្សព្វផ្សាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពក្នុងមូលដ្ឋាន។

**ឃ. ឆ្លើយតបរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖** បានត្រៀមសម្ភារ បរិក្ខារ និងកម្លាំងសមត្ថកិច្ច សហការជាមួយជំនាញ ក្នុងការចុះអន្តរាគមន៍ជួយសង្គ្រោះបន្ទាន់ ករណីមានការរីករាលដាលជំងឺឆ្លងកាចសាហាវណាមួយ។

## ២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍

– **សភាពការណ៍សន្តិសុខនៅតាមព្រំដែន ៖** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨២៧ ដើរល្បាតម្ចាស់ការចំនួន៥៧លើក និងល្បាតសហការជាមួយកងយោធពលខេមរភូមិន្ទ៥លើក (ក្នុង១លើកៗ មានកម្លាំងពី៦នាក់ទៅ១២នាក់) ប្រដាប់ដោយអាវុធគ្រប់ដៃ ជាពិសេសបានដាក់កម្លាំងតាមគោលដៅសំខាន់ៗចំនួន ១៣ចំណុចៗ

– **សកម្មភាពសហគមន៍-ពលរដ្ឋតវ៉ាផ្សេងៗ ៖** កើតឡើងចំនួន៣លើក

- សកម្មជនតវ៉ាដីធ្លី (ក្រុម១២៩+៨៤៣គ្រួសារ) ចំនួន២៣នាក់ ស្រី១៦នាក់ បានប្រមូលផ្តុំគ្នាប្រជុំនៅស្ថិតក្នុងភូមិកណ្តោល ឃុំកណ្តោល ស្រុកបូទុមសាគរ គោលបំណងផ្សព្វផ្សាយអំពីការចូលប្រជុំរបស់លោក ថេង សាវឿន និងសហការីនៃសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា CCFC នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ ដែលបានចូលរួមប្រជុំជាមួយ ឯកឧត្តម សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើករណីទំនាស់ដីធ្លី និងដំណោះស្រាយ យកមកផ្សព្វផ្សាយបន្ត ជូនដល់សមាជិករបស់ខ្លួន
- ប្រជាពលរដ្ឋ ចំនួន១៦នាក់ ស្រី៨នាក់ មធ្យោបាយធ្វើដំណើរដោយរថយន្តសាំយ៉ុង១គ្រឿង មកពីឃុំជីខលើ ស្រុកស្រែអំបិល បានមកប្រមូលផ្តុំនៅមុខសាលាដំបូង ដើម្បីគាំទ្រអ្នកតំណាងរបស់ពួកគាត់ចំនួន៣នាក់ប្រុស ដែលតុលាការ កោះហៅ អំពីបញ្ហាដីធ្លី។ លទ្ធផលតុលាការសម្រេចឱ្យតំណាងពួកគាត់ទាំង៣នាក់ ត្រឡប់ទៅមូលដ្ឋានវិញ រង់ចាំដីកាកោះហៅលើកទី២
- ប្រជាពលរដ្ឋតវ៉ាដីធ្លី(ក្រុម១៩៧+៩៥៥គ្រួសារ) ចំនួន៨៦នាក់ ស្រី៦២នាក់ តាមរថយន្តសាំយ៉ុង៥គ្រឿង មកពី៣ឃុំ(ជីខលើ-ជីខក្រោម-ដងពែង)ស្រុកស្រែអំបិល បានឡើងមកតាមដីកាកោះហៅរបស់សាលាដំបូងខេត្ត គោលបំណង គាំទ្រតំណាងរបស់ពួកគាត់ ដែលសាលាដំបូងកោះហៅឱ្យចូលមកសវនាការ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ ដែលត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ប្រព្រឹត្តនៅចំណុចចំណោតអូរជ្រៅ ស្ថិតនៅភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល។ ក្នុងនោះដែរ មានអង្គការសង្គមស៊ីវិលចូលរួមឃ្លាំមើលចំនួន២ (អង្គការលីកាដូ និងអង្គការអាដហុក)។

– **សកម្មភាពគណបក្សនយោបាយ ៖** មានគណបក្សនយោបាយចំនួន២ គឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សឆន្ទៈខ្មែរ បានធ្វើសកម្មភាពឃោសនាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក អាណត្តិទី៤ ឆ្នាំ២០២៤ ប្រព្រឹត្តទៅដោយរលូន។

– **សកម្មភាពអង្គការ-សមាគម និងគ្រឹះស្ថានអប់រំ ៖** កើតឡើងចំនួន៤លើក

- ក្រុមការងារអង្គការម្លប់ឫស្សី ចំនួន៤នាក់ បានចុះមកចំណុចផ្ទះឈ្មោះ អ៊ិន ធូ ស្ថិតក្នុងភូមិតានី ឃុំជីខលើ ស្រុកស្រែអំបិល ដើម្បីធ្វើសមាហរណកម្មយុវជនទៅរស់នៅជួបជុំគ្រួសារសាច់ញាតិក្នុងសហគមន៍ ដែលបច្ចុប្បន្នយុវជនកំពុងស្ថិតនៅក្នុងមជ្ឈមណ្ឌលបុរីបាត់ដំបង២ នៃខេត្តបាត់ដំបង
- ក្រុមការងារអង្គការ Save the children ចំនួន៥នាក់ ស្រី១នាក់ ជនជាតិញ៉ូសាឡែន១នាក់ស្រី បានចុះពិភាក្សាការងារជាមួយលោកអភិបាលស្រុកកោះកុង លោកមេឃុំជ្រោយប្រស់ និងមេឃុំត្រពាំងរូង ក្នុងការអនុវត្តគម្រោងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ នៅសាលប្រជុំនៅសាលាស្រុកកោះកុង និងបន្តចុះជួបសំណេះសំណាលពិភាក្សាការងារ ជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅសាលាបឋមសិក្សាវត្តត្រពាំងរូង
- ក្រុមការងារអង្គការ CBN Cambodia ចំនួន៣នាក់ ស្រី២នាក់ បាននាំយកអំណោយរបស់អង្គការ មានកំព្យូទ័រ ១គ្រឿង និងម៉ាស៊ីនព្រីន១គ្រឿង ប្រគល់ជូនសាលាបឋមសិក្សាកោះស្រឡៅ ស្ថិតនៅភូមិកោះស្រឡៅ ឃុំកោះកាពិ ស្រុកកោះកុង មានអ្នកចូលរួម១៣នាក់ ស្រី៥នាក់
- ក្រុមការងារអង្គការរុក្ខជាតិ និងសត្វព្រៃអន្តរជាតិ ចំនួន៦នាក់ ស្រី៥នាក់ បាននាំយកសម្ភារចិញ្ចឹមមាន់ ចែកជូនប្រជាពលរដ្ឋក្រុមចិញ្ចឹមមាន់ចំនួន១៥គ្រួសារ ក្នុងសហគមន៍ការពារធនធានធម្មជាតិកោះស្រឡៅ ស្ថិតក្នុងភូមិកោះស្រឡៅ ឃុំកោះកាពិ ស្រុកកោះកុង មានអ្នកចូលរួម២៧នាក់ ស្រី១២នាក់។

– **សកម្មភាពសហគមន៍ ពលរដ្ឋ និងសាសនា ៖** មានក្រុមសាសនាយេស៊ូគ្រីស្ទចំនួន២នាក់ ស្រី១នាក់ បានចុះផ្សព្វផ្សាយវិស័យសាសនាព្រះយេស៊ូគ្រីស្ទ និងបានចែកនំ ចំណីដល់ក្មេងៗ និងមនុស្សចាស់ នៅភូមិតានី ឃុំភ្នំមាស ស្រុកគិរីសាគរ ចំនួន២លើក។

តារាងទី២៣៖ការគ្រប់គ្រងសន្តិសុខ សណ្ដាប់ធ្នាប់ និងចរាចរណ៍

| ល.រ. | បរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | គ្រោះថ្នាក់ចរាចរណ៍ | ២ | ០ | ២ |
| ២ | គ្រោះថ្នាក់ផ្សេងៗ | ៩ | ៣ | ១២ |
| ៣ | បទល្មើសគ្រឿងញៀន | ២២ | ៥ | ២៧ |
| ៤ | បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ | ០ | ០ | ០ |
| ៥ | បទល្មើសសេដ្ឋកិច្ច | ០ | ០ | ០ |
| ៦ | ល្បែងស៊ីសង | ១ | ០ | ១ |
| ៧ | ក្មេងទំនើង | ១ | ០ | ១ |
| ៨ | បទល្មើសផ្សេងៗ | ០ | ០ | ០ |

២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត

– **ការគ្រប់គ្រងតាមកំពង់ផែសមុទ្រ (តាមច្រកកំពង់ផែសមុទ្រស្រែអំបិល និងប៉ាក់ខ្លង) ៖**
  - នាវិកកម្ពុជាចូលចំនួន១៧២នាក់ ស្រី០០នាក់ ស្មើនឹងជលយានយន្ត១០គ្រឿង
  - នាវិកកម្ពុជាចេញចំនួន១៧២នាក់ ស្រី០០នាក់ ស្មើនឹងជលយានយន្ត១០គ្រឿង។

– **ការគ្រប់គ្រង ការស្នាក់នៅរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ៖**
  - ជនបរទេសស្នាក់នៅរយៈពេលខ្លី សរុបចំនួន៥៩២នាក់ ស្រី២១៤នាក់ មាន២៩សញ្ជាតិ
  - ជនបរទេសស្នាក់នៅរយៈពេលវែង សរុបចំនួន២.៥១៦នាក់ ស្រី៦៧៥នាក់ មាន៣៦សញ្ជាតិ។

– **ការគ្រប់គ្រងប្រព័ន្ធវត្តមានជនបរទេស (FPCS) ៖** ពុំមាន។

– **ការងារអធិការកិច្ចហត្ថពលកម្មបរទេស៖** ពុំមាន។

– **ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត ៖**
  - ការិយាល័យគ្រប់គ្រងជនបរទេស បានទទួលពាក្យស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ពីជនបរទេសអន្តោប្រវេសន្ត សរុបចំនួន២២គ្រួសារ ស្មើនឹង៣៨នាក់ ស្រី២១នាក់ សញ្ជាតិវៀតណាម
    - ជនបរទេសអន្តោប្រវេសន្តស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី២ សរុបចំនួន៦គ្រួសារ មនុស្សរួមចំនួន១០នាក់ ស្រី៧នាក់
    - ជនបរទេសអន្តោប្រវេសន្តស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី៣ សរុបចំនួន១៦គ្រួសារ មនុស្សរួមចំនួន២៨នាក់ ស្រី១៤នាក់
    - មានជនអន្តោប្រវេសស្លាប់ចំនួន១នាក់ ភេទប្រុស សញ្ជាតិអាឡឺម៉ង់ មូលហេតុចាស់ជរា និងមានជំងឺស្ទួតប្រចាំកាយ ស្ថិតនៅភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។

– **ជនបរទេសរងគ្រោះដោយបទល្មើសផ្សេងៗ៖** ពុំមាន។

– **ជនបរទេសល្មើសច្បាប់អន្តោប្រវេសន៍ ៖** កម្លាំងជំនាញការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី បានបញ្ជូនជនបរទេសចំនួន៣នាក់ ស្រី១នាក់ ពីបទលួចឆ្លងដែន និងស្នាក់នៅធ្វើការងារដោយខុសច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា ទៅស្នាក់ការគ្រៀមបណ្ដេញចេញនៅរាជធានីភ្នំពេញ។

– **ជនបរទេសបង្កបទល្មើសផ្សេងៗ៖** ពុំមាន។

– **ជនបរទេសប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ៖** ពុំមាន។
– **ជនបរទេសប្រព្រឹត្តិបទល្មើសផ្សេងៗ ៖** ពុំមាន។
– **ជនបរទេសរងគ្រោះដោយឧបទ្ទវហេតុផ្សេងៗ៖** មានករណីគ្រោះថ្នាក់រថយន្ត១ករណី បង្កឡើងដោយខ្លួនឯង ស្ថិតនៅភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង។
– **កិច្ចប្រតិបត្តិការ ៖** បានជួយសង្គ្រោះជនបរទេស៨លើក សរុបចំនួន៩នាក់ ស្រី២នាក់ ក្នុងនោះ ជនជាតិចិនចំនួន៧នាក់ ជនជាតិវៀតណាមចំនួន២នាក់ តាមពាក្យបណ្តឹងលេខ៣៥៤, ១៤១០, ១៤០០, ១៣៩៧, ១៤៤៥, ១៤៦៧, ១៤៨៨ និង៤០៩ ប្រភពហ្វេសប៊ុកផេកក្រសួងមហាផ្ទៃ និងHotline ជនបរទេស។ ជនបរទេសខាងលើ ត្រូវបានកម្លាំងផែនការងារសន្តិសុខ នៃស្នងការដ្ឋាននគរបាលខេត្ត កសាងសំណុំរឿងបញ្ជូនទៅនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម និងនាយកដ្ឋានចារកម្ម នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីបន្តនីតិវិធី ។

## ២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ

– បានអប់រំមន្ត្រីឱ្យយល់ដឹងពីច្បាប់ ក្រមសីលធម៌ បទវិន័យរបស់មន្ត្រីពន្ធនាគារ ចំនួន១លើក
– បានអប់រំជនជាប់ឃុំឱ្យយល់ដឹងពីក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាល ចំនួន៣លើក
– បានបង្រៀនថ្នាក់អក្ខរកម្មដល់ទណ្ឌិត ចំនួន១៥នាក់បុរស (គ្រូបង្គោលជាមន្ត្រីពន្ធនាគារ) ក្រោមការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ រយៈពេល៨ខែ
– បានបណ្តុះបណ្តាលជនជាប់ឃុំឱ្យមានជំនាញកាត់សក់ ដេរប៉ាក់ ជាងឈើ ជាងសំណង់ ជាងជួសជុលរថយន្ត និងដេរលេបក្តាម ជារៀងរាល់ថ្ងៃ
– បានលើកគោលការណ៍ពិនិត្យ ណែនាំដល់មន្ត្រីពន្ធនាគារ ពិសេសការអនុវត្តកម្មវិធីគ្រប់គ្រងពន្ធនាគារ និងការផ្គត់ផ្គង់ជីវភាព សេវាថែទាំសុខភាពរបស់ជនជាប់ឃុំ និងអនាម័យក្នុងពន្ធនាគារចំនួន៤លើក
– បានទទួលក្រុមគ្រូពេទ្យអង្គការលើកាដូមកពិនិត្យព្យាបាល និងផ្តល់ឱសថដល់ជនជាប់ឃុំ១លើក
– បានទទួលអង្គការលើកាដូចុះមកផ្តល់ប្រឹក្សាច្បាប់ដល់ជនជាប់ឃុំចំនួន៣នាក់ ចំនួន១លើក
– បានអង្គការលើកាដូមកចែកអំណោយដល់ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនតាមម្តាយ(១លើក)
– គិតត្រឹមថ្ងៃទី១០/៥/២០២៤ ជនជាប់ឃុំជាក់ស្តែងមានចំនួន៥៨៣នាក់ ស្ត្រី៤៦នាក់ ក្នុងនោះមាន៖
  - ជនត្រូវចោទ ចំនួន៩៦នាក់ ស្ត្រី១១នាក់
  - ជនជាប់ចោទ ចំនួន៧២នាក់ ស្ត្រី៨នាក់
  - ពិរុទ្ធជន ចំនួន១៤០នាក់ ស្ត្រី១៥នាក់
  - ទណ្ឌិត ចំនួន២៧៥នាក់ ស្ត្រី១២នាក់

ក្នុងនោះមាន៖

- ជនជាតិបរទេស មានចំនួន១១នាក់ ស្ត្រី៣នាក់ (វៀតណាមចំនួន៥នាក់ ស្ត្រី២នាក់ ថៃ២នាក់ ចិន២នាក់ ម៉ាឡេស៊ី២នាក់ ស្ត្រី១នាក់)
- អនីតិជនចំនួន៣៧នាក់ ស្ត្រី២នាក់
- កូនតាមម្តាយចំនួន៣នាក់ កុមារី១នាក់
- ស្ត្រីមានគភ៌មានចំនួន២នាក់

– ជនជាប់ឃុំត្រូវបានចាប់ចូលថ្មីមានចំនួន២៩នាក់ ស្ត្រី៤នាក់
– ជនជាប់ឃុំត្រូវបានដោះលែងមានចំនួន២៥នាក់ ស្ត្រី១នាក់។

## ២.៤.៥-ការងារផ្សេងៗ

– (ពុំមាន)។

## ផ្នែកទី៣÷បញ្ហាប្រឈម និងសំណើដោះស្រាយ

| ល.រ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដោះស្រាយ |
|---|---|---|
| ១ | ការផ្តល់សេវាវិស័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី នៅមានភាពយឺតយ៉ាវ | រៀបចំកិច្ចប្រជុំពិភាក្សារកដំណោះស្រាយជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត |
| ២ | រដ្ឋបាលក្រុង ស្រុក ពុំទាន់បានបំពាក់ឧបករណ៍ និងសម្ភារ ក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ សម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋ | លើកគម្រោងចំណាយទិញឧបករណ៍ និងសម្ភារ ក្នុងការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ និងកៀរគរសប្បុរសជន |
| ៣ | ការផ្តល់សេវាវិស័យសាធារណការ និងដឹកជញ្ជូន ទម្រង់បែបបទមិនទាន់បន្សុីគ្នាក្នុងស្តង់ដារតែមួយ | ស្នើសុំក្រសួងមហាផ្ទៃ និងក្រសួងសាធារណការ និងដឹកជញ្ជូន រៀបចំឱ្យមានប្រព័ន្ធស្តង់ដារតែមួយ |
| ៤ | ក្រុមហ៊ុនមួយចំនួន ទទួលបានសិទ្ធិសម្បទានដីពីរាជរដ្ឋាភិបាល ដើម្បីវិនិយោគ ហើយមានទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ | -ស្នើឱ្យក្រុមហ៊ុនបន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀតជូនប្រជាពលរដ្ឋ<br>-ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយទៅតាមលិខិតបទដ្ឋានគតិយុត្ត |
| ៥ | ដំណើរការផ្តល់កម្មសិទ្ធិដីធ្លីជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋដែលរស់នៅកាន់កាប់អាស្រ័យផលជាក់ស្តែងលើដីសារពើភណ្ឌរបស់រដ្ឋ នៅមានភាពយឺតយ៉ាវ | សហការជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយតាមនីតិវិធី |
| ៦ | ជំនាញផ្នែកសារព័ត៌មាន ជំនាញបច្ចេកទេសវិទ្យុ និងទូរទស្សន៍របស់មន្ត្រីមួយចំនួននៅក្នុងមន្ទីរព័ត៌មានខេត្ត នៅមានកម្រិត | ស្នើសុំក្រសួងព័ត៌មាន បើកវគ្គបណ្តុះបណ្តាលអំពីជំនាញផ្នែកសារព័ត៌មាន ជំនាញបច្ចេកទេសវិទ្យុ និងទូរទស្សន៍ |
| ៧ | ដីចម្ការឈើអាកាស្យាស្ថិតនៅភូមិ១ សង្កាត់ស្មាច់មាន-ជ័យ ក្រុងខេមរភូមិន្ទ នៅតែមានការរំលោភទន្ទ្រានកាន់កាប់ ពីសំណាក់ប្រជាពលរដ្ឋដោយខុសច្បាប់ | ស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់នីតិវិធីក្នុងការដោះស្រាយ |
| ៨ | គ្រឹះស្ថានសិក្សាមួយចំនួន នាយក នាយិកាមិនសូវយកចិត្តទុកដាក់លើម៉ោងបង្ហាត់អប់រំកាយ-កីឡាដល់សិស្សានុសិស្សឱ្យបានទៀងទាត់ | ណែនាំបន្ថែមឱ្យគាត់យល់ដឹងពីសារៈសំខាន់នៃអប់រំកាយ និងកីឡា |

## ផ្នែកទី៤÷ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅខែបន្ទាប់

### ៤.១-រដ្ឋបាលខេត្ត

#### ៤.១.១-ការងាររដ្ឋបាល

- ត្រៀមរៀបចំកិច្ចប្រជុំសាមញ្ញលើកទី៦១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំកិច្ចប្រជុំគណៈអភិបាលប្រចាំខែ និងប្រចាំអឌ្ឍមាស
- រៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំខែ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្ត
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬ ខូចខាតដោយយថាហេតុ តាមរយៈការស្នើសុំរបស់សាមីខ្លួន

- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈរដ្ឋបាលឃុំ សង្កាត់
- បញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ (www.cdepart.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋ។

### ៤.១.២-ការងារផែនការ និងវិនិយោគ

- ចុះសិក្សាគម្រោង រៀបចំប្លង់ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោងអភិវឌ្ឍន៍មូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៤
- ចុះត្រួតពិនិត្យ និងវាយតម្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៣
- រៀបចំសេចក្តីព្រាងគម្រោងអាទិភាពដោយប្រើប្រាស់ថវិកាខេត្ត ឆ្នាំ២០២៥។

### ៤.១.៣-ការគ្រប់គ្រងធនធានមនុស្ស

- ត្រៀមរៀបចំពិធីប្រកាសទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក
- បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម នៅតាមបណ្តាក្រុង ស្រុក
- បន្តធ្វើប័ណ្ណសម្គាល់ខ្លួនជូនក្រុមប្រឹក្សាឃុំ ដែលនៅសល់ចំនួន៤ស្រុក រួមមាន ស្រុកកោះកុង ស្រុកបូទុមសាគរ ស្រុកគិរីសាគរ និងស្រុកស្រែអំបិល។

### ៤.១.៤-ការងារអន្តរវិស័យ

- បន្តសហការជាមួយក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីនៅសេសសល់ជូនប្រជាពលរដ្ឋ
- ជំរុញដំណើរការផ្តល់កម្មសិទ្ធិដីធ្លីជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋដែលរស់នៅកាន់កាប់អាស្រ័យផលជាក់ស្តែងលើដីសារពើភណ្ឌរបស់រដ្ឋ
- បន្តសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល សមាគម និងសហគមន៍មូលដ្ឋាននានា ដែលមានប្រតិបត្តិការក្នុងភូមិសាស្ត្រខេត្ត
- បន្តសហការជាមួយមន្ទីរជំនាញ និងអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យទីតាំងស្នើសុំបើកអាជីវកម្ម សិប្បកម្ម និងដំឡើងប៉ាណូនានា
- បន្តជំរុញការរៀបចំទីលានទុកដាក់សំរាមនៅតាមបណ្តាស្រុក
- បន្តសហការ ជាមួយរដ្ឋបាលក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចុះរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងធ្វើតេស្តហ៊ើសរកសារធាតុញៀនតាមទឹកមូត្រដល់ថ្នាក់ដឹកនាំ មន្ត្រី និងមន្ត្រីជាប់កិច្ចសន្យា នៃរដ្ឋបាលក្រុង ស្រុក។

### ៤.១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ

- បន្តផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យកាន់តែល្អប្រសើរ
- បន្តតាមដាន និងជួយគាំទ្រលើការផ្តល់សេវាប័ណ្ណព្រំដែនកម្ពុជា-ថៃ នៅក្រុង ស្រុក
- បន្តជំរុញ និងផ្តល់សេវាផ្នែកជលយានជូនប្រជានេសាទនៅក្រុង ស្រុក គោលដៅទាំង៦ តាមផែនការកំណត់
- បន្តជូនដំណឹងផ្សព្វផ្សាយការបង់កម្រៃតាមប្រព័ន្ធធនាគារ (Payment Hub) ជូនប្រជាពលរដ្ឋ
- បន្តផ្សព្វផ្សាយនូវលិខិតបទដ្ឋានគតិយុត្តថ្មីៗ ដល់មន្ត្រីក្នុងអង្គភាព។

### ៤.១.៦-ការងារការិយាល័យប្រជាពលរដ្ឋ

- ប្រចាំការនៅគុពិសេស ក្នុងអង្គភាពច្រកចេញចូលតែមួយចំនួន១២ម៉ោង ក្នុង១សប្តាហ៍
- ចុះបើកប្រអប់សំបុត្រការិយាល័យប្រជាពលរដ្ឋខេត្ត នៅតាមមុខមន្ទីរមួយចំនួន និងក្រុង ស្រុក ឃុំ សង្កាត់

- ត្រៀមទទួលពាក្យបណ្តឹង និងព័ត៌មានផ្សេងៗ តាមមធ្យោបាយទាំង៤ (១.ជួបផ្ទាល់ ២.ប្រអប់សំបុត្រ ៣.ប្រព័ន្ធតេឡេក្រាម និង៤.តាមទូរស័ព្ទ)
- ចាត់វិធានការដោះស្រាយបណ្តឹងក្នុងសមត្ថកិច្ចឱ្យបានឆាប់បំផុត ដើម្បីបង្កើនទំនុកចិត្តជូនប្រជាពលរដ្ឋ
- រៀបចំកិច្ចប្រជុំប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៤ ដើម្បីត្រួតពិនិត្យវឌ្ឍនភាពការងារ។

## ៤.១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- បន្តពិនិត្យ និងផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ជូនដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់
- បន្តសហការរៀបចំពាក្យបណ្តឹងឱ្យរដ្ឋបាលខេត្ត និងបំពេញតួនាទីជាមេធាវីតំណាង និងការពារផលប្រយោជន៍ស្របច្បាប់ជូនរដ្ឋបាលខេត្ត។

## ៤.១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

- សហការទប់ស្កាត់នូវរាល់អំពើរត់គេចពន្ធតាមច្រកទ្វារ ដូចជា ទំនិញគ្រប់ប្រភេទ ឬការជួញដូរមនុស្សឆ្លងដែន ជួញដូរគ្រឿងញៀន អាវុធជាតិផ្ទុះ និងវត្ថុបុរាណផ្សេងៗ
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធរវាងប្រទេសជិតខាង ដោយឈរលើគោលជំហរ គោរពបូរណភាពទឹកដី នៃប្រទេសទាំងពីរ ក្នុងតំបន់ព្រំដែន
- បន្តពង្រឹងការយាមល្បាតការពារគ្រប់គោលដៅ ដើម្បីរក្សាសុវត្ថិភាពក្នុងភូមិសាស្ត្រ ឱ្យបានល្អប្រសើរ
- បន្តពង្រឹងការអនុវត្តជាប្រចាំ នូវការងារសន្តិសុខ សណ្តាប់ធ្នាប់ និងថែរក្សាអនាម័យបរិស្ថាន
- បន្តត្រួតពិនិត្យលិខិតស្នាម មនុស្ស មធ្យោបាយ ទំនិញចេញចូល និងទប់ស្កាត់បទល្មើសជ្រៀតចូលដោយខុសច្បាប់។

## ៤.១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ

- រៀបចំអាណត្តិបើកបៀវត្សប្រចាំខែមិថុនា ឆ្នាំ២០២៤
- ត្រៀមរៀបចំទូទាត់ប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

## ៤.១.១០-ការងារលទ្ធកម្ម

- ត្រៀមរៀបចំឯកសារជូនដំណឹងដេញថ្លៃលទ្ធកម្មសំណង់ ឆ្នាំ២០២៤។

## ៤.១.១១-ការងារសុខាភិបាល

- បន្តផ្តល់សេវាពិនិត្យ ពិគ្រោះព្យាបាលជំងឺ និងពង្រឹងការថែទាំ ព្យាបាលជំងឺដោយការយកចិត្តទុកដាក់នៅគ្រប់មូលដ្ឋានសុខាភិបាល
- បន្តចុះអប់រំផ្សព្វផ្សាយអំពីវិធានការទប់ស្កាត់ការព្យាបាល ការបង្ការជំងឺឆ្លង និងជំងឺមិនឆ្លងតាមកម្មវិធីជាយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល
- បន្តអនុវត្តតាមគោលការណ៍យុទ្ធសាស្ត្រថ្មីរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលដែលបានដាក់ចេញថ្មីៗ
- បន្តចុះអភិបាលកិច្ចការងារសុខាភិបាលតាមកម្មវិធី នៅតាមមូលដ្ឋានសុខាភិបាលតាមផែនការគ្រោងទុក
- បន្តផ្តល់កិច្ចសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាលក្នុងខេត្ត
- ប្រជុំក្រុមការងារបច្ចេកទេសសុខាភិបាល (Pro.TWGH) ដែលមានអង្គការដៃគូចូលរួម
- បន្តអប់រំ ផ្សព្វផ្សាយអំពីវិធីការពារការចម្លងមេរោគអេដស៍ ធ្វើតេស្តដើម្បីស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងពង្រឹងការព្យាបាលប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តផ្តល់សេវាជូនដល់ស្ត្រីមានផ្ទៃពោះឱ្យមកពិនិត្យផ្ទៃពោះមុន-ក្រោយសម្រាល និងមកសម្រាលកូន នៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យ
- ផ្តល់សេវាផ្តល់ថ្នាំបង្ការ១១មុខដល់កុមារ និងផ្តល់ថ្នាំបង្ការជំងឺតេតាណូសដល់ស្ត្រីមានផ្ទៃពោះ នៅតាមមណ្ឌលសុខភាព

- បន្តផ្តល់សេវាពន្យារកំណើតនៅតាមមណ្ឌលសុខភាព
- បន្តចាត់ក្រុមការងារចត្តាឡីស័កប្រចាំការនៅទីស្នាក់ការច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម ដើម្បីពិនិត្យកម្តៅលើអ្នកធ្វើដំណើរ អ្នកបើកបរថយន្តចេញចូលច្រកព្រំដែនជារៀងរាល់ថ្ងៃ ព្រមទាំងបាញ់ថ្នាំសម្លាប់មេរោគទៅលើរថយន្តដឹកទំនិញចេញ-ចូល
- បន្តអប់រំសុខភាព ស្តីពីវិធានការការពារជំងឺគ្រុនឈាមតាមរយៈបុគ្គលិកសុខាភិបាល នៅពេលប្រជាពលរដ្ឋមកទទួលសេវានៅមូលដ្ឋាន និងសិស្សានុសិស្សនៅតាមសាលារៀន។

### ៤.១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល

- បន្តចុះសួរសុខទុក្ខប្រជាពលរដ្ឋ ដើម្បីឈ្វេងយល់អំពីកង្វល់នានា នៅក្នុងមូលដ្ឋាន
- បន្តខិតខំដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើង នៅតាមបណ្តាក្រុង ស្រុក ឃុំ សង្កាត់។

### ៤.១.១៣-ការងារផ្សេងៗ

- (ពុំមាន)។

## ៤.២-មន្ទីរ និងអង្គភាពជំនាញ

## ៤.២.១-ផ្នែកសេដ្ឋកិច្ច

### ៤.២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះតាមដាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មតាមបណ្តាក្រុង/ស្រុក ពិសេសបច្ចេកទេសដាំដុះដំណាំ និងចិញ្ចឹមសត្វដោយប្រើប្រាស់ទឹកតិច
- ត្រៀមអន្តរាគមន៍ពីការបំផ្លាញរបស់សត្វល្អិតចង្រៃ និងជំងឺលើដំណាំតាមបណ្តាក្រុង/ស្រុក
- ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ ចលនាដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វ ក្នុងភូមិសាស្ត្រខេត្តកោះកុង
- តាមដានត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វនៅតាមបណ្តាក្រុង ស្រុក
- បន្តតាមដានត្រួតពិនិត្យទីតាំងអាជីវកម្ម ការចរាចរណ៍ជី និងថ្នាំកសិកម្មក្នុងខេត្ត
- ចុះអង្កេតតាមដាន និងពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលកំពុងដំណើរការ
- ចុះតាមដានវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្ត
- បន្តសហការជាមួយក្រុមការងារថ្នាក់ខេត្ត ចុះផ្សព្វផ្សាយ និងផ្តល់សេវាចុះបញ្ជីជលយាន និងការផ្តល់លិខិតអនុញ្ញាត ឱ្យធ្វើអាជីវកម្មនេសាទ នៅតាមមូលដ្ឋាននានាក្នុងខេត្ត
- សហការជាមួយគម្រោងជលផលសមុទ្រ និងតំបន់ឆ្នេរប្រកបដោយចីរភាព(SCMF) ចុះប្រជុំផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្នុងការដាក់ពង្រាយសំណង់សិប្បនិម្មិត ជាមួយសហគមន៍នេសាទនានាទូទាំងខេត្ត
- បន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងកម្លាំងល្បាតរបស់សហគមន៍ ដើម្បីទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃឱ្យបានទាន់ពេលវេលា
- បន្តចុះតាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ករណីរំលោភទន្រ្ទានកាន់កាប់ សាងសង់ផ្ទះពីសំណាក់ប្រជាពលរដ្ឋនៅលើដីចម្ការឈើអាកាស្យា ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។

### ៤.២.១.២-ការងារធនធានទឹក និងឧតុនិយម

- បន្តពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្ពង់ ស្ថិតនៅភូមិខ្ពង់ ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្តោល ស្ថិតនៅភូមិធ្នង់ និងភូមិកណ្តោល ឃុំកណ្តោល ស្រុកបូទុមសាគរ
- ពង្រឹងការងារប្រមូលទិន្នន័យឧតុនិយម នៅតាមបណ្តាស្រុកដែលមានស្ថានីយឧតុនិយមឱ្យកាន់តែឆាប់រហ័ស និងសុក្រឹតដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម

- ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃកណ្តាល ក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- ជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃតាំកន់ ក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- ស្តារប្រឡាយរំដោះទឹកជំនន់តាមបណ្តោយទំនប់ការពារទឹកប្រៃជីត្រេះ ក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ។

### ៤.២.១.៣-ការងារអភិវឌ្ឍជនបទ

- បន្តចុះធ្វើបច្ចុប្បន្នភាពផ្លូវ និងសំណង់សិល្បការ្យ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ តាមបណ្តាឃុំ ស្រុក
- បន្តចុះស្រង់ទិន្នន័យសារពើភណ្ឌផ្លូវជនបទ និងរាប់ចរាចរណ៍យានយន្តផ្លូវតាមបណ្តាឃុំ និងស្រុក
- បន្តចុះធ្វើបច្ចុប្បន្នភាព អណ្តូងលូ អណ្តូងស្នប់ ស្រះទឹក និងប្រព័ន្ធចែកចាយទឹកសហគមន៍ នៅក្នុងឃុំ ស្រុក។

### ៤.២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍

- ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ដែបាញ់ប្រេង ទំនិញផលិត ទំនិញវេចខ្ចប់ និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ជូនម្ចាស់ស្ថានីយ និងម្ចាស់សហគ្រាស/សិប្បកម្ម នៅស្រុកបូទុមសាគរ
- ជំរុញម្ចាស់សហគ្រាស/សិប្បកម្ម ឱ្យយកសំណាកផលិតផល ទៅវិភាគគុណភាព នៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- ពង្រឹងការអនុវត្តយន្តការច្រកចេញចូលតែមួយរបស់មន្ទីរលើការផ្តល់សេវាសាធារណៈជូនម្ចាស់សហគ្រាស/សិប្បកម្ម ដូចជា៖
    - សេចក្តីសម្រេចបង្កើតសហគ្រាស/សិប្បកម្ម
    - វិញ្ញាបនបត្រថ្មី និងបន្ត
    - សហគ្រាស/សិប្បកម្ម បិទទ្វារ និងព្យួរ
    - សហគ្រាស/សិប្បកម្មពង្រីកមុខផលិតផលថ្មី ឬពង្រីកដើមទុន ប្តូរទីតាំង ឬ ប្តូរម្ចាស់។

### ៤.២.១.៥-ការងាររ៉ែ និងថាមពល

- បន្តផ្សព្វផ្សាយដល់អាជីវករឱ្យយល់ដឹងអំពីច្បាប់ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែ (ខ្សាច់ និងកាយយកអាចម៍ដី)
- បន្តផ្សព្វផ្សាយសារាចរ និងសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ជូនដល់អាជីវករពាក់ព័ន្ធក្នុងខេត្ត
- ជំរុញ និងគាំទ្រដល់ក្រុមហ៊ុនផលិត ផ្គត់ផ្គង់ និងចែកចាយថាមពលអគ្គិសនី ទាំងអស់ឱ្យបន្តពង្រីកបណ្តាញជូនប្រជាពលរដ្ឋ ដើម្បីប្រើប្រាស់
- តាមដាន និងត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញអគ្គិសនី ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ទាំងគុណភាព ប្រសិទ្ធភាព និងសោភណ្ឌភាពនៅទីប្រជុំជន ក្នុងក្រុងខេមរភូមិន្ទ ដើម្បីចៀសវាងកើតឧបទ្ទវហេតុផ្សេងៗ
- បន្តខិតខំកៀរគរចំណូលសួយសារធនធានរ៉ែ ដើម្បីបង់ចូលថវិការដ្ឋ
- បន្តជំរុញការចេញអាជ្ញាប័ណ្ណខ្សាច់បកជូនអាជីវករ (រាំ ចាន់នី)។

### ៤.២.១.៦-ការងារពាណិជ្ជកម្ម

- បន្តផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងបំពេញប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បន្តតាមដានស្តីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ចំនួន១១៩មុខប្រចាំថ្ងៃ
- បន្តតាមដានការផ្គត់ផ្គង់ តម្រូវការ និងតម្លៃទំនិញប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ រៀងរាល់២ដងក្នុងមួយសប្តាហ៍

- បន្តចុះពិនិត្យតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ និងដេប៉ូលក់ប្រេងឥន្ធនៈក្នុងក្រុង ស្រុកទូទាំងខេត្ត
- ចុះសិក្សាផលិតផលសក្តានុពលនៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង
- ត្រៀមចូលរួមរៀបចំវេទិកាផ្គូផ្គងរវាងអ្នកលក់ និងអ្នកទិញ ក្រោមគម្រោងអភិវឌ្ឍអាជីវកម្ម និងការទទួលបានទីផ្សារសម្រាប់អ្នកផលិតក្នុងស្រុក និងM/SMEs និងនាំចេញនៅនឹងកន្លែង
- បន្តចូលរួមសហការជាមួយសាខាការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ដើម្បីចុះត្រួតពិនិត្យគុណភាពទំនិញ និងសុវត្ថិភាពម្ហូបអាហារ
- សហការជាមួយសភាពាណិជ្ជកម្មខេត្តក្នុងការអភិវឌ្ឍន៍ពាណិជ្ជកម្ម
- បន្តតាមដានស្ថានភាពលក់ដូរប្រកបរបរប្រចាំថ្ងៃនៅតាមច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម។

### ៤.២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ

#### ៤.២.១.៧.១-ការងារហិរញ្ញវត្ថុ

- ពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ពង្រឹងការត្រួតពិនិត្យចំណូល ចំណាយតាមបណ្តាអង្គភាព ក្រុង និងស្រុក ឱ្យបានត្រឹមត្រូវ
- ត្រៀមបណ្តុះបណ្តាលមន្ត្រីហិរញ្ញវត្ថុតាមបណ្តាអង្គភាពអនុវត្តថវិកានូវនីតិវិធីអនុវត្តថវិកា និងកិច្ចលទ្ធកម្មសាធារណៈ
- ពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈ
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ជាបន្តបន្ទាប់
- ជំរុញរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធ្វើបញ្ជីសារពើភណ្ឌ (ទាំងដីមានកម្មសិទ្ធិ និងដីបម្រុងរដ្ឋ)។

#### ៤.២.១.៧.២-ការងារពន្ធដារ

- បន្តកៀរគរចំណូលពន្ធ ដើម្បីសម្រេចបានតាមផែនការចំណូលពន្ធសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ របស់សាខាពន្ធដារខេត្តកោះកុង ដែលបានកំណត់ដោយលិខិតលេខ៨៤0 អពដ ចុះថ្ងៃទី0៥ ខែមករា ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានពន្ធដារ និងបន្តអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ។

#### ៤.២.១.៧.៣-ការងារគយ និងរដ្ឋាករ

- បន្តពង្រឹងការងារគ្រប់គ្រងការប្រមូលពន្ធឱ្យបានតាមផែនការកំណត់ និងពង្រឹងការអនុវត្តវិមជ្ឈការតម្លៃឱ្យបានល្អ
- បន្តជំរុញឱ្យមានការជម្រះបញ្ជីប្រាក់កក់លើស្រឡាង និងម៉ាស៊ីនបូមខ្សាច់ដែលនាំចូលដោយក្រុមហ៊ុន LYP Group Co.,Ltd តាំងពីឆ្នាំ២០០៨ តាមរបបប្រវេសន៍កាលិក
- បន្តធ្វើប្រតិបត្តិការបង្ក្រាបរថយន្តចង្កូតឆ្វេង និងចង្កូតស្តាំ ដែលគ្មានពន្ធ
- បន្តបង្កើនប្រសិទ្ធភាពការងារបង្ការ បង្ក្រាបអំពើរត់គេចពន្ធ និងបន្លំពន្ធ ជាពិសេសតាមរយៈការអនុវត្តឱ្យបានហ្មត់ចត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវបទបញ្ជាលេខ ០១បប ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បន្តពង្រឹងប្រសិទ្ធភាពនៃការបំពេញបែបបទបញ្ចេញទំនិញពីគយ ជាមួយក្រុមអន្តរាគមន៍ពិសេស និងក្រុមអនុលោមភាព ដើម្បីចូលរួមប្រសិទ្ធភាពការងារនៅតាមការិយាល័យមាត់ច្រកក្រោមឱវាទ និងបន្តកែលម្អ និងខិតខំប្រមូលចំណូលពីក្រុមទំនិញចម្រុះបន្ថែមឱ្យអស់តាមសក្តានុពលជាក់ស្តែង
- បន្តសម្របសម្រួល ពាណិជ្ជកម្មអន្តរជាតិឱ្យបានសមស្របតាមបទប្បញ្ញត្តិជាធរមាន និងចាត់វិធានការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនចេញ និងចូលឱ្យកាន់តែសុក្រឹត
- បន្តជំរុញសកម្មភាពគ្រប់គ្រងផលនេសាទនាំចេញនាំចូលឱ្យមកបង់ពន្ធតាមនីតិវិធីគយ

- បន្តពង្រឹងអភិបាលកិច្ច គុណភាពសេវារបស់អង្គភាពគយ និងរដ្ឋាករ និងបន្តបំពេញការងារ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពទាំងការងាររដ្ឋបាល និងការងារប្រតិបត្តិការគយ ពិសេសកែសម្រួលកម្លាំង ដើម្បីបំពេញភារកិច្ចមានការទទួខុសត្រូវច្បាស់លាស់តាមទង្វានគយ និងរដ្ឋាករ។

### ៤.២.១.៨-ការងារទេសចរណ៍

- បន្តផ្សព្វផ្សាយអំពីសក្តានុពល និងគោលដៅទេសចរណ៍ទាក់ទាញសំខាន់ៗក្នុងខេត្តដល់ភ្ញៀវទេសចរ
- ចុះសម្ភាសន៍កម្រងសំណួរ ស្តីពី "ការសិក្សាកម្លាំងពលកម្ម និងការបណ្តុះបណ្តាលក្នុងមូលដ្ឋានអាជីវកម្មទេសចរណ៍" និងផ្សព្វផ្សាយពីប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ដល់អាជីវកម្មទេសចរណ៍ក្នុងស្រុកថ្មបាំង

### ៤.២.១.៩-ការងារផែនការ

- បន្តចុះប្រមូលទិន្នន័យសន្ទស្សន៍ថ្លៃទំនិញនៅផ្សារស្រែអំបិល ស្រុកស្រែអំបិល និងផ្សារដងទង់ ក្រុងខេមរភូមិន្ទ
- បន្តធ្វើបច្ចុប្បន្នភាពគ្រួសារក្រីក្រ និងផលិតប័ណ្ណសមធម៌ជូនគ្រួសារក្រីក្រ នៅតាមបណ្តាភូមិ ឃុំ សង្កាត់
- បន្តចុះអនុវត្តការកំណត់អត្តសញ្ញាណគ្រួសារងាយរងហានិភ័យ និងជំរុញបុគ្គលបម្រើការងារក្នុងវិស័យសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យស្នើសុំដាក់ពាក្យសម្ភាសកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។

### ៤.២.១.១០-ការងារផ្សេងៗ

#### ៤.២.១.១០.១-ការងារសាខាធនាគារជាតិនៃកម្ពុជា

- បន្តផ្តល់សេវាបើក និងបង់ប្រាក់ជូនអតិថិជន
- បន្តប្តូរប្រាក់ចាស់ ទក់ រហែក ជូនអតិថិជន
- បន្តស្រាល់ជ្រើសក្រដាសប្រាក់ចាស់ ទក់ រហែក។

#### ៤.២.១.១០.២-ការងាររតនាគារ

- បន្តអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធFMIS នូវជំហានបន្តបន្ទាប់ទៀត
- បន្តពង្រឹងការកត់ត្រាចំណូល ចំណាយ តាមប្រព័ន្ធFMIS ឱ្យកាន់តែប្រសើរ
- បន្តការអនុវត្តតាមសារាចរលេខ ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្សរៀងរាល់២សប្តាហ៍ម្តង ក្នុងខែនីមួយៗ
- បន្តពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល(FMIS Portal)ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ឱ្យបានកាន់តែប្រសើរ
- បន្តពិនិត្យផ្ទៀងផ្ទាត់ និងធ្វើរបាយការណ៍ចំណូល ចំណាយ និងតារាងតុល្យភាពឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

#### ៤.២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត

- បន្តរៀបចំខ្លឹមសារ និងកម្មវិធីអប់រំ ផ្សព្វផ្សាយដល់អាជីវករ ពាណិជ្ជករ និងបណ្តាក្រុមហ៊ុននានា អំពីច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ
- បន្តរៀបចំ និងដំណើរការអនុវត្តកម្មវិធីចុះអង្កេតទំនិញ តាមទីផ្សារនានា នៅខេត្តកោះកុង
- បន្តកសាង វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីហានិភ័យមុខទំនិញដែលចរាចរលើទីផ្សារ
- បន្តបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រី អំពីច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធ និងអនុវត្តនីតិវិធី
- បន្តចុះអប់រំផ្សព្វផ្សាយស្តីពីសុវត្ថិភាពម្ហូបអាហារដល់អាជីវករ និងសិស្សានុសិស្ស ក្នុងស្រុកបូទុមសាគរ និងក្រុងខេមរភូមិន្ទ។

### ៤.២.២-ផ្នែកសង្គមកិច្ច

#### ៤.២.២.១-ការងារអប់រំ យុវជន និងកីឡា

- បន្តចុះពិនិត្យតាមដាន និងណែនាំលើការងារបច្ចេកទេសផ្សេងៗរបស់ការិយាល័យជំនាញនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នៅតាមគ្រឹះស្ថានសិក្សា
- បន្តពង្រឹងបង្ហាត់ដល់ក្រុមកីឡាករបាល់ទាត់ បុរស នារី អាយុក្រោម១៥ឆ្នាំ ត្រៀមចូលរួមប្រកួតនៅថ្នាក់ជាតិ
- ត្រៀមដឹកនាំក្រុមយុវជន ធ្វើការងារសិក្សាស្រាវជ្រាវផែនការយុវជនជជែកដេញដោល ដើម្បីចូលរួមកម្មវិធីការប្រកួតប្រជែងសម្រាប់ឆ្នាំ២០២៤។

#### ៤.២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បន្តកិច្ចសហការជាមួយមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត និងអាជ្ញាធរឃុំ សង្កាត់ ចុះដោះស្រាយបញ្ហានានាលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- បន្តដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងការអនុវត្តកម្មវិធីជំនួយសង្គមដែលកើតមានឡើងនៅតាមឃុំ/សង្កាត់ ឱ្យបានទាន់ពេលវេលា
- បន្តសម្របសម្រួល និងជួយគាំទ្រដល់មន្ត្រីកម្មវិធីនៅឃុំ/សង្កាត់ ទៅលើការអនុវត្តកម្មវិធីជាតិជំនួយសង្គម ក្នុងកញ្ចប់គ្រួសារ ឱ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹងកិច្ចសហការជាមួយមន្ត្រីពាក់ព័ន្ធមានដូចជាៈ អ្នកទទួលបន្ទុកកម្មវិធី (TVET) នៅវិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង និងមន្ត្រីទទួលបន្ទុកកម្មវិធីនៅឃុំ/សង្កាត់ ក្នុងដំណើរការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងងាយរងហានិភ័យ
- បន្តសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រះសីហនុ និងអង្គការម្លប់តាប៉ាង ដើម្បីស្នើសុំម្តាយរបស់កុមារសមាហរណកម្មចំនួន៧នាក់ ស្រី១នាក់ ដែលស្នាក់នៅមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កែវផុស ខេត្តព្រះសីហនុ ឱ្យគាត់បានមករស់នៅជុំកូនៗ នៅក្នុងសហគមន៍វិញ ស្ថិតនៅភូមិ២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។

#### ៤.២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងរបបសន្តិសុខសង្គម

##### ៤.២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បន្តជំរុញដល់នាយកសហគ្រាស/គ្រឹះស្ថាន ដែលប្រើប្រាស់កម្មករ និយោជិតខ្មែរ និងបរទេសមុនចូលបម្រើការងារ និងកំពុងបម្រើការងារឱ្យមកធ្វើសៀវភៅ និងប័ណ្ណការងារឱ្យស្របតាមនីតិវិធី
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងលក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង
- បន្តពង្រឹងយន្តការដោះស្រាយវិវាទការងាររួម និងវិវាទបុគ្គល
- បន្តពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារតាមបណ្តាសហគ្រាស/គ្រឹះស្ថានក្នុងខេត្ត
- បន្តពង្រឹងប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈរបស់មន្ទីរ
- បន្តពង្រឹងភាពសុខដុមរមនា នៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត។

##### ៤.២.២.៣.២-ការងាររបបសន្តិសុខសង្គម

- បន្តផ្សព្វផ្សាយគោលនយោបាយសន្តិសុខសង្គម ដល់ស្ថាប័នពាក់ព័ន្ធ ទាំងវិស័យសាធារណៈ និងឯកជន
- បន្តស្រាវជ្រាវ និងចុះបញ្ជិកាសហគ្រាសថ្មីៗ។

### ៤.២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- បន្តតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ចេញពីសំពៅលិច និងវត្ថុដែលមាននៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ខេត្តកោះកុង
- បន្តពង្រឹងការគ្រប់គ្រង ថែរក្សា និងការពារស្ថានីយ ចេតិយ និងបូជនីយដ្ឋានប្រវត្តិសាស្ត្រនានា ក្នុងភូមិសាស្ត្រខេត្តកោះកុង
- បន្តចុះត្រួតពិនិត្យ និងកំណត់និយាមកាស្ថានីយទើបរកឃើញថ្មី ស្ថិតនៅភូមិប្រកបឫស្សី ឃុំជំនាប់ ស្រុកថ្មបាំង។

### ៤.២.២.៥-ការងារព័ត៌មាន

- ជំរុញការផ្សព្វផ្សាយផ្នែកឯកជននានាឱ្យគោរពច្បាប់ និងបទដ្ឋានបច្ចេកទេសវិស័យព័ត៌មាន
- បន្តផ្សព្វផ្សាយសេចក្ដីជូនដំណឹង ស្ដីពីការដាក់ពាក្យស្នើសុំបើក និងបន្តសុពលភាពអាជ្ញាប័ណ្ណ វិស័យព័ត៌មានជូនដល់ម្ចាស់អាជីវកម្ម សេវាកម្មនៅក្នុងខេត្តកោះកុងទាំងអស់ដែលពុំទាន់មានអាជ្ញាប័ណ្ណ និងអាជ្ញាប័ណ្ណផុតសុពលភាព ត្រូវមកស្នើសុំអាជ្ញាប័ណ្ណរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ និងទាន់ពេលវេលា
- ជំរុញការចុះយកព័ត៌មានតាមរយៈថតវីដេអូ និងបង្កើនទំនាក់ទំនងតាមបណ្ដាក្រុង ស្រុកដើម្បីទទួលបានព័ត៌មាន
- ស្រាវជ្រាវលើបច្ចេកវិទ្យា និងកម្មវិធីថ្មីៗស្របតាមកាលៈទេសៈសង្គម
- បង្កើនការផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ ទូរទស្សន៍បាយ័ន និងទូរទស្សន៍ផ្សេងៗទៀត
- បង្កើនការផ្សព្វផ្សាយព័ត៌មានតាមបណ្ដាញសង្គម ឱ្យកាន់តែទូលំទូលាយជាងមុន
- បង្កើនការយកចិត្តទុកដាក់កែលម្អកម្មវិធីផ្សាយរបស់វិទ្យុផ្សាយសំឡេង
- បន្តផ្សព្វផ្សាយព័ត៌មាន ស្ប៉ុតអប់រំផ្សេងៗ ពិសេសស្ប៉ុតស្ដីពីជំងឺកូវីដ-១៩
- បន្តផ្សព្វផ្សាយរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំជាតិ និងខេត្តឱ្យកាន់តែទូលំទូលាយ។

### ៤.២.២.៦-ការងារកិច្ចការនារី

- រៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីការលើកកម្ពស់សុខភាពអាហារូបត្ថម្ភសម្រាប់ស្ត្រី និងក្មេងស្រី ដល់ប្រជាពលរដ្ឋនៅស្រុកថ្មបាំង
- ចុះពិនិត្យ និងតាមដានពីការកែច្នៃ ចង្អេរ កញ្ចើ និងកន្ត្រក ដែលធ្វើពីឬស្សី របស់ស្ត្រីនៅឃុំដងពែង ស្រុកស្រែអំបិល។

### ៤.២.២.៧-ការងារទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- បន្តសហការជាមួយមន្ទីរជំនាញចុះតាមដានការអនុវត្តច្បាប់ របស់រាជរដ្ឋាភិបាលនៅតាមក្រុង ស្រុក ទូទាំងខេត្តកោះកុង
- បន្តទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋ និងមជ្ឈដ្ឋាននានា ដើម្បីពិនិត្យដោះស្រាយតាមនីតិវិធី
- បន្តសម្របសម្រួល និងទំនាក់ទំនងរាល់ការងាររវាងអាជ្ញាធរខេត្ត និងទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តកោះកុង។

### ៤.២.២.៨-ការងារធម្មការនិងសាសនា

- ត្រៀមសហការជាមួយសាលាគណទាំងពីរគណៈ និងរដ្ឋបាលខេត្តកោះកុង រៀបចំពិធីបុណ្យចម្រើនព្រះជន្មសម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជ មាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយសាលាគណទាំងពីរគណៈ និងរដ្ឋបាលខេត្តកោះកុង ដើម្បីត្រៀមទទួល គ្រឿងឧបភោគបរិភោគដែលជាសទ្ធាជ្រះថ្លា របស់មហាពុទ្ធបរិស័ទ មកប្រគេនក្នុងពិធីបុណ្យចូលព្រះវស្សា ព.ស.២៥៦៨ គ.ស. ២០២៤ សម្រាប់វត្តទូទាំងខេត្តកោះកុង។

### ៤.២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បន្តសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ទីរអង្គភាពនានាជុំវិញខេត្ត និងបណ្តាក្រុមហ៊ុនបម្រើសេវាទូរគមនាគមន៍ ប្រតិបត្តិករប្រៃសណីយ៍កម្ពុជា និងទូរគមនាគមន៍កម្ពុជា ដើម្បីអនុវត្តការងារឱ្យបានស្របតាមនីតិវិធី
- ចុះត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងគោលនយោបាយលើការប្រើប្រាស់ការធ្វើសេវាលើវិស័យប្រៃសណីយ៍ វិស័យទូរគមនាគមន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានគ្រប់ប្រភេទនៅក្នុងខេត្ត។

### ៤.២.២.១០-ការងារមុខងារសាធារណ:

- បន្តត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណើសុំទូទាត់ប្រាក់បៀវត្សប្រចាំខែ របស់មន្ត្រីរាជការស៊ីវិល នៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តពិនិត្យផ្ទៀងផ្ទាត់ រៀបចំរបាយការណ៍ និងបែងចែកតារាងបៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តត្រួតពិនិត្យ ផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុកជុំវិញខេត្តឱ្យបានត្រឹមត្រូវ
- បន្តផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការ និងបន្តត្រួតពិនិត្យ តាមដាន និងជំរុញការបង្វែរប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលបើកមិនប្រក្រតីចូលថវិកាវិញ។

### ៤.២.២.១១-ការងារផ្សេងៗ

#### ៤.២.២.១១.១-ការងារសាលាដំបូង

- បន្តយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌស៊ើបសួរដែលនៅសល់ឱ្យបានសម្រេចពី៣០%ទៅ៥០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច
- បន្តយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះដែលនៅសល់ឱ្យបានសម្រេចពី៥០%ទៅ៨០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច
- បន្តយកចិត្តទុកដាក់ចាត់ការលើសំណុំរឿងរដ្ឋប្បវេណីជំនុំជម្រះដែលនៅសល់ឱ្យបានសម្រេចពី៣០%ទៅ៥០% នៃសំណុំរឿងដែលពុំទាន់ចាត់ការរួច។

## ២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

- បន្តពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ និងប្រមូលចំណូលជូនរដ្ឋ
- បន្តអនុវត្តការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ
- បន្តពង្រឹង និងយកចិត្តទុកដាក់ការងារគ្រប់គ្រងសំណង់
- បន្តចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ។

### ២.៣.២-ការងារបរិស្ថាន

- បន្តចុះល្បាតទប់ស្កាត់បង្ក្រាបរាល់បទល្មើស ក្នុងតំបន់ការពារធម្មជាតិ
- បន្តចុះផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋកុំឱ្យទន្ទ្រានព្រៃយកដីធ្វើកម្មសិទ្ធិ ការបរបាញ់ និងការចាប់សត្វព្រៃក្នុងតំបន់ការពារធម្មជាតិ
- បន្តចុះពង្រឹងការធ្វើកិច្ចសន្យាការពារបរិស្ថាន និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញដល់ម្ចាស់សិប្បកម្ម និងអាជីវកម្មផ្សេងៗ
- រៀបចំប្រារព្ធទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា។

### ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

- បន្តអនុវត្តការងារថែទាំជាប្រចាំ ជួសជុលផ្លូវសំបុកមាន់ និងស្រោចកៅស៊ូលើស្នាមប្រេះសម្រាប់ឆ្នាំ២០២៤
- បន្តអនុវត្តគម្រោងថែទាំខួបផ្លូវជាតិលេខ៤៨ និងផ្លូវខេត្តលេខ១៤៨៥A
- បន្តចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យយានយន្តគ្រប់ប្រភេទដែលធ្វើចរាចរណ៍តាមដងផ្លូវសាធារណៈឱ្យគោរពច្បាប់ចរាចរណ៍ ពិសេសឱ្យអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មី និងរឹតបន្តឹងគ្រប់អ្នកបើកបររថយន្តទាំងអស់ត្រូវមានប័ណ្ណបើកបរ និងផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក តាមសាលារៀន ទីប្រជុំជន និងស្រង់ស្ថិតិយានដ្ឋានក្នុងក្រុង ស្រុកទូទាំងខេត្ត
- បន្តការត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេសពីច្បាប់កំណត់ រថយន្តដឹកជញ្ជូន រថយន្តដឹកដី និងខ្សាច់ ដែលអាចបង្កគ្រោះថ្នាក់ចរាចរណ៍។

### ២.៣.៤-ការងារផ្សេងៗ

- (ពុំមាន)។

## ២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

### ២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

- បន្តផ្សព្វផ្សាយគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" លេខ ០១ គ.ន.ប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២១ របស់រាជរដ្ឋាភិបាលឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ គ្រប់ភូមិ ឃុំ សង្កាត់ និងបណ្តាអង្គការសង្គមស៊ីវិលទូទាំងខេត្ត
- បន្តរៀបចំកសាងផែនការ និងកម្មវិធីការងារប្រចាំខែសម្រាប់ចុះអនុវត្តគោលនយោបាយនៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ដែលក្រុមនីមួយៗទទួលខុសត្រូវ
- បន្តបង្កើនកម្មវិធីធ្វើវេទិកាសាធារណៈឱ្យបានគ្រប់ភូមិ ឃុំ សង្កាត់ ទូទាំងខេត្ត ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមយោបល់ដោះស្រាយបញ្ហាផ្សេងៗ ដែលបានកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន និងទិតៀនកែលម្អរាល់សកម្មភាពអសកម្មរបស់សមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានដែលមានកន្លងមក សំដៅបង្កើនសកម្មភាពអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែមានប្រសិទ្ធភាព
- បន្តដឹកនាំអនុវត្តឱ្យបានទៀងទាត់នូវរបបប្រជុំប្រចាំខែដើម្បីត្រួតពិនិត្យលទ្ធផលកិច្ចប្រតិបត្តិការ និងដាក់ចេញផែនការវិធានការ អនុវត្តជាក់ស្តែងក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន
- បន្តយកចិត្តទុកដាក់ចាត់តាំងអនុវត្តនូវបណ្តាវិធានការស្តីពីការលុបបំបាត់បទល្មើស និងគ្រោះថ្នាក់សង្គម ពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិទាំង៧យ៉ាង នៃគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យមានប្រសិទ្ធភាពខ្ពស់
- បន្តជំរុញចលនាប្រឡងប្រណាំងបង្កើតស្នាដៃនៅតាមភូមិ ឃុំ សង្កាត់ ឱ្យបានផុលផុសក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" សម្រាប់ទទួលការសរសើរ និងជូនរង្វាន់ប្រចាំឆ្នាំនីមួយៗ។

### ២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍

- បន្តស្រាវជ្រាវក្តាប់សភាពការណ៍ ឧបាយកលរបស់បណ្តាភាគីអមិត្ត និងចលនាប្រឆាំងផ្សេងៗចំពោះរាជរដ្ឋាភិបាល ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងការងារត្រួតពិនិត្យវត្តមានជនបរទេសឆ្លងកាត់ និងស្នាក់នៅក្នុងខេត្តដើម្បីទប់ស្កាត់ការលួចជ្រៀតចូលរបស់ក្រុមភេរវជន
- បន្តក្តាប់សភាពការណ៍បាតុកម្ម កូដកម្ម និងអំពើភេរវកម្មផ្សេងៗ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា

- បន្តក្តាប់រាល់សភាពការណ៍ បទល្មើសព្រហ្មទណ្ឌទូទាំងខេត្ត និងធ្វើការវិភាគវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ចេញនូវវិធានការបង្ការ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព
- បន្តជំរុញវិធានការ និងបង្ក្រាបក្រុមក្មេងទំនើងនៅទូទាំងខេត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងកាត់បន្ថយបទល្មើសក្នុងសង្គម
- បន្តពង្រឹងបំប៉នជំនាញដល់មន្ត្រីនគរបាលយុត្តិធម៌គ្រប់លំដាប់ថ្នាក់ ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព
- បន្តសហការជាមួយអាជ្ញាធរដែនដី ដើម្បីបំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមប្រឆាំងទប់ស្កាត់បទល្មើសគ្រឿងញៀន
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយភ្នាក់ងារប្រឆាំងគ្រឿងញៀនភាគីថៃ ដើម្បីដកបទពិសោធន៍ និងផ្តល់ព័ត៌មានជូនគ្នាទៅវិញទៅមក សំដៅធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងដែនឱ្យមានប្រសិទ្ធភាព
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី ដើម្បីអប់រំឱ្យស៊ីជម្រៅដល់ប្រជាពលរដ្ឋ សំដៅកាត់បន្ថយនូវអត្រាគ្រោះថ្នាក់ចរាចរណ៍ និងមានវិធានការផាកពិន័យតាមច្បាប់កំណត់
- បន្តពង្រឹងការគ្រប់គ្រងបណ្តាគោលដៅដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច ដូចជា សណ្ឋាគារ ផ្ទះសំណាក់។ល។ ដោយធ្វើកិច្ចសន្យា និងតាមដានកុំឱ្យគោលដៅទាំងនោះ ក្លាយជាកន្លែងប្រព្រឹត្តបទល្មើស
- បន្តចុះស្រង់ទិន្នន័យ និងស្រាវជ្រាវប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់។

## ២.៤.៣-ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត

- បន្តទទួលពាក្យស្នើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង ចំពោះអ្នកគ្រប់អាយុ និងស្នើសុំបន្តសុពលភាពប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី១ តាមនីតិវិធី
- បន្តរៀបចំបញ្ជីទទឹងជនបរទេសអន្តោប្រវេសន្ត ដែលមិនមកបន្តសុពលភាពប័ណ្ណស្នាក់នៅ
- បន្តសហការជាមួយបណ្តាម្ចាស់ផ្ទះសំណាក់ ផ្ទះជួល និងសណ្ឋាគារ ដើម្បីប្រមូលព័ត៌មាននិងទិន្នន័យជនបរទេសស្នាក់នៅរយៈពេលខ្លី និងរយៈពេលវែង ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់
- បន្តសហការជាមួយអធិការនគរបាលក្រុង ស្រុក និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងវត្តមានជនបរទេស និងត្រួតពិនិត្យស្រាវជ្រាវរកជនបរទេសដែលលួចចូលស្នាក់នៅ និងប្រកបមុខរបរមិនស្របច្បាប់
- បន្តចែកប្រកាសទទួលស្គាល់ជនបរទេសអន្តោប្រវេសន្ត និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនបរទេសអន្តោប្រវេសន្តប្រើប្រាស់តាមនីតិវិធីច្បាប់
- បន្តសហការជាមួយអង្គភាពពន្ធនាគារ ដើម្បីគ្រប់គ្រង និងប្រមូលទិន្នន័យជនបរទេសឱ្យបានជាប់ជាប្រចាំ
- បន្តជំរុញអធិការនគរបាលក្រុង ស្រុក អនុវត្តផែនការលេខ ០៩៥៨.ក របស់ស្នងការដ្ឋាននគរបាលខេត្ត ស្តីពីការគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីស្រាវជ្រាវរកឯកសារលិខិតឆ្លងដែនរបស់ជនបរទេសដែលស្នាក់នៅលើសទិដ្ឋាការ ដើម្បីបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ធ្វើការផាកពិន័យ និងបន្តនីតិវិធីបណ្តេញចេញពីប្រទេស។

## ២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ

- បន្តអប់រំមន្ត្រីឱ្យយល់ដឹងអំពីច្បាប់ ក្រមសីលធម៌ និងបទវិន័យរបស់មន្ត្រីពន្ធនាគារ
- បន្តអប់រំជនជាប់ឃុំឱ្យយល់ដឹងពី ក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាល
- បន្តរៀបចំវគ្គបណ្តុះបណ្តាលជនជាប់ឃុំឱ្យមានជំនាញ កាត់សក់ ដេរប៉ាក់ ជាងឈើ ជាងសំណង់ ជាងជួសជុលរថយន្ត និងផលិតឥដ្ឋបុក

- បន្តពិនិត្យរៀបចំកម្មវិធីផែនការកសិកម្ម និងឧស្សាហកម្មក្នុងពន្ធនាគារ
- បន្តលើកគោលការណ៍ ណែនាំដល់មន្ត្រីពន្ធនាគារ ពិសេសអនុវត្តកម្មវិធីគ្រប់គ្រងពន្ធនាគារ និងការផ្តត់ផ្គង់ជីវភាព សេវាថែទាំសុខភាពរបស់ជនជាប់ឃុំ និងអនាម័យក្នុងពន្ធនាគារ
- បន្តពិនិត្យ និងឆែកឆេរយ៉ាងហ្មត់ចត់ក្នុងតំបន់ឃុំឃាំង
- បន្តសហការជាមួយអង្គការលីកាដូ ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ ការពិនិត្យព្យាបាលជំងឺ និងផ្តល់ថ្នាំពេទ្យជូនជនជាប់ឃុំ និងចែកអំណោយជូនកូនតាមម្តាយក្នុងពន្ធនាគារខេត្ត។

របាយការណ៍ប្រចាំខែឧសភា ឆ្នាំ២០២៤ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី៦១ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកោះកុង នាថ្ងៃព្រហស្បតិ៍ ១៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤។

**អភិបាល**
**នៃគណៈអភិបាលខេត្ត**

**ពេលខ សុខវណ្ណាដា**

**ចម្លងជូនៈ**
- ក្រសួងមហាផ្ទៃ
- មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ
- ឯកសារកាលប្បវត្តិ

## ឧបសម្ព័ន្ធទី១៖ ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំខែ...... (គិតត្រឹមថ្ងៃទី......ខែ..........ឆ្នាំ២០...)

| ឈ្មោះ ក្រុង ស្រុក | ចំនួនគ្រួសារ | | | ប្រជាពលរដ្ឋទូទៅ | | | | | | ប្រជាពលរដ្ឋ១៨ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | | |
| | សរុប | អចិន្ត្រៃយ៍ | បណ្ដោះអាសន្ន | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | ក្នុង | ក្រៅ |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | | | | |

## ឧបសម្ព័ន្ធទី២៖ ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំខែមេសា ឆ្នាំ២០២៤

- ថវិកាគ្រោងសម្រាប់សកម្មភាពសេវាសង្គមនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ៖២៧.៦៤០.០០០រៀល ស្មើនឹង១០០% នៃថវិកាសរុប
- ចំណាយជាក់ស្តែងដែលបានបូកយោងសម្រាប់សកម្មភាពសេវាសង្គមចំនួន ១១.២៣៨.០០០រៀល ស្មើនឹង៤១% (គិតត្រឹមថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤)

| ល.រ. | ឈ្មោះសកម្មភាព | ថវិកាគ្រោង | %សកម្មភាពសម្រេចបាន | អ្នកទទួលផល | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| ក)-សុខភាពមាតា កុមារ និងអាហាររូបត្ថម្ភ | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| ខ)-ទឹកស្អាតនិងអនាម័យ | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| គ)-ការអប់រំកុមារតូច | | | | | |
| ១.១ | | | | | |
| ១.២ | | | | | |
| ឃ)-ការអប់រំបឋមសិក្សា និងមធ្យមសិក្សា | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| ង)-ការការពារស្ត្រី និងកុមារ | | | | | |
| ១.១ | | | | | |
| ១.២ | | | | | |
| ច)-កិច្ចគាំពារសង្គម | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| ឆ)-លំនៅឋាន | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| | | | | | |

## ឧបសម្ព័ន្ធទី៣៖ វឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគនៃរដ្ឋបាលខេត្ត ប្រចាំខែ...(ថវិការភាជន៍ពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសប្បុរសជន)

| ល.រ. | ឈ្មោះគម្រោង | គ្រោង/ជាក់ស្តែង | លទ្ធផលគម្រោង | តម្លៃ (លានរៀល) | ទីតាំងអនុវត្ត | អ្នកទទួលផល | | វិធីសាស្ត្រលទ្ធកម្ម | អ្នកទទួលការ | % អនុវត្ត | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ប្រុស | ស្រី | | | | |
| ក-ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ខ-ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| គ-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ឃ-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| ១ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |
| ២ | | គ្រោង | | | | | | | | | |
| | | ជាក់ស្តែង | | | | | | | | | |

ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី.......ខែ............ឆ្នាំ២០.